Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

# ការអភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលថ្មីៗ និងទស្សនវិស័យ

ខែមេសា ២០១៨



អត្ថបទជម្រើស៖

**របកគំហើញសង្ខេបអំពីការងារនាពេលអនាគតនៅកម្ពុជា**

ក្រុមធនាគារពិភពលោក

**រូបភាពគម្រប៖** © ithinkasia

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

# ការអភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលថ្មីៗ និងទស្សនវិស័យ

ខែមេសា ២០១៨

អត្ថបទជម្រើស៖

**របកគំហើញសង្ខេបអំពីការងារនាពេលអនាគតនៅកម្ពុជា**

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ........ ២

**បញ្ជីអក្សរកាត់** ........ ៣

**ខ្លឹមសារសង្ខេប** ........ ៤

**ផ្នែកទី ១: ការអភិវឌ្ឍន៍សេដ្ឋកិច្ចថ្មីៗ និងទស្សនវិស័យ** ........ ៨

១. ការអភិវឌ្ឍន៍សេដ្ឋកិច្ចថ្មីៗ ........ ៨

*ក) វិស័យផលិត* ........ ៨

*ខ) វិស័យពាណិជ្ជកម្មក្រៅប្រទេស* ........ ១៧

*គ) ភាពក្រីក្រ* ........ ១៩

*ឃ) វិស័យរូបិយវត្ថុ* ........ ២២

*ង) វិស័យសារពើពន្ធ* ........ ២៧

២. ទស្សនវិស័យ និងហានិភ័យ ........ ៣២

៣. អនុសាសន៍សំខាន់ៗ ........ ៣៣

**ផ្នែកទី ២ ៖ អត្ថបទជម្រើស ការងារនាពេលអនាគត នៅកម្ពុជា** ........ ៣៥

១. សេចក្តីផ្តើម ........ ៣៥

២. ស្ថានភាពការងារបច្ចុប្បន្ន ........ ៣៦

*ក) ការផ្លាស់ប្តូររចនាសម្ព័ន្ធ* ........ ៣៦

*ខ) ទិដ្ឋភាពការងារ* ........ ៣៨

*គ) ការចូលរួមរបស់កម្លាំងពលកម្ម* ........ ៣៩

៣. ការងារនៅពេលអនាគត ........ ៤១

*ក) ឱកាស និងឧបសគ្គ* ........ ៤១

*ខ) សហគ្រាសៈ កង្វះខ្នាតមធ្យម* ........ ៤៤

*គ) ពាណិជ្ជកម្ម និងការវិនិយោគផ្ទាល់ពីបរទេស* ........ ៤៥

*ឃ) សហគ្រាសគ្រួសារមិនមែនកសិដ្ឋាន* ........ ៤៦

*ង) កម្មករនិយោជិត* ........ ៤៦

៤. ទិសដៅយុទ្ធសាស្ត្រសម្រាប់ការងារនៅពេលអនាគត៖ ឆ្ពោះទៅរកការងារល្អប្រសើរ និងមានការចូលរួម ........ ៥០

*ក) ជម្រើសគោលនយោបាយតាមវិស័យ* ........ ៥០

*ខ) ជម្រើសគោលនយោបាយអន្តរវិស័យ* ........ ៥១

**ប្រទេសកម្ពុជា៖ សូចនាករសំខាន់ៗ** ........ ៥៣

# សេចក្តីថ្លែងអំណរគុណ

ការរៀបចំរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១៨ នៅកម្ពុជា (CEU) ស្ថិតក្រោមការដឹកនាំរបស់លោក លី សុដេត ដោយមានការរួមចំណែកពីលោក Miguel Eduardo Sánchez Martín។ អត្ថបទជម្រើស គឺ “ការងារនាពេលអនាគតនៅកម្ពុជា” ដែលត្រូវបានរៀបចំឡើងដោយ Wendy Cunningham និង Claire Honore Hollweg។ លោកស្រី គី លីនណា បានផ្តល់ការគាំទ្រខាងបច្ចេកទេស និងផ្នែកភ័ស្តុភារដល់ការបោះពុម្ពផ្សាយ ចំណែកឯ លោក ភឹម រុនស៊ីណារិទ្ធ បានផ្តល់ការគាំទ្រដល់ការស្រាវជ្រាវ។ លោក តុង គឹមស៊ុន ផ្តល់ធាតុចូលផ្នែកធាតុក្រីក្រ។ ក្រុមការងារទំនាក់ទំនងនៃការិយាល័យធនាគារពិភពលោក រួមមាន លោក ប៊ូ សារឿន និង លោកស្រី សំអឿន សុភីនិត្យ បានជួយដល់ការចេញផ្សាយព័ត៌មាន ការបង្ហាញគេហទំព័រ និងការផ្សព្វផ្សាយព្រឹត្តការណ៍នានា។

ក្រុមការងារនេះ បានធ្វើការក្រោមការដឹកនាំរបស់ លោក Deepak Mishra។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះដំបូន្មាន និងយោបល់ដែលផ្តល់ឱ្យដោយលោកស្រី Ellen A. Goldstein និងលោកស្រី Inguna Dobraja។ សហសេវិករបស់ធនាគារពិភពលោកមួយចំនួន រួមមាន Andy Mason, Ekaterine T. Vashakmadze, Ha Minh Nguyen, Shabih Ali Mohib និង Sudhir Shetty បានផ្តល់យោបល់លើសេចក្តីព្រាងនៃរបាយការណ៍នេះ។

ក្រុមការងារសូមអរគុណដល់អាជ្ញាធរកម្ពុជា ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់ពួកគេ។ របាយការណ៍ក៏ទទួលបានផលប្រយោជន៍ពីដំបូន្មាន យោបល់ និងទស្សនៈរបស់អ្នកពាក់ព័ន្ធនានានៅក្នុងប្រទេសកម្ពុជា រួមទាំងអ្នកអាន និងអ្នករិះគន់ផងដែរ។

របាយការណ៍នេះត្រូវបានផលិតពីរដងក្នុងមួយឆ្នាំ ផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពីការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ ឯកសារនេះត្រូវបានចែកចាយ និងពិភាក្សាយ៉ាងទូលំទូលាយ រួមទាំងក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ អង្គការសង្គមស៊ីវិល និងសាកលវិទ្យាល័យនានា។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារពិភពលោកនៅកម្ពុជា សូមមើលគេហទំព័ររបស់យើងតាមរយៈអាសយដ្ឋាន: www.worldbank.org/cambodia ។

ដើម្បីបញ្ចូលនៅក្នុងបញ្ជីចែកចាយអ៊ីមែល CEU និងការបោះពុម្ពផ្សាយដែលពាក់ព័ន្ធសូមទាក់ទង លោកស្រី គី លីនណា (lky@worldbank.org)។សម្រាប់សំណួរអំពីខ្លឹមសារនៃអត្ថបទនេះសូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank.org)។

# បញ្ជីអក្សរកាត់

| | |
|---|---|
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **CPI** | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ |
| **CR** | ប្រាក់រៀល |
| **EU** | សហភាពអឺរ៉ុប |
| **FCD** | ប្រាក់បញ្ញើរូបិយប័ណ្ណបរទេស |
| **FDI** | វិនិយោគដោយផ្ទាល់ពីបរទេស |
| **GDP** | ផលិតផលក្នុងស្រុកសរុប |
| **GIR** | ទុនបម្រុងអន្តរជាតិសរុប |
| **GNI** | ចំណូលជាតិសរុប |
| **IDP** | គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម |
| **IMF** | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| **LPCO** | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា |
| **MA** | មធ្យមភាគប្រែប្រួល |
| **MoEYS** | ក្រសួងអប់រំ យុវជន និងកីឡា |
| **NCDs** | វិញ្ញាបនប័ត្របញ្ញើដែលអាចជួញដូរបាន |
| **NFHE** | សហគ្រាសគ្រួសារមិនមែនកសិដ្ឋាន |
| **NPL** | កម្ចីមិនដំណើរការ |
| **NSDP** | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| **PDR** | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត |
| **PFM** | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **RMS** | យុទ្ធសាស្ត្រប្រមូលចំណូល |
| **SDR** | សិទ្ធិដកប្រាក់ពិសេស |
| **SMEs** | សហគ្រាសធុនតូចនិងមធ្យម |
| **SPPF** | ក្របខ័ណ្ឌគោលនយោបាយគាំពារសង្គម |
| **TVET** | ការអប់រំ និង បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| **US$** | ដុល្លារអាមេរិក |
| **VAT** | ពន្ធលើតម្លៃបន្ថែម |
| **WBG** | ក្រុមធនាគារពិភពលោក |
| **YTD** | ពីដើមឆ្នាំដល់បច្ចុប្បន្ន |
| **y/y** | ធៀបនឹងឆ្នាំមុន |




# ខ្លឹមសារសង្ខេប

*ខណៈពេលដែលសេដ្ឋកិច្ចនៅតែបន្តរីកចម្រើនយ៉ាងឆាប់រហ័សនៅកម្ពុជា កំណើន ផសស ពិតបានថមថយពី ៧ ភាគរយ នៅឆ្នាំ ២០១៦ មកត្រឹម ៦,៨ ភាគរយនៅឆ្នាំ ២០១៧។ ដូច្នេះ ប្រទេសកម្ពុជាបានធ្វើដំណើរផ្ទុយនឹងនិន្នាការក្នុងតំបន់ ដោយសារតែប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើននៅអាស៊ីបូព៌ាបានបង្កើនកំណើននៅឆ្នាំ ២០១៧។ បន្ទាប់ពីមានការថយចុះកំណើននៅឆមាសទីមួយនៃឆ្នាំ ២០១៧ ការនាំចេញវាយនភ័ណ្ឌ និងសម្លៀកបំពាក់បានកើនឡើងសាជាថ្មី។ វិស័យ ទេសចរណ៍ និងកសិកម្ម បានងើបឡើងវិញជាលើកដំបូងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយបន្ទាប់ពីប្រឈមនឹងការធ្លាក់ចុះបន្តិចម្តងៗ។ កំណើនត្រូវបានព្យាករណ៍ថានឹងនៅតែរឹងមាំ និងកើនឡើង ៦,៩ ភាគរយនៅឆ្នាំ ២០១៨។ ហានិភ័យចំពោះទស្សនវិស័យនេះ រួមមាន ការបាត់បង់ភាពប្រកួតប្រជែងក្នុងការនាំចេញដោយសារការតម្លើងប្រាក់ឈ្នួលពិតយ៉ាងឆាប់រហ័ស ការបង្កើនភាពងាយរងគ្រោះពីសន្ទុះនៃការរីកចម្រើនរយៈពេលយូរនៃផ្នែកអចលនទ្រព្យ និងសំណង់ សក្ដានុភាពនៃភាពមិនច្បាស់លាស់ទាក់ទងនឹងការបោះឆ្នោត និងការប្រែប្រួលដែលតែងកើតឡើងជារឿយៗចំពោះរបបពាណិជ្ជកម្មអន្តរជាតិក្នុងទម្រង់គាំពារនិយម និងកំណើនវិវាទពាណិជ្ជកម្ម។*

## ការអភិវឌ្ឍន៍ថ្មីៗ

**កំណើនសេដ្ឋកិច្ចនៅតែមានភាពរឹងមាំ ដែលទ្រទ្រង់ដោយតម្រូវការក្រៅប្រទេស ដែលមានភាពសុទិដ្ឋិនិយម។** យោងតាមការប៉ាន់ប្រមាណបឋមរបស់អាជ្ញាធរកម្ពុជា កំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានថានឹងថមថយមកត្រឹម ៦,៨ ភាគរយនៅឆ្នាំ ២០១៧។ ការនាំចេញវាយនភ័ណ្ឌ និងសម្លៀកបំពាក់ទៅសហភាពអឺរ៉ុប (រួមទាំងចក្រភពអង់គ្លេស) បានកើនឡើងក្នុងកម្រិតល្អប្រសើរស្មើនឹង ៧,៤% (ធៀបនឹងឆ្នាំមុន) គិតត្រឹមខែធ្នូឆ្នាំ ២០១៧ ធៀបនឹងកំណើនប្រចាំឆ្នាំ -១,០% ក្នុងខែ ឧសភា ឆ្នាំ ២០១៧។ ដូចគ្នាដែរ ការនាំចេញវាយនភ័ណ្ឌ និងសម្លៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិកបានងើបឡើងវិញយ៉ាងឆាប់រហ័ស ដោយកើនឡើង ៣,៧ ភាគរយ ធៀបទៅនឹង -៣,៥ ភាគរយ ក្នុងកំឡុងពេលដូចគ្នា។ ទោះបីជាប្រាក់ឈ្នួលពិតកើនឡើងយ៉ាងឆាប់រហ័សក្តី ក៏ការនាំចេញវាយនភ័ណ្ឌ និងសម្លៀកបំពាក់បានកើនឡើងយ៉ាងល្អ គឺកើនឡើង ៧,៧ ភាគរយ ក្នុងឆ្នាំ ២០១៧ ដែលថយចុះបន្តិចពី ៨,៤ ភាគរយ ក្នុងឆ្នាំ ២០១៦។ ការមកដល់នៃភ្ញៀវទេសចរបានកើនដល់ ១១,៨ ភាគរយ ក្នុងឆ្នាំ ២០១៧ ធៀបនឹង ៥ ភាគរយ ក្នុងឆ្នាំ ២០១៦ ដោយសារការខិតខំប្រឹងប្រែងរបស់អាជ្ញាធរដើម្បីបង្កើតជើងហោះហើរក្នុងតំបន់បន្ថែមទៀត រួមទាំងការដាក់ឲ្យប្រើប្រាស់គំនិតផ្តួចផ្តើម

“ចិនត្រៀមខ្លួនជាស្រេច”។ វិស័យកសិកម្មក៏បានងើបឡើងវិញជាមួយនឹងការពង្រីកដំណាំស្រូវ និងកៅស៊ូ ដោយសារតែលក្ខខណ្ឌអាកាសធាតុអំណោយផល និងការងើបឡើងវិញជាបណ្តើរៗនៃថ្លៃទំនិញកសិកម្ម។

**ទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាមិនអាចទាញយកអត្ថប្រយោជន៍ច្រើនពីការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកដូចប្រទេសជិតខាងក្នុងតំបន់នោះទេ។** សេដ្ឋកិច្ចនៃប្រទេសចិន ឥណ្ឌូនេស៊ី ថៃ និងវៀតណាម មានការពន្លឿនកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០១៧។ ដូចគ្នានេះដែរបណ្តាក្រុមប្រទេសអាស៊ានមានកំណើន ៥,៤ ភាគរយ ក្នុងឆ្នាំ ២០១៧ ធៀបនឹង ៤,៩ ភាគរយក្នុងឆ្នាំ ២០១៦ ។ ការបង្កើនល្បឿនកំណើនភាគច្រើនរបស់ពួកគេគឺដោយសារការបង្កើនការនាំចេញ។ ក្នុងករណីប្រទេសកម្ពុជាវិញ ការនាំចេញក៏បានដំណើរការយ៉ាងល្អដែរ ប៉ុន្តែ ពុំមានកម្រិតដូចគ្នានឹងបណ្តាប្រទេសជិតខាងក្នុងតំបន់ ដែលជាការបង្ហាញថា សេដ្ឋកិច្ចកម្ពុជាមានបញ្ហារចនាសម្ព័ន្ធច្រើន។

**ការប្រើប្រាស់របស់ឯកជនបានថយចុះ ធ្វើឱ្យអតិផរណាថយចុះ ខណៈការពង្រីកឥណទានបានថយចុះ។** អតិផរណាបានធ្លាក់ចុះដល់ ២,២ ភាគរយនៅចុងឆ្នាំ ២០១៧ ធៀបទៅនឹង ៣,៩ ភាគរយ នៅឆ្នាំ ២០១៦។ ខណៈដែលកំណើនឥណទានសរុបរបស់ធនាគារធ្លាក់មកត្រឹម ១៩,៦ ភាគរយ នៅឆ្នាំ ២០១៧ ពី ២៥,៨ ភាគរយ នៅឆ្នាំ ២០១៦ ការផ្តល់ហិរញ្ញប្បទានឥណទានក្នុងស្រុកចំពោះវិស័យសំណង់ និងអចលនទ្រព្យ បានកើនឡើងជាថ្មីម្តងទៀត គឺកើនឡើងពី ២៨,៤% ក្នុងខែឧសភា ឆ្នាំ ២០១៧ មក ៣៧,១% ក្នុងខែវិច្ឆិកា ឆ្នាំ ២០១៧ មក ដោយសារតែតម្រូវការសម្រាប់វិស័យសំណង់ និងអចលនទ្រព្យបានងើបឡើងវិញ។

**គោលនយោបាយវិនិយោគ និងពាណិជ្ជកម្មសេរីរបស់ប្រទេសកម្ពុជានៅតែបន្តទាក់ទាញលំហូរវិនិយោគទុនផ្ទាល់ពីបរទេស (FDI)។** ដោយសារការនាំចូលតិចតួចជាងមុន បណ្តាលមកពីការថមថយនូវតម្រូវការក្នុងស្រុក ឱនភាពគណនីចរន្តបានរួមតូចមកត្រឹម ៩,៨ ភាគរយនៃ ផសស ដោយសារតែហិរញ្ញប្បទានពីលំហូរវិនិយោគទុនផ្ទាល់ពីបរទេស។ ប្រាក់បញ្ញើធនាគារ (ភាគច្រើនជាដុល្លារអាមេរិកដោយសារដុល្លារូបនីយកម្មខ្ពស់) បានកើនឡើង គឺ កើនឡើង ២៣,៣ ភាគរយ ក្នុងខែ ធ្នូ ឆ្នាំ ២០១៧។ ទុនបម្រុងបរទេសសរុបបានកើនឡើងដល់ ៨,៧ ប៊ីលានដុល្លារ ឬស្មើនឹងការនាំចូល ៦,៨ ខែ។ ប្រាក់រៀល (CR) ដែលត្រូវបានភ្ជាប់ជាមួយប្រាក់ដុល្លារអាមេរិក នៅតែមានស្ថិរភាព ស្មើនឹង ៤,០០០ រៀលក្នុងមួយដុល្លារអាមេរិកក្នុងខែ មីនា ឆ្នាំ ២០១៨។

**ការប្រមូលប្រាក់ចំណូលមានភាពល្អប្រសើរជាងការរំពឹងទុកបានជួយទប់ស្កាត់ឱនភាពទូទៅរបស់រដ្ឋាភិបាលដែលស្ថិតនៅក្រោមសម្ពាធនៅពេលដែលបញ្ជីចំណាយប្រាក់ខែកើនឡើង។** ឱនភាពសារពើពន្ធ (មិនរាប់បញ្ចូលជំនួយឥតសំណង) ត្រូវបានប៉ាន់ស្មានថាបានថយចុះពី ៣,៦ភាគរយ នៅឆ្នាំ ២០១៦ មកនៅត្រឹម ២,៧ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០១៧។ ខណៈដែលថវិកាប្រចាំឆ្នាំ ២០១៨ នៅតែបន្តឆ្លុះឲ្យឃើញបញ្ជីចំណាយប្រាក់ខែ ដែលកើនឡើងដល់ ៨,៤ ភាគរយនៃ ផសស នេះគឺជាលើកទីមួយហើយដែលថវិកាវិនិយោគសាធារណៈមានកំណើនយ៉ាងខ្ពស់រហូតដល់ ៧,៨ ភាគរយនៃ ផសស។ តាមការវិភាគផ្នែកនិរន្តរភាពបំណុលរបស់ធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិឆ្នាំ ២០១៧ កម្រិតសម្ពាធបំណុលរបស់កម្ពុជានៅតែមានកម្រិតទាបនៅឡើយ។

## ទស្សនវិស័យ

**គន្លងកំណើនខ្ពស់របស់ប្រទេសកម្ពុជាត្រូវរំពឹងថានឹងបន្តទៅទៀត។** កំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ៦,៩ ភាគរយនៅឆ្នាំ ២០១៨ ដែលគាំទ្រដោយការបង្កើនចំណាយរបស់រដ្ឋាភិបាល និងស្ថានភាពពិភពលោកអំណោយផល រួមទាំងតម្រូវការដ៏រឹងមាំនៅក្នុងប្រទេសជឿនលឿន។ ទោះជាយ៉ាងណាក៏ដោយ អត្រាកំណើនរបស់ប្រទេសកម្ពុជាត្រូវបានរំពឹងថានឹងថយចុះជាបន្តបន្ទាប់ ប្រសិនបើបញ្ហាជារចនាសម្ព័ន្ធ (ឧទាហរណ៍ការបាត់បង់ភាពប្រកួតប្រជែង) មិនត្រូវបានដោះស្រាយទេនោះ។ គេរំពឹងថា ការប្រកាសអំពីយុទ្ធសាស្ត្រចតុកោណថ្មីក្រោយការបោះឆ្នោតនឹងធ្វើឱ្យកំណែទម្រង់កើនឡើង។ ដូច្នេះ ក្នុងរយៈពេលមធ្យម លំហូរវិនិយោគទុនផ្ទាល់ពីបរទេស និងការបង្កើនវិនិយោគសាធារណៈយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានរំពឹងថានឹងជួយពង្រីកសមត្ថភាពផលិតកម្មនៃសេដ្ឋកិច្ច។ ចំណុចនេះ រួមជាមួយការកែទម្រង់រចនាសម្ព័ន្ធជាច្រើនដែលត្រូវបានរៀបចំឡើងជាចម្បងដើម្បីបង្កើនភាពប្រកួតប្រជែងខាងក្រៅប្រទេសរបស់កម្ពុជា អាចជួយជំរុញល្បឿនកំណើនក្នុងរយៈពេលវែង។

**ហានិភ័យចំពោះទស្សនវិស័យ នៅតែចង្អុលឆ្ពោះទៅភាពអវិជ្ជមាន។** នៅក្នុងស្រុក ហានិភ័យមានទំនាក់ទំនងជាមួយនឹងសន្ទុះកំណើនផ្នែកអចលនទ្រព្យ និងសំណង់ដែលអូសបន្លាយរយៈពេលវែង សក្តានុពលនៃភាពមិនច្បាស់លាស់ទាក់ទងនឹងការ

បោះឆ្នោតសកលខែកក្កដា ឆ្នាំ២០១៨ និងការថយចុះនៃភាពប្រកួតប្រជែងក្រៅប្រទេស។ នៅក្រៅស្រុក ហានិភ័យមានទំនាក់ទំនងជាមួយនឹងពាណិជ្ជកម្មសកលលោកដែលមានលក្ខណៈមិនប្រាកដប្រជាដោយសារនយោបាយគាំពារនិយមមានការកើនឡើង។ លើសពីនេះទៀត កំណើនការងារទំនងជាមិនមានភាពច្បាស់លាស់។ ដោយសារប្រាក់ខែពិតកើនឡើងយ៉ាងឆាប់រហ័ស ភាពប្រកួតប្រជែងក្រៅប្រទេសរបស់កម្ពុជាដែលពឹងផ្អែកជាចម្បងលើកម្លាំងពលកម្មថោកនោះ កំពុងតែបាត់បង់។ ជាលទ្ធផល ល្បឿននៃការកាត់បន្ថយភាពក្រីក្រអាចមានភាពយឺតយ៉ាវនាពេលអនាគត។

## អនុសាសន៍ និងជម្រើសគោលនយោបាយគន្លឹះ

**វិនិយោគដើម្បីអភិវឌ្ឍធនធានមនុស្ស។** កំលាំងពលកម្មដែលមានជំនាញជួយជំរុញសន្ទុះកំណើនផលិតភាព និងប៉ះប៉ូវចំពោះការតម្លើងប្រាក់ខែពិតឆាប់រហ័ស ហើយក៏គាំទ្រដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធដែលកំពុងដំណើរការបន្ត។ ក្នុងន័យនេះ ជោគជ័យនៃការអន្តរាគមន៍គោលនយោបាយណាមួយទំនងជាពឹងផ្អែកលើប្រសិទ្ធភាពនៃការលើកទឹកចិត្ត និងដំណើរការនានា ដើម្បីសម្រួលដល់តួនាទីរបស់វិស័យសហគ្រាសក្នុងការផ្តល់ការណែនាំ និងការជំរុញឲ្យមានប្រព័ន្ធអភិវឌ្ឍន៍ជំនាញដែលឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារការងារ (សូមមើលបញ្ហាជាអាទិភាពស្តីពីការងារនាពេលអនាគតនៅកម្ពុជា)។ ដូច្នេះ ការដោះស្រាយឧបសគ្គលើផ្នែកជំនាញដូចដែលបានលើកឡើងនៅក្នុងគោលនយោបាយជាតិស្តីពីការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧ គឺជាអាទិភាពមួយ។ ការសម្របសម្រួលកាន់តែច្រើនក្នុងចំណោមអង្គភាពសាធារណៈ និងឯកជន នឹងមានសារៈសំខាន់ចាំបាច់ចំពោះការអនុវត្តក្របខណ្ឌនេះដោយជោគជ័យ។

**ការដោះស្រាយបញ្ហាប្រឈមចំពោះអាជីវកម្មខ្នាតតូច និងសហគ្រាសនានា អាចគាំទ្រដល់ការធ្វើពិពិធកម្ម ទន្ទឹមនឹងការជំរុញកំណើនការងារ។** ការកាត់បន្ថយថ្លៃដើម្បីធ្វើឲ្យសហគ្រាសមានលក្ខណៈផ្លូវការ ថ្លៃដំណើរការ និងថ្លៃហិរញ្ញប្បទាន មានសារៈសំខាន់ រួមទាំងការផ្តល់ការលើកទឹកចិត្ត និងលទ្ធភាពទទួលបានកម្មវិធីគាំទ្រផ្សេងៗ។ ការដាក់ឲ្យដំណើរការនូវការគាំទ្រផ្នែកគោលនយោបាយដើម្បីលើកកម្ពស់សហគ្រាសខ្នាតតូច និងមធ្យម និងសហគ្រាសគ្រួសារមិនមែនកសិកម្ម នឹងជួយបង្កើតការងារ។ ការគាំទ្រគោលនយោបាយសក្តានុពលអាចរួមទាំង ការអភិវឌ្ឍន៍ជំនាញសម្រាប់ម្ចាស់ក្រុមហ៊ុន និងការអភិវឌ្ឍន៍ ព្រមទាំងការទទួលបានបច្ចេកវិទ្យាឌីជីថល និងបច្ចេកវិទ្យាអ៊ិនធើណិត។ ការជំរុញការវិនិយោគក្នុងស្រុក រួមទាំងការកែច្នៃកសិផល ក៏អាចជួយពង្រឹងទំនាក់ទំនងទៅកាន់អាជីវកម្ម និងក្រុមហ៊ុននាំចេញរបស់ជនបរទេសដែរ។

**សន្ទុះរីកចម្រើននៃវិស័យសំណង់ និងអចលនទ្រព្យដែលកំពុងប្រព្រឹត្តទៅតម្រូវឲ្យមានការឃ្លាំមើលៈយ៉ាងដិតដល់។** កំណើនឥណទានដែលបានផ្តល់ឲ្យវិស័យសំណង់ និងអចលនទ្រព្យ បាន និងកំពុងកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ដូច្នេះ ការបង្កើតគោលនយោបាយប្រុងប្រយ័ត្នផ្នែកម៉ាក្រូសេដ្ឋកិច្ច សំដៅកាត់បន្ថយសកម្មភាពប្រថុយប្រថាន គឺជាការចាំបាច់។ នៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ទាមទារឲ្យមានការអនុម័តគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន និងត្រូវមានការតាមដានឱ្យបានគ្រប់គ្រាន់ នៅពេលធ្វើការពិនិត្យឡើងវិញលើចំណាត់ថ្នាក់ឥណទានមិនដំណើរការ។

# រូប១: ទិដ្ឋភាពរួមនៃសេដ្ឋកិច្ចកម្ពុជា

**កំណើនសេដ្ឋកិច្ចបានថយល្បឿនបន្តិចក្នុងឆ្នាំ ២០១៧**
ការរួមចំណែកចំពោះកំណើន (ភាគរយ)




**ការនាំចេញសម្លៀកបំពាក់បន្តកើនឡើង ទោះជាមានការតម្លើងប្រាក់ឈ្នួលពិតក្តី** (លានដុល្លារ)




**ផលិតកម្មកសិកម្ម ជាពិសេសស្រូវអង្ករបានកើនឡើង**
ការរួមចំណែកចំពោះការបង្កើនផលិតកម្ម (លានតោន)




**កំណើនលំហូរវិនិយោគទុនផ្ទាល់បានពង្រឹងវិស័យពាណិជ្ជកម្មក្រៅប្រទេស បង្កើនទុនបម្រុងបរទេស**




**អត្រាការប្រាក់រយៈពេលខ្លីថយចុះដែលជួយសម្រួលដល់វិនិយោគឯកជន**




**ចំណាយសាធារណៈត្រូវបានបង្កើនធ្វើអោយវិនិយោគសាធារណៈកើនឡើង** (ភាគរយនៃ ផផស)




*ប្រភព៖* ការប៉ាន់ប្រមាណរបស់អាជ្ញាធរកម្ពុជា និងរបស់បុគ្គលិកធនាគារពិភពលោក។
*សម្គាល់៖* e=ប៉ាន់ស្មាន GIR= ប្រាក់បម្រុងអន្តរជាតិ ដុល P= ការព្យាករ RHS=ផ្នែកខាងស្តាំ



# ផ្នែកទី ១៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ចថ្មីៗ និងទស្សនវិស័យ

## ១. ការអភិវឌ្ឍន៍សេដ្ឋកិច្ចថ្មីៗ

### ក) វិស័យផលិត

**កំណើននៅតែរឹងមាំដែលទទួលការគាំទ្រដោយតម្រូវការក្រៅប្រទេសមានភាពសុទិដ្ឋិនិយម។** យោងតាមការប៉ាន់ស្មានជំហានបឋមរបស់អាជ្ញាធរ កំណើនបានថយចុះពីជិត ៧ ភាគរយ នៅឆ្នាំ ២០១៦ មក ៦.៨ ភាគរយ ក្នុងឆ្នាំ ២០១៧ (រូប ១)។ បន្ទាប់ពីការថយចុះជាបណ្តើរៗនៅដើមឆ្នាំ ២០១៧ ការនាំចេញវាយនភ័ណ្ឌ និងសម្លៀកបំពាក់ បានងើបឡើងវិញនៅឆមាសទី ២ ក្នុងឆ្នាំដដែល នៅពេលសេដ្ឋកិច្ចសាកលគ្រប់វិស័យកំពុងតែងើបឡើងវិញ ដែលទទួលបានការគាំទ្រដោយការងើបឡើងវិញនៃវិនិយោគបរទេស[១] (សូមមើលប្រអប់ ១ ស្តីពីទស្សនវិស័យ និងហានិភ័យសកល និងក្នុងតំបន់)។ វិស័យទេសចរណ៍ និងវិស័យកសិកម្ម បានបន្តងើបឡើងវិញ ចំណែកឯតម្រូវការសម្រាប់ការវិនិយោគលើវិស័យសំណង់ និងអចលនទ្រព្យ នៅតែមានការកើនឡើង។

**រូប ១៖ ការរួមចំណែកដល់កំណើនពិត (ភាគរយ)**




*ប្រភព៖* វិទ្យាស្ថានជាតិស្ថិតិ
*សម្គាល់៖* P = បឋម

១ ចក្ខុវិស័យសេដ្ឋកិច្ចសកលនាខែមករាឆ្នាំ២០១៨ ដោយធនាគារពិភពលោក

## ប្រអប់ ១៖ ទស្សនវិស័យ និងហានិភ័យក្នុងសកលលោក និងក្នុងតំបន់

កំណើនសេដ្ឋកិច្ចជាសកលត្រូវបានព្យាករណ៍ថានឹងឡើងដល់កម្រិតខ្ពស់បំផុត ស្មើនឹង ៣.២ ភាគរយនៅឆ្នាំ ២០១៨ ខណៈពេលដែលបម្រែបម្រួលតាមវដ្តនៅតែបន្ត។ បន្ទាប់មក កំណើននេះនឹងថយចុះបន្តិចមកត្រឹម ៣ ភាគរយជាមធ្យម ក្នុងឆ្នាំ ២០១៩-២០២០ ដែលឆ្លុះឲ្យឃើញពីការការធ្លាក់ចុះបន្តិចម្តងៗ នៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន (រូប ខ ១.១)។ បន្ទាប់ពីមានការងើបឡើងវិញជាទូទៅនៅឆ្នាំ ២០១៧ កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនត្រូវបានព្យាករណ៍ក្នុងកម្រិត ២,៤ ភាគរយនៅឆ្នាំ ២០១៨ និងថមថយចុះទៅ ១,៨ ភាគរយ ជាមធ្យមនៅឆ្នាំ ២០១៩-២០ ដោយហេតុថា ទីផ្សារការងារមានលក្ខណៈចង្អៀតជាងមុន ហើយការអនុវត្តគោលនយោបាយរូបិយវត្ថុលែងសូវមានប្រសិទ្ធភាព។

ត្រូវបានរំពឹងថានឹងកើនឡើងខ្ពស់បំផុតដល់ ៥,៤ ភាគរយនៅឆ្នាំ ២០១៨ ហើយនៅតែរក្សាស្ថិរភាពជុំវិញអត្រាសក្តានុពលរបស់វាក្នុងឆ្នាំ ២០១៩។ ទស្សនវិស័យនេះពឹងផ្អែកលើតម្លៃទំនិញមានស្ថិរភាពទូទៅ និងតម្រូវការសកលដែលមានលក្ខណៈរឹងមាំ ប៉ុន្តែថមថយបន្តិចម្តងៗ និងការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញប្បទានសកលលោកមានជាបន្តបន្ទាប់។ ថ្វីបើមានការព្យាករថា សកម្មភាពមានសភាពរឹងមាំនៅក្នុងតំបន់ក្នុងរយៈពេលខ្លីក៏ដោយ ក៏កំណើនសក្តានុពលដែលបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ហាក់ដូចជាបានធ្លាក់ចុះក្នុងរយៈពេលវែង ឆ្លុះឲ្យឃើញពីលំនាំប្រជាសាស្ត្រមានភាពអវិជ្ជមាន និងការព្យាករអំពីល្បឿនយឺតនៃការគៀរគរបង្កើនមូលធន ដែលចាំបាច់សម្រាប់ទប់ទល់កំណើនផលិតភាពទាប។

**រូប ខ១.១៖ កំណើនផលិតផលក្នុងស្រុកសរុបពិត** (ភាគរយ)




*ប្រភព៖* ហិរញ្ញវត្ថុអភិវឌ្ឍន៍ពិភពលោក ខែមិថុនា ២០១៨ (ទិសដៅអនាគត)
*សម្គាល់៖* f = ការព្យាករណ៍

**រូប ខ១.២៖ កំណើនផលិតផលក្នុងស្រុកសរុបពិត** (ភាគរយ)




*ប្រភព៖* ហិរញ្ញវត្ថុអភិវឌ្ឍន៍ពិភពលោក ខែមិថុនា ២០១៨ (ទិសដៅអនាគត)

កំណើនក្នុងទីផ្សារកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ត្រូវបានរំពឹងថានឹងឡើងដល់កម្រិតខ្ពស់បំផុតក្នុងរយៈពេល ៥ ឆ្នាំ គឺ ៤,៥% ក្នុងឆ្នាំ ២០១៨ និងមានស្ថិរភាពជាមធ្យម ៤,៧ ភាគរយក្នុងឆ្នាំ ២០១៩-២០។ ស្ថានភាពនេះឆ្លុះឲ្យឃើញជាសំខាន់ពីការកើនឡើងបន្ថែមទៀតទៅតាមវដ្តជាបន្តបន្ទាប់នៃកំណើនក្រុមហ៊ុននាំចេញទំនិញនៅពេលដែលផលប៉ះពាល់នៃការធ្លាក់ចុះថ្លៃទំនិញពីពេលមុនបានសាបរលត់។ ការថយចុះជាបន្តបន្ទាប់នៅប្រទេសចិនត្រូវបានរំពឹងថានឹងត្រូវទប់ទល់ដោយការកើនឡើងខ្លះៗនៃប្រទេសដទៃទៀតក្នុងក្រុមនេះដែលបង្ហាញពីការធ្លាក់ចុះនៃតួនាទីនៃកត្តាឯកជនដែលផ្អែកលើសកម្មភាពនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចធំៗមួយចំនួននៅឆ្នាំ ២០១៧។

កំណើននៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ត្រូវបានរំពឹងថានឹងថយចុះបន្តិចពី ៦,៣ ភាគរយក្នុងឆ្នាំ ២០១៨ ដល់ ៦,១% ជាមធ្យម ក្នុងឆ្នាំ ២០១៩-២០២០ (រូប ខ ១.២)។ កំណើនក្នុងតំបន់ធ្លាក់ចុះបន្តិចបណ្តាលមកពីការធ្លាក់ចុះជាបណ្តើរៗតាមផែនការបន្ថយកំណើនជារចនាសម្ព័ន្ធនៅប្រទេសចិន។ សកម្មភាពនៅប្រទេសផ្សេងទៀតក្នុងតំបន់នេះ

**រូប ខ១.៣៖ ការព្យាករតម្លៃទំនិញនៅលើពិភពលោក**
(ដុល្លារអាមេរិកដុល្លារឆ្នាំ ២០១០= ១០០)




*ប្រភព៖* ហិរញ្ញវត្ថុអភិវឌ្ឍន៍ពិភពលោក, ខែមិថុនា ២០១៨ (នឹងត្រូវផ្សព្វផ្សាយនាពេលខាងមុខ)

## ប្រអប់ ១៖ ទស្សនវិស័យ និងហានិភ័យក្នុងសកលលោក និងក្នុងតំបន់ (បន្ត)

និន្នាការសកលត្រូវបានរំពឹងថានឹងមានការគាំទ្រតិចក្នុងអំឡុងពេលព្យាករណ៍។ ពាណិជ្ជកម្មពិភពលោកដែលបានកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ ២០១៧ ដោយទទួលបានអត្ថប្រយោជន៍ពីការកើនឡើងទៅតាមវដ្តក្នុងការផលិតនៅលើពិភពលោក ត្រូវបានរំពឹងថានឹងនៅតែរឹងមាំនៅឆ្នាំ ២០១៨ ប៉ុន្តែនឹងថមថយបន្ទាប់ពីពេលនោះ ដោយសារតែការវិនិយោគសកលនឹងធ្លាក់ចុះ។ សរុបមក ការកើនឡើងនៃពាណិជ្ជកម្មទំនិញ និងសេវាកម្មសកលត្រូវបានគេរំពឹងថានឹងថយចុះពី ៤,៨ ភាគរយនៅឆ្នាំ ២០១៧ ដល់ ៤,៣ ភាគរយនៅឆ្នាំ ២០១៨។

ស្ថានភាពហិរញ្ញវត្ថុសកលដែលនៅតែមានភាពធូរស្រាលនៅទូទាំងឆ្នាំ ២០១៧ ទំនងជារឹតបន្តឹងនៅឆ្នាំ ២០១៨ ដោយសារតែគោលនយោបាយរូបិយវត្ថុមានភាពប្រក្រតីជាបណ្តើរៗវិញនៅក្នុងប្រទេសមានសេដ្ឋកិច្ចជឿនលឿនសំខាន់ៗ។ ការរំពឹងទុកនៃអតិផរណា និងទស្សនវិស័យនៃការធ្វើឱ្យមានប្រក្រតីភាពនៃគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិកបានកើនឡើង។ អត្រាការប្រាក់សកលត្រូវបានរំពឹងថានឹងបន្តកើនឡើង ខណៈដែលអតិផរណាកើនឡើងជាបណ្តើរៗ ហើយគោលនយោបាយរូបិយវត្ថុមានប្រក្រតីភាព នៅតាមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន។ ការដកទ្រព្យសកម្មសុទ្ធពីសំណាក់ធនាគារជាតិធំៗ នឹងរួមចំណែកដាក់សម្ពាធអត្រាការប្រាក់ភាគលាភរយៈពេលវែងឲ្យកើនឡើង។ លំហូរចូលមូលធននៅតែត្រូវបានរំពឹងថានឹងបន្តមាននិរន្តរភាពក្នុងឆ្នាំ ២០១៨ ដោយសន្មតថាមានការងើបឡើងវិញនៃកំណើនទីផ្សារកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ ខណៈដែលអត្រាការប្រាក់ពិភពលោកបន្តកើនឡើងនោះ ស្ថានភាពហិរញ្ញប្បទានក្រៅស្រុកនៃទីផ្សារកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍អាចនឹងក្លាយជាបញ្ហាប្រឈមកាន់តែខ្លាំងនៅឆ្នាំ ២០១៨ និង ២០១៩។

ថ្លៃថាមពល និងថ្លៃកសិផលមួយចំនួនត្រូវបានរំពឹងថានឹងមានភាពរឹងមាំជាបង្គួរក្នុងកំឡុងពេលព្យាករ (រូប ខ ១.៣)។ ថ្លៃប្រេងឥន្ធនៈត្រូវបានរំពឹងថាជាមធ្យមស្មើនឹង ៦០ ដុល្លារអាមេរិកក្នុងមួយធុង ក្នុងឆ្នាំ ២០១៨ និង ៦០,៨ ដុល្លារអាមេរិកក្នុងមួយធុង ក្នុងឆ្នាំ ២០១៩។ ថ្លៃលោហធាតុមានស្ថិរភាពនៅត្រីមាសទីមួយនៃឆ្នាំ ២០១៨ ហើយត្រូវបានរំពឹងថានឹងមានការប្រែប្រួលតិចតួចធៀបនឹងតួលេខព្យាករដោយសារតម្រូវការរបស់ចិនថយចុះជាបណ្តើរៗ។ ថ្លៃកសិផលបានកើន ឡើងបន្តិចនៅត្រីមាសទីមួយនៃឆ្នាំ ២០១៨ បន្ទាប់ពីមានស្ថិរភាពរយៈពេលបីឆ្នាំ។ អនុបាតបរិមាណធញ្ញជាតិដែលមានធៀបនឹងបរិមាណធញ្ញជាតិសម្រាប់ការប្រើប្រាស់ ជាការវាស់វែងបរិមាណផ្គត់ផ្គង់ក្នុងពិភពលោក ធៀបនឹងនឹងតម្រូវការ នៅតែមានកម្រិតខ្ពស់សម្រាប់ធញ្ញជាតិភាគច្រើន ដែលនឹងបន្តដាក់សម្ពាធមកលើតម្លៃឲ្យធ្លាក់ចុះ។

ទោះបីហានិភ័យចំពោះទស្សនវិស័យសកលកាន់តែមានតុល្យភាពជាងមុនក៏ពិតមែន ក៏នៅតែមានហានិភ័យអវិជ្ជមាននៅឡើយ។ ចលនាទីផ្សារហិរញ្ញវត្ថុមិនប្រក្រតី ដូចជា ការរឹតបន្តឹងប្រញាប់ប្រញាល់នៃលក្ខខណ្ឌផ្តល់ហិរញ្ញប្បទានសកល ឬការកើនឡើងភ្លាមៗអំពីការប្រែប្រួលទីផ្សារហិរញ្ញវត្ថុ អាចបង្កឱ្យមានចលាចលហិរញ្ញវត្ថុ និងអាចធ្វើឱ្យធ្លាក់ពីផ្លូវកំណើន។ ផលប៉ះពាល់អវិជ្ជមាននៃការកើនឡើងនៃអត្រាការប្រាក់កម្ចីអាចមានភាពធ្ងន់ធ្ងរចំពោះទីផ្សារកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ដែលមានតម្រូវការហិរញ្ញប្បទានធំៗពីបរទេស ដែលតារាងតុល្យភាពសាជីវកម្មមានលក្ខណៈផុយស្រួយ ហើយដែលគម្លាតនិរន្តរភាពសារពើពន្ធមានទំហំធំ។ លើសពីនេះទៀត ការបង្កើនគោលនយោបាយគាំពារនិយមផ្នែកពាណិជ្ជកម្ម ឬការកើនឡើងហានិភ័យភូមិសាស្ត្រនយោបាយ ក៏អាចប៉ះពាល់ជាអវិជ្ជមានដល់ទំនុកចិត្តពាណិជ្ជកម្ម និងសកម្មភាពសេដ្ឋកិច្ចជាទូទៅផងដែរ។ ទោះបីជាផលប៉ះពាល់សរុបពីការតម្លើងពន្ធនាំចូលដែលបានប្រកាសដោយសហរដ្ឋអាមេរិក និងប្រទេសចិនកន្លងមក ហាក់ដូចជាមានកម្រិតតិចតួច ហានិភ័យនៃផលប៉ះពាល់ជាលក្ខណៈទ្រង់ទ្រាយធំនៅតែមានជាបន្ត។ ក្នុងរយៈពេលវែង ការធ្លាក់ចុះបន្ថែមទៀតចំពោះកំណើនលទ្ធផលសក្តានុពលទាំងនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន និងទាំងនៅទីផ្សារកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ នឹងធ្វើឱ្យសេដ្ឋកិច្ចពិភពលោកកាន់តែងាយរងគ្រោះទៅនឹងវិបត្តិ ហើយប៉ះពាល់ចំពោះការលើកកម្ពស់ជីវភាពរស់នៅ។

១. រៀបចំដោយ Ekaterine T. Vashakmadze, សេដ្ឋវិទូជាន់ខ្ពស់,ក្រុមធនាគារពិភពលោក

## កត្តាជំរុញសំខាន់ៗនៃកំណើន

*វិស័យកម្មន្តសាល៖* **បន្ទាប់ពីការថយចុះបន្តិចម្តងៗ ការនាំចេញវាយនភ័ណ្ឌ និងសម្លៀកបំពាក់ បានងើបឡើងវិញនៅពាក់កណ្តាលឆ្នាំ ២០១៧ ដោយមានការគាំទ្រការងើបឡើងវិញនៃតម្រូវការសកល។** នៅឆ្នាំ ២០១៧ ការនាំចេញទៅកាន់សហភាពអឺរ៉ុបបានកើនឡើង ដោយកើនពី -១.០ ភាគរយ ក្នុងខែឧសភា (ធៀបនឹងឆ្នាំមុន) ដល់ ៧,៤% នៅក្នុងខែធ្នូ (រូប ២) ។ ក្នុងអំឡុងពេលដូចគ្នា ការនាំចេញទៅសហរដ្ឋអាមេរិចបានងើបឡើងវិញ ដោយឡើងពី -៣,៥ ភាគរយ ដល់ ៣,៧ ភាគរយ។ ចំណែកនៃការនាំចេញទៅកាន់ទីផ្សារចម្បងទាំងពីរនៅតែមានចំនួន ៧០ ភាគរយនៅឆ្នាំ ២០១៧ ។

**រូប ២៖ កំណើនការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌផ្សេងៗ** (បម្រែបម្រួលភាគរយពីមួយឆ្នាំទៅមួយឆ្នាំ)




*ប្រភព៖ អាជ្ញាធរកម្ពុជា*

**នៅឆ្នាំ ២០១៧ ការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌដទៃទៀត សម្រេចបាន ៧,២ ប៊ីលានដុល្លារ មានកំណើន ៧,៧ ភាគរយ ទាបជាង ៨,៤ ភាគរយបន្តិច នៅឆ្នាំ ២០១៦**[២] ។ វិស័យកម្មន្តសាល និងសម្លៀកបំពាក់បានកែតម្រូវដើម្បីសម្របតាមការកើនឡើងនៃការប្រកួតប្រជែងដោយការបន្ថែមតម្លៃលើផលិតផលរបស់ខ្លួនតាមរយៈការបញ្ចូលការបោះពុម្ព ប៉ាក់ និងការបោកគក់ ព្រមទាំងធ្វើសមាហរណកម្មតាមខ្សែឈរតាមដែលអាចធ្វើទៅបាន។ ទោះជាមានកិច្ចប្រឹងប្រែងឈានទៅកាន់ផលិតផលដែលមានតម្លៃខ្ពស់ក្នុងឆ្នាំ ២០១៧ កំណើននៃការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌផ្សេងៗ កំពុងពឹងផ្អែកយ៉ាងច្រើនទៅលើការកើនឡើងនៃបរិមាណដែលឆ្លុះបញ្ចាំងការប្រកួតប្រជែងជាខ្លាំង (រូប ៣)។ លើទិដ្ឋភាពបរិមាណ ការនាំចេញមុខទំនិញវាយនភ័ណ្ឌ និងសម្លៀកបំពាក់ បានកើនឡើង ៦,៦% ធៀបនឹង ១២,៣ ភាគរយនៅឆ្នាំ ២០១៦។

**រូប ៣ ៖ ការរួមចំណែកចំពោះកំណើននាំចេញសំលៀកបំពាក់ និង វាយនភ័ណ្ឌផ្សេងៗទៀត** (គិតជាលានដុល្លារអាមេរិក)




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*វិស័យស្បែកជើង៖* **ការនាំចេញផលិតផលស្បែកជើងបន្តកើនឡើង ប៉ុន្តែតម្លៃជាមធ្យមបានថយចុះ។** ដោយសារកម្មវិធី “អនុគ្រោះពន្ធលើផលិតផលគ្រប់យ៉ាង លើកលែងតែអាវុធ” របស់សហភាពអឺរ៉ុប ផលិតផលស្បែកជើងបានកើនឡើង ហើយក្លាយជាទំនិញកម្មន្តសាលនាំចេញក្រៅប្រទេសនាំមុខទីពីរបន្ទាប់ពីផលិតផលសម្លៀកបំពាក់ និងវាយនភ័ណ្ឌ។ ទឹកប្រាក់នាំចេញផលិតផលស្បែកជើងសរុបមានចំនួនសរុបជិត ០,៩ ប៊ីលានដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ ២០១៧ ឬ ១៤,៤ ភាគរយ ដែលកើនឡើងបន្តិចពី ១៣,៩ ភាគរយ នៅឆ្នាំ ២០១៦។ ខុសពីសម្លៀកបំពាក់ និងវាយនភ័ណ្ឌ ទឹកប្រាក់នាំចេញស្បែកជើងបានថយចុះខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះដោយសារតែកំណើននៃការប្រកួតប្រជែងដែលធ្វើឲ្យតម្លៃថយចុះទៅ ៦,៦ ដុល្លារក្នុងមួយគូរនៅឆ្នាំ ២០១៧ ដោយថយពីតម្លៃ ៧,០ ដុល្លារកាលពីឆ្នាំ ២០១៦ (រូប ៤)។

**រូប ៤៖ ការនាំចេញស្បែកជើងបន្តកើនឡើង តែតម្លៃជាមធ្យមកំពុងធ្លាក់ចុះ**




*ប្រភព៖ អាជ្ញាធរកម្ពុជា*
*សម្គាល់៖* RHS ខាងស្តាំ

*វិស័យកម្មន្តសាលមិនមែនវាយនភ័ណ្ឌ និងមិនមែនសម្លៀកបំពាក់។* **ការនាំចេញកង់មានទំហំធំជាងគេលំដាប់ទីបី បន្ទាប់ពីការនាំចេញផលិតផលកម្មន្តសាល និងការនាំចេញស្បែកជើង។** ការនាំចេញកង់បានកើនដល់ ៣៩៥ លានដុល្លារក្នុងឆ្នាំ ២០១៧។ លើសពីនេះទៀត មានក្រុមហ៊ុនផលិតដែលទើបកើតឡើងថ្មីៗដែលផលិតផលិតផលមានតម្លៃបន្ថែមខ្ពស់ (ភាគច្រើនជាការវិនិយោគទុនផ្ទាល់ពីបរទេស) ពិសេសចំពោះគ្រឿង និងបរិក្ខាអគ្គិសនី និងគ្រឿងបន្លាស់រថយន្ត។ ការនាំចេញគ្រឿងអគ្គិសនី និងបន្លាស់រថយន្ត មានចំនួនសរុប ៤៣០ លានដុល្លារនៅក្នុងឆ្នាំ ២០១៧។ ដោយមានការពង្រឹងទំនាក់ទំនងកាន់តែខ្លាំងរវាងសេដ្ឋកិច្ចកម្ពុជា

២ អត្ថបទស្តីពីសម្លៀកបំពាក់ និងគ្រឿងបន្ថែម ជាប្រភេទតម្បាញ និងប៉ាក់ខិន (ប្រព័ន្ធចំណាត់ថ្នាក់ទំនិញ, លេខកូដ ៦១), និងអត្ថបទស្តីពីសម្លៀកបំពាក់ និងគ្រឿងបន្ថែម មិនមែនប្រភេទតម្បាញ និងប៉ាក់ខិន (លេខកូដ ៦២)

និងខ្សែសង្វាក់តម្លៃក្នុងតំបន់ គ្រឿងអគ្គិសនី និងគ្រឿងបន្លាស់រថយន្តដែលផលិតនៅប្រទេសកម្ពុជាជាទំនិញពាក់កណ្តាលសម្រេច ត្រូវបាននាំចេញទៅកែច្នៃបន្ត ឬតម្លើងនៅទីកន្លែងដទៃ។ នៅពេលដែលការធ្វើសមាហរណកម្មកាន់តែមានលក្ខណៈស៊ីជម្រៅ ប្រទេសកម្ពុជាអាចមានលទ្ធភាពឈានឡើង ផ្នែកខាងលើនៃខ្សែសង្វាក់ផលិតកម្ម។ រោងចក្រនានាត្រូវបានបង្កើតឡើងដើម្បីទាញយកផលប្រយោជន៍ពីការចូលទីផ្សារសហរដ្ឋអាមេរិកដែលមិនគិតថ្លៃពន្ធចំពោះទំនិញធ្វើដំណើរ[៣]។

*កំណើនក្នុងវិស័យសំណង់ ដែលជាក***តត្តាជំរុញកំណើនដ៏សំខាន់ និងជាកត្តារួមចំណែកក្នុងការបង្កើតការងារ បានថមថយ។** ដូចបានបង្ហាញនៅក្នុងរូប ១ ការប៉ាន់ស្មានបឋមដោយអាជ្ញាធរកម្ពុជាបានបង្ហាញថា ក្នុងឆ្នាំ ២០១៧ ការរួមចំណែកនៃវិស័យសំណង់ និងអចលនទ្រព្យចំពោះកំណើនផលិតផលក្នុងស្រុកសរុប បានរួមតូចបន្តិច។ នេះឆ្លុះបញ្ចាំងពីភាពមិនស៊ីសង្វាក់គ្នារវាងតម្រូវការវិនិយោគ ដែលមានភាពសុទិដ្ឋិនិយម និងការថមថយនូវសកម្មភាពសំណង់ដោយសារតែតម្លៃ (និងចំនួន) នៃគម្រោងសាងសង់ដែលបានអនុម័ត បានកើនឡើងបន្ថែមទៀត ដោយកើនឡើង ២២ ភាគរយនៅឆ្នាំ ២០១៧។ ប៉ុន្តែ សូចនាករជាច្រើនបានបង្ហាញពីកម្រិតថយចុះក្នុងវិស័យសំណង់ និងអចលនទ្រព្យ។ គួរកត់សំគាល់ថា កំណើននៃការនាំចូលដែកសសៃ និងសម្ភារសាងសង់សំខាន់ៗផ្សេងទៀតបានថយចុះ ឬប្រែជាអវិជ្ជមាននៅឆ្នាំ ២០១៧ (រូប ៥)។

**កំណើនឥណទានក្នុងស្រុកផ្តល់ឲ្យវិស័យសំណង់ និងអចលទ្រព្យ ដែលបានថយចុះចាប់ពីឆ្នាំ ២០១៦ រហូតដល់ពាក់កណ្តាលឆ្នាំ ២០១៧ បានងើបឡើងវិញជាថ្មី** (រូប ៦)។ បរិមាណឥណទានក្នុងស្រុកដែលផ្តល់ដោយវិស័យធនាគារទៅកាន់វិស័យសំណង់ និងអចលនទ្រព្យ បានកើនឡើងពី ២៨,៤ ភាគរយនៅក្នុងខែឧសភាឆ្នាំ ២០១៧ ដល់ ៣៦,៣ ភាគរយនៅចុងឆ្នាំ ២០១៧។ អត្រាកំណើននៅចុងឆ្នាំ ២០១៧ បានត្រលប់ស្មើនឹង ៣៦ ភាគរយ ដែលជាកំណើនមធ្យមក្នុងរយៈពេល ៤ ឆ្នាំមុន។ ស្ថានភាពនេះ ឆ្លុះបញ្ចាំងមួយផ្នែកពីតម្រូវការដែលជំរុញដោយគម្រោងអភិវឌ្ឍន៍ថ្មីៗ ប៉ុន្តែមានទំហំតូចៗ ដូចជាគម្រោងលំនៅដ្ឋានដែលមានតម្លៃថោក[៤]។ ស្ថានភាពនេះកើតឡើងបន្តពីគម្រោងលំនៅដ្ឋានដីធ្លី និងគម្រោងលំនៅដ្ឋានខ្ពស់ៗ និងគម្រោងសំណង់ពាណិជ្ជកម្មជាបន្តបន្ទាប់ស្ថិតនៅទីតាំងល្អៗនៅតំបន់ទីប្រជុំជន។ លើសពីនេះទៀត មានកំសួលថ្មីនៃការទិញដីដែលជំរុញដោយកំណើនវិនិយោគផ្ទាល់ពីបរទេសលើវិស័យហេដ្ឋារចនាសម្ព័ន្ធ។

**រូប ៥៖ ការនាំចូលសម្ភារៈសំណង់ និងដែកថែប**
(ធៀបនឹងឆ្នាំមុន បម្រែបម្រួលគិតជាភាគរយ)




*ប្រភព៖* អាជ្ញាធរកម្ពុជា

**រូប ៦៖ បរិមាណឥណទានក្នុងស្រុកដែលផ្តល់ទៅវិស័យ សាងសង់ អចលនទ្រព្យ និងការបញ្ចាំ**
(ធៀបនឹងឆ្នាំមុន បម្រែបម្រួលគិតជាភាគរយ)




*ប្រភព៖* អាជ្ញាធរកម្ពុជា

---

៣ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ការិយាល័យតំណាងពាណិជ្ជកម្មអាមេរិកបានប្រកាសពីការពង្រីកសំខាន់នៃប្រព័ន្ធអនុគ្រោះពន្ធដែលនឹងនាំយកអត្ថប្រយោជន៍ជាច្រើនដល់កម្ពុជា។ ក្រោមការផ្លាស់ប្តូរថ្មីៗលើប្រព័ន្ធអនុគ្រោះទូទៅនៃសហរដ្ឋអាមេរិក ប្រទេសកម្ពុជា និងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចផ្សេងទៀត ក៏ដូចជាបណ្តារប្រទេសស្ថិតក្នុងច្បាប់ឱកាសពាណិជ្ជកម្ម និងច្បាប់ដើម្បីអភិវឌ្ឍន៍អាហ្វ្រិក ធ្វើការផលិតផលិតផលធ្វើដំណើរដូចជា កាបូបតវ៉ាន់ កាបូបស្ពាយ កាបូបដៃ និងកាបូបលុយ ដែលអាចនាំចេញផលិតផលទាំងនោះទៅសហរដ្ឋអាមេរិកដោយមិនគិតពន្ធ។ ប្រភព៖ https://kh.usembassy.gov/duty-free-access-travel-goods-made-cambodia/។

៤ សូមអាន https://www.realestate.com.kh/news/Demand-for-Affordable-Residential-Housing-Expected-to-Continue-Throughout-2-0-1-8/.

**ការគ្មានទំនាក់ទំនងគ្នា រវាងការថយចុះនៃសកម្មភាពសាងសង់ និងចំណាប់អារម្មណ៍វិនិយោគ ជាមួយនឹងការកើនឡើងនៃឥណទានក្នុងស្រុក ទៅកាន់វិស័យ សំណង់ និងអចលនទ្រព្យ និងវិស័យបញ្ចាំ គឺជាមូលហេតុមួយនាំឱ្យមានការព្រួយបារម្ភ។** ការកើនឡើងនៃភាពងាយរងគ្រោះពីសកម្មភាពទិញទុកដើម្បីលក់យកចំណេញអាចកើតមានឡើង។ លើសពីនេះទៀត លំហូរវិនិយោគផ្ទាល់ពីបរទេសចូលក្នុងវិស័យនេះបានថយចុះក្នុងឆ្នាំ ២០១៧[៥]។

*សកម្មភាពសំណង់ក្នុងស្រុកកំពុងរីកដុះដាល* ហួសពីតំបន់ទីក្រុងធំៗ ដូចជា រាជធានីនៃរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តសៀមរាបជាដើម។ សកម្មភាពសាងសង់កំពុងកើតឡើងនៅតាមបណ្តាខេត្តជាប់សមុទ្រសំខាន់ៗ ដូចជា ខេត្តព្រះសីហនុ និងខេត្តកោះកុង ក៏ដូចជានៅតាមខេត្តជាប់ព្រំដែននៃប្រទេសថៃ និងប្រទេសវៀតណាម ដូចជាខេត្តបន្ទាយមានជ័យ និងស្វាយរៀង ជាដើម។

**អត្រាសំណង់ និងអចលនទ្រព្យនៅក្នុងឥណទានក្នុងស្រុកសរុបបានកើនឡើងពី ២២% ក្នុងឆ្នាំ ២០១៦ ដល់ ២៦% នៅក្នុងឆ្នាំ ២០១៧** (សូមមើលផ្នែករូបិយវត្ថុខាងក្រោយសម្រាប់ព័ត៌មានលម្អិត)។ ភាគរយបច្ចុប្បន្នមានកម្រិតខ្ពស់ជាង ២៣ ភាគរយដែលជាកម្រិតខ្ពស់បំផុតយ៉ាងច្រើនក្នុងឆ្នាំ ២០០៩ នៅពេលដែលវិបត្តិហិរញ្ញវត្ថុពិភពលោកបានធ្វើឲ្យពពុះសំណង់ផ្ទុះបែក។

**ការទិញផ្ទះតម្លៃទាប និងដីឡូត៍តូចៗត្រូវបានរៀបចំដោយក្រុមហ៊ុនអភិវឌ្ឍអចលនទ្រព្យសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប។** ការផ្លាស់ប្តូរឆ្ពោះទៅរកការវិនិយោគបន្ថែមលើផ្ទះសម្បែង និងដីឡូត៍តូចៗដែលមានតម្លៃថោក ដើម្បីបម្រើដល់ផ្នែកទីផ្សារដែលមានតម្លៃទាបនៅជាយក្រុងភ្នំពេញ និងនៅតំបន់អភិវឌ្ឍន៍ថ្មីៗ។ ផ្នែកនេះនៃទីផ្សាររហូតមកដល់ពេលនេះពុំមែនជាការផ្តោតអារម្មណ៍របស់ក្រុមហ៊ុនអភិវឌ្ឍន៍ជាច្រើននោះទេ។ ប៉ុន្តែ ខណៈដែលគម្រោងធំៗមានច្រើនធ្វើឱ្យទីផ្សារមានសភាពឆ្អែត (លក់លែងមិនសូវដាច់ដូចមុន)ជាបណ្តើរៗការប្រកួតប្រជែងមានលក្ខណៈកាន់តែខ្លាំងឡើងចំពោះអចលនទ្រព្យតម្លៃទាប ជាមួយនឹងការបញ្ចុះតម្លៃយ៉ាងច្រើន និងការកាត់បន្ថយប្រាក់កក់សម្រាប់ការទិញអចលនទ្រព្យថ្មីៗដើម្បីកុំឲ្យតម្រូវការធ្លាក់ចុះ។

*វិស័យទេសចរណ៍* - **ការងើបឡើងវិញនៃវិស័យទេសចរណ៍ដែលបានចាប់ផ្តើមកាលពីដើមឆ្នាំមុននៅតែបន្តកើនឡើង។** ភាគច្រើនគឺការមកដល់នៃភ្ញៀវទេសចរមកពីប្រទេសចិន កំណើននៃការមកដល់សរុបសម្រាប់ឆ្នាំ ២០១៧ បានកើនឡើង ពី ៥,០% នៅក្នុងឆ្នាំ ២០១៦ ដល់ ១១,៨ % ឬស្មើ ៥,៦ លាននាក់ (រូប ៧)។ គួរបញ្ជាក់ផងដែរថា ការមកដល់នៃអ្នកទេសចរតាមផ្លូវអាកាសបានកើនឡើងគួរឱ្យកត់សម្គាល់ គឺ កើនឡើង ២២,៥ ភាគរយ ដែលជាកម្រិតកំណើនខ្ពស់បំផុតក្នុងមួយទសវត្សរ៍ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរដើម្បីពង្រីក និងពង្រឹងការភ្ជាប់ការហោះហើរក្នុងតំបន់ ជាពិសេសរវាងកម្ពុជា និងចិន។ ការតភ្ជាប់ជើងគោករួមគ្នាជាមួយយុទ្ធនាការស្អាត និងបៃតង កំពុងដំណើរការដើម្បីទាក់ទាញបន្ថែមទៀត និងធ្វើពិពិធកម្មគោលដៅទេសចរណ៍លើសពីប្រាសាទអង្គរវត្ត។

**រូប ៧៖ ភ្ញៀវទេសចរមកកាន់ប្រទេសកម្ពុជាមានភាពល្អប្រសើរ ប៉ុន្តែនៅទាបជាងប្រទេសជិតខាងវៀតណាម**
(ធៀបនឹងឆ្នាំមុន បម្រែបម្រួលគិតជាភាគរយ)




*ប្រភព៖* អាជ្ញាធរ កម្ពុជា និងវៀតណាម

៥ គម្រោងវិនិយោគផ្ទាល់ពីបរទេស(ក្នុងទ្រព្យសកម្មថេរ) ដែលត្រូវបានអនុម័តឲ្យវិនិយោគលើវិស័យសាងសង់និងវិស័យអចលនទ្រព្យបានធ្លាក់ចុះពី ៧០០លានដុល្លារនៅក្នុងឆ្នាំ ២០១៦ ទៅ ១៥០លានដុល្លារក្នុងឆ្នាំ ២០១៧។

**មួយចំណែកអមដោយការដាក់ឲ្យដំណើរការគម្រោងផ្តួចផ្តើម “ចិនត្រៀមខ្លួនជាស្រេច” សព្វថ្ងៃនេះ ភ្ញៀវទេសចរចិនមកពីប្រទេសចិនមានចំនួនច្រើនជាងភ្ញៀវទេសចរមកពីប្រទេសវៀតណាម ដែលធ្វើឲ្យភ្ញៀវទេសចរចិនស្ថិតក្នុងក្រុមលេខរៀងទីមួយ ក្នុងការធ្វើទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា**[៦] ។ ភ្ញៀវទេសចរចិនមានចំនួនជាង ១,២ លាននាក់ ឬ ២១,៦ ភាគរយ នៃចំនួនភ្ញៀវទេសចរសរុបក្នុងឆ្នាំ ២០១៧ ឬកើនឡើង ៤៦ ភាគរយ។ ប្រសិនបើភ្ញៀវទេសចរចិនបន្តមានកំណើនខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ផែនការរបស់អាជ្ញាធរក្នុងការទទួលបានភ្ញៀវទេសចរចិន ២ លាននាក់នៅត្រឹមឆ្នាំ ២០២០ គឺអាចធ្វើទៅបាន។ ប្រទេសវៀតណាម ឡាវ ថៃ និងសាធារណរដ្ឋកូរ៉េ នៅតែជាប្រទេសប្រភពចម្បងនៃភ្ញៀវអន្តរជាតិបន្ទាប់ពីប្រទេសចិន មានភ្ញៀវទេសចរចំនួន ១៤,៩ ភាគរយ ៩.០ ភាគរយ ៧ ភាគរយ និង ៦,២ ភាគរយតាមលំដាប់លំដោយ ដៀងគ្នានៃចំនួនភ្ញៀវសរុប។ បីភាគបួននៃជនបរទេសមកធ្វើទស្សនកិច្ចនៅកម្ពុជាមកពីតំបន់អាស៊ី និងប៉ាស៊ីហ្វិក ខណៈដែលមានតែ ១៥ ភាគរយប៉ុណ្ណោះមកពីអឺរ៉ុប។

**ការមកដល់ខេត្តសៀមរាបដែលជាទីតាំងប្រាសាទអង្គរវត្តស្ថិតនៅមានចំនួនជិត ៦០ ភាគរយនៃការមកដល់នៃជើងហោះហើរអន្តរជាតិសរុបតាមអាកាស។** ដោយសារថ្លៃសំបុត្រចូល និងចំនួនភ្ញៀវទេសចរណ៏កើនឡើង ប្រាក់ចំណូលដែលប្រមូលបានពីភ្ញៀវទេសចរ ដែលមកទស្សនាប្រាសាទ បានកើនឡើងយ៉ាងខ្លាំង។ ប្រាក់ចំណូលដែលទទួលបានពីការចូលទស្សនាប្រាសាទអង្គរវត្ត បានកើនឡើងដល់ជាង ១០០ លានដុល្លារនៅឆ្នាំ ២០១៧ កើនឡើងប្រហែល ៧០ ភាគរយលើសឆ្នាំ ២០១៦។ ទោះជាយ៉ាងណាក៏ដោយ សក្តានុពលទេសចរណ៍នៅតែមិនត្រូវបានគេយកមកប្រើប្រាស់អស់លទ្ធភាពនៅឡើយទេ។ ត្រូវធ្វើពិពិធកម្មគោលដៅទេសចរណ៍ដោយផ្តោតលើអេកូទេសចរណ៍ ភាគច្រើននៅភាគខាងជើង និងភាគឦសាននៃប្រទេស ដោយមានការដាក់ឲ្យដំណើរការឧទ្យានផ្សងព្រេងសត្វព្រៃ និងសកម្មភាពដើរកំសាន្តថ្មើរជើងនានា (សូមមើលការវិភាគលម្អិតអំពីវិស័យទេសចរណ៍កម្ពុជាក្នុងឯកសារបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានៅខែតុលាឆ្នាំ ២០១៧) ។

**ចំណែកភាគរយនៃចំនួនភ្ញៀវទេសចររួមគ្នាមកកាន់ប្រទេសទាំងបី (កម្ពុជា ថៃ និង វៀតណាម) បានធ្លាក់ចុះ ហើយសក្តានុពលនេះនៅមិនទាន់ត្រូវបានប្រើប្រាស់នៅឡើយ។** ប្រទេសជិតខាងកម្ពុជា ប្រទេសថៃ និងវៀតណាម រួមបញ្ចូលគ្នាបានទាក់ទាញភ្ញៀវទេសចរជិត ៥០ លាននាក់ក្នុងឆ្នាំ ២០១៧ ឬកើនឡើង ១១,៣ ភាគរយ ធៀបនឹងឆ្នាំ ២០១៦ ខណៈពេលដែលចំនួនអ្នកទេសចរសរុបរបស់កម្ពុជាមានចំនួនត្រឹមតែ ៥,៦ លាននាក់ប៉ុណ្ណោះ។ បើប្រៀបធៀបទៅនឹងទីផ្សាររួម មានភ្ញៀវទេសចរចំនួន ៥៤ លាននាក់កំពុងទស្សនាទាំងបី កម្ពុជា ថៃ និងវៀតណាម ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិមកកាន់ប្រទេសកម្ពុជាមានចំនួនត្រឹមតែ ១០ ភាគរយ ហើយចំណែកភាគរយនេះមាននិន្នាការធ្លាក់ចុះ (រូប ៨) ។ ក្នុងឆ្នាំ ២០១៧ ប្រទេសជិតខាងរបស់ប្រទេសកម្ពុជា គឺ វៀតណាមមានកំណើនភ្ញៀវទេសចរបំបែកកំណត់ត្រានៃវិស័យទេសចរដោយសារតែភ្ញៀវទេសចរបរទេសបានកើនឡើង ២៩% ធៀបនឹងឆ្នាំមុន ឡើងដល់កម្រិតខ្ពស់បំផុតគឺ ១២,៩ លាននាក់ (សូមមើលប្រអប់ ២ ស្តីពីទេសចរណ៍វៀតណាម - សក្តានុពលមិនទាន់បានទាញផល)។ គោលនយោបាយមួយក្នុងចំណោមគោលនយោបាយផ្សេងទៀតដើម្បីទាញប្រយោជន៍ពីទីផ្សារដែលកំពុងរីកចម្រើននេះ អាចទាក់ទងទៅនឹងការពិនិត្យមើលទៅលើតម្រូវការរបស់ទេសចរណ៍ដែលមិនត្រូវបានផ្តល់ដោយថៃ និងវៀតណាម។ បន្ទាប់មក ប្រទេសកម្ពុជាអាចបង្កើតយុទ្ធសាស្ត្រដើម្បីបំពេញតាមតម្រូវការផ្នែកទាំងនោះ។ ផ្នែកទីផ្សារសក្តានុពលអាចរួមមាន ទេសចរណ៍ធម្មជាតិ ជាពិសេសគឺឧទ្យានផ្សងព្រេងសត្វព្រៃ និងការដើរកំសាន្តថ្មើរជើង ដោយសារកម្ពុជាមានផ្ទៃដីធំទូលាយដែលគ្របដណ្តប់ដោយឧទ្យានជាតិ និងតំបន់បម្រុងទុកដែលមានជីវចម្រុះច្រើន។

៦ ឯកសារពណ៌សស្តីពីការត្រៀមខ្លួនសម្រាប់ទេសចរណ៍ចិននៅកម្ពុជា (ឆ្នាំ ២០១៥) ចេញដោយក្រសួងទេសចរណ៍។ កិច្ចផ្តួចផ្តើមនៃការត្រៀមខ្លួនជាស្រេចសម្រាប់ទេសចរចិនបង្ហាញពីកិច្ចប្រឹងប្រែងរបស់ប្រទេសកម្ពុជាដើម្បីទាញយកប្រយោជន៍ពីកំណើនឆាប់រហ័សរបស់ទេសចរណ៏ចិនចូលមក។ កិច្ចផ្តួចផ្តើមនេះផ្តល់ផ្លាកសញ្ញាជាភាសាចិន សម្រួលឯកសារសម្រាប់ដំណើរការទិដ្ឋាការ លើកតម្កើងការប្រើប្រាស់ប្រាក់យន់ចិននៅក្នុងតំបន់ ជំរុញការប្រើប្រាស់ភាសាចិន និងធានាថា អាហារ និងកន្លែងស្នាក់នៅ សមស្របទៅនឹងចំណង់ចំណូលចិត្តរបស់ចិន។ ការផ្តួចផ្តើមរយៈពេលប្រាំឆ្នាំនេះមានគោលដៅទាក់ទាញភ្ញៀវទេសចរចិន ២ លាននាក់ក្នុងមួយឆ្នាំនៅឆ្នាំ ២០២០។

**រូប ៨៖ ចំណែករបស់កម្ពុជាក្នុងចំនួនភ្ញៀវទេសចរសរុបបីប្រទេស (ប្រទេសកម្ពុជា ថៃ និងវៀតណាម)** (ភាគរយ មធ្យមភាគ៣ខែ)



*ប្រភព៖* អាជ្ញាធរកម្ពុជា ថៃ និងវៀតណាម។
*ចំណាំ៖* 3mma=មធ្យមភាគក្នុងរយៈពេល៣ខែ

*វិស័យកសិកម្ម* - **វិស័យកសិកម្មនៅតែជាប្រភពដ៏សំខាន់នៃកំណើន និងការងារសម្រាប់សេដ្ឋកិច្ច។** ការរួមចំណែករបស់វិស័យនេះចំពោះកំណើនផលិតផលក្នុងស្រុកសរុប បានងើបឡើងវិញមួយផ្នែកដោយសារតែស្ថានភាពអាកាសធាតុមានភាពប្រសើរឡើងក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។ វិស័យកសិកម្មបានរីកចម្រើនបន្តទៀតជាពិសេសផលិតកម្មស្រូវ។ ផលិតកម្មស្រូវវស្សាបានកើនឡើង ៥,៤% នៅឆ្នាំ ២០១៧ (រូប ៩) មានកំណើនទាបជាង ៦,៥ % បន្តិច ក្នុងឆ្នាំ ២០១៦ ដល់ ៨,០៥ លានតោន[៧]។ ផលិតកម្មសរុបត្រូវបានប៉ាន់ស្មានថាមានចំនួន ១០,៤ លានតោន ឬកើនឡើង ៤,៤% ក្នុងឆ្នាំ ២០១៧ ។

**រូប ៩៖ ការរួមចំណែកចំពោះកំណើន ទិន្នផលស្រូវវស្សារាល់ឆ្នាំ** (គិតជាភាគរយ)




*ប្រភព៖* អាជ្ញាធរកម្ពុជា

៧ របាយការណ៍ប្រចាំខែមករា២០១៨ ស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ ២០១៨។

## ប្រអប់ ២ ៖ ទេសចរណ៍វៀតណាម - សក្តានុពលមិនទាន់បានទាញផល[៩]

នាពេលថ្មីៗនេះ ប្រទេសវៀតណាមបានខិតខំប្រឹងប្រែងយ៉ាងច្រើន ដើម្បីលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ កែលម្អគុណភាពសេវាកម្មទេសចរណ៍ បង្កើនធនធានមនុស្ស និងសម្រួលនីតិវិធីទិដ្ឋាការសម្រាប់ភ្ញៀវទេសចរបរទេស។ ប្រទេសនេះបានដាក់ផែនការទទួលបានភ្ញៀវទេសចរបរទេសចំនួន ១៩ លាននាក់ក្នុងឆ្នាំ ២០២០ ។

កំឡុងឆ្នាំ ២០០៦ ដល់ ២០១៦ ការមកដល់នៃភ្ញៀវបរទេសទៅកាន់ប្រទេសវៀតណាមបានកើនឡើងជាមធ្យម ១១% ជារៀងរាល់ឆ្នាំ។ ឆ្នាំ ២០១៧ គឺជាឆ្នាំបំបែកឯតទគ្គកម្មមួយទៀតសម្រាប់វិស័យទេសចរណ៍ ដោយសារតែភ្ញៀវទេសចរបរទេសមកកាន់ប្រទេសវៀតណាមបានកើនឡើង ២៩ ភាគរយលើសពីឆ្នាំមុនៗ ដែលឈានដល់កម្រិតខ្ពស់បំផុត គឺ ១២,៩ លាននាក់ (រូប ខ ២.១)។ ប្រទេសនេះបានក្លាយទៅជា "ទិសដៅទេសចរណ៍កំពូលរបស់ពិភពលោក" ដោយយោងទៅតាមតំបន់ទេសចរណ៍ និងកាសែតល្បីល្បាញ។

**រូបភាព ខ២.១៖ ការមកដល់នៃភ្ញៀវទេសចរបរទេស** (លាននាក់)



*ប្រភព៖* ការិយាល័យស្ថិតិទូទៅរបស់វៀតណាម

ភាពជាគជ័យនេះសម្រេចបានបន្ទាប់ពីរដ្ឋាភិបាលវៀតណាមបានចេញកម្មវិធីសកម្មភាពមួយស្តីពីការអភិវឌ្ឍវិស័យទេសចរណ៍ឲ្យទៅជាវិស័យឈានមុខរបស់សេដ្ឋកិច្ច។ កម្មវិធីសកម្មភាពគឺជាកំណែទម្រង់ដ៏ទូលំទូលាយ។ សកម្មភាពនេះគឺសំដៅទៅបង្កើត និងបញ្ចប់ឯកសារមួយចំនួន ដូចជា ឯកសារណែនាំពីការអនុវត្តច្បាប់ទេសចរណ៍ឆ្នាំ ២០១៧ ការដាក់ចេញនូវគោលនយោបាយអនុគ្រោះដែលលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យទេសចរណ៍ ឯកសារកំណត់អទិភាពដើមទុនក្នុងការអភិវឌ្ឍធនធានមនុស្ស និងលើកកម្ពស់ការងារវិស័យទេសចរណ៍។ កម្មវិធី សកម្មភាពនេះក៏ពិនិត្យឡើងវិញ កែប្រែ និងបំពេញបន្ថែមច្បាប់ស្តីពីការចូល ការចេញ ការឆ្លងកាត់ និងទីលំនៅដ្ឋានរបស់ជនបរទេសនៅវៀតណាម ក៏ដូចជា ច្បាប់វិនិយោគទុនឆ្នាំ ២០១៤ និងបទបញ្ញាច្បាប់ពាក់ព័ន្ធផ្សេងទៀត។

កម្មវិធីសកម្មភាពបានកំណត់គោលដៅជាក់លាក់មួយចំនួនក្នុងការកែលម្អវិធីសាស្ត្រ និងខ្លឹមសារ ព្រមទាំងធានានូវការអនុវត្តសកម្មភាពលើកកម្ពស់វិស័យទេសចរណ៍ឲ្យមានសង្គតភាព វិជ្ជាជីវៈ និងប្រសិទ្ធភាពទាំងក្នុង និងក្រៅប្រទេស។ គោលបំណងជាក់លាក់មួយទៀតគឺដើម្បីអនុវត្តបច្ចេកវិទ្យាថ្មីៗក្នុងការលើកកម្ពស់វិស័យទេសចរណ៍ និងដើម្បីបង្កើតម៉ាក (Brand) សំគាល់ទេសចរណ៍ជាតិដែលភ្ជាប់ជាមួយរូបភាពកម្រៗមួយចំនួនដែលជាអត្តសញ្ញាណវប្បធម៌ជាតិ។

ថ្លៃអង្ករបានងើបឡើងវិញជាបណ្តើរៗ (រូប ១០) ។ កាលពីពេលថ្មីៗនេះ អាជ្ញាធរបានដាក់ចេញនូវគំនិតផ្តួចផ្តើមមួយចំនួនដើម្បីជួយលើកកម្ពស់ភាពប្រកួតប្រជែងនៃវិស័យស្រូវអង្ករ ដើម្បីកាត់បន្ថយភាពខុសគ្នាយ៉ាងច្រើនរវាងតម្លៃកសិផលក្រោយពេលប្រមូលផលដែលទាប និងតម្លៃលក់រាយផលិតផលកសិកម្មដែលខ្ពស់។ ដើម្បីផ្តល់អត្ថប្រយោជន៍ដល់កសិករក្នុងស្រុកកាន់តែច្រើន ផែនការមួយចំនួនបានបង្កើតឡើងសំដៅលើកកម្ពស់លទ្ធភាពរបស់កសិករក្នុងការចូលទៅកាន់ទីផ្សារ និងសំដៅកាត់បន្ថយថ្លៃដឹកជញ្ជូន និងទុកដាក់ (និងថ្លៃនាំចេញ)។ ការទទួលបានប្រាក់កម្ចីដែលមានការប្រាក់ទាបក្នុងវិស័យស្រូវអង្ករ រួមទាំង ការវិនិយោគក្នុងការសាងសង់ឃ្លាំងស្តុកស្រូវអង្ករ និងកន្លែងសម្ងួត កំពុងត្រូវបានកែលម្អ និងពង្រីក[៨]។

### រូប ១០៖ តម្លៃស្រូវអង្ករមានភាពប្រសើរឡើងវិញជាលំដាប់




*ប្រភព៖* ធនាគារពិភពលោក
*សម្គាល់៖* RHS ខាងស្តាំ

**ផលិតកម្មកៅស៊ូក៏បានពង្រីកផងដែរនៅពេលថ្លៃកៅស៊ូបានឡើងបន្តិចក្នុងឆ្នាំ ២០១៧** (រូប ១១) ។ ខណៈដែលការដាំដុះកៅស៊ូបានកើនឡើងត្រឹមតែ ១,២% ផលិតផលកៅស៊ូបានឡើងដល់ ១៩៣,០០០ តោន ឬកើនឡើង ៣៣% នៅក្នុងឆ្នាំ ២០១៧។ ដោយឆ្លុះបញ្ចាំងពីភាពធន់របស់វា ផលិតកម្មកៅស៊ូបានរីកចម្រើនយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះទោះជាតម្លៃកៅស៊ូបានធ្លាក់ចុះយ៉ាងគំហុកពីកម្រិតខ្ពស់បំផុតក្នុងឆ្នាំ ២០១១ ក៏ដោយ។

---

៨ ក្នុងកិច្ចខិតខំរបស់អាជ្ញាធរដើម្បីធ្វើឲ្យតម្លៃកសិផលមានតម្លៃទាប ជាពិសេសតម្លៃស្រូវ ទុនបម្រុងពិសេសមួយដែលមានអត្រាការប្រាក់ទាប ដែលមានទំហំទឹកប្រាក់ចំនួន ៥០លានដុល្លារ ត្រូវបានបង្កើតឡើង (ហើយទុនបន្ថែម១៥លានដុល្លារ និងត្រូវបានប្រើប្រាស់សម្រាប់វិនិយោគក្នុងការសាងសង់ឃ្លាំងស្តុកស្រូវ និងកន្លែងសម្ងួត)។ ទុនបម្រុងនេះត្រូវបានគៀរគរឡើងដើម្បីផ្តល់ប្រាក់កម្ចីដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវសម្រាប់ឲ្យពួកគាត់មានលទ្ធិភាពទិញស្រូវក្នុងរដូវច្រូតកាត់។

## ប្រអប់ ២ ៖ ទេសចរណ៍វៀតណាម - សក្តានុពលមិនទាន់បានទាញផល (បន្ត)

កម្មវិធីសកម្មភាពក៏មានគោលបំណងផ្តល់បរិយាកាសអំណោយផលដល់អាជីវកម្ម និងសហគមន៍ ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍តាមរយៈការបង្កើតបរិយាកាសអាជីវកម្មដែលមានសុខភាពល្អ មានតម្លាភាព និងអំណោយផល សម្រាប់សហគ្រាស បន្ថែមលើការធានាសន្តិសុខ និងសុវត្ថិភាពសម្រាប់សកម្មភាពទេសចរណ៍។ កម្មវិធីសកម្មភាពបានវិវត្តឆ្ពោះទៅកាន់ការគាំទ្រដល់ការចាប់ផ្តើមអាជីវកម្មទេសចរណ៍ ការលើកទឹកចិត្តភ្នាក់ងារទេសចរណ៍ឲ្យធ្វើពិពិធកម្មប្រភេទផលិតផល និងសេវាកម្មទេសចរណ៍នានា ការចូលរួមទេសចរណ៍ជាមួយផលិតផលវប្បធម៌ និងសិល្បៈ និងភូមិសិប្បកម្ម ការផ្តល់លទ្ធភាពឱ្យប្រជាជនចូលរួមដោយផ្ទាល់ក្នុងការអភិវឌ្ឍទេសចរណ៍ និងទទួលបានប្រយោជន៍ពីវិស័យទេសចរណ៍ ការកសាងសហគមន៍ទេសចរណ៍ដែលមានភាពរួសរាយ និងស៊ីវិល័យក្នុងការប្រាស្រ័យជាមួយភ្ញៀវទេសចរ និងការលើកកម្ពស់តួនាទីរបស់អង្គការសង្គម និងការងារនៅក្នុងការអភិវឌ្ឍវិស័យទេសចរណ៍។

យោងតាមក្រុមប្រឹក្សាធ្វើដំណើរ និងទេសចរណ៍ពិភពលោកបានឱ្យដឹងថា ការរួមចំណែកដោយផ្ទាល់ទៅលើការធ្វើដំណើរ និងទេសចរណ៍ចំពោះផលិតផលក្នុងស្រុកសរុប (GDP) មានប្រមាណ ១០,២ ប៊ីលានដុល្លារ (៤,៦ ភាគរយនៃផលិតផលក្នុងស្រុកសរុប) នៅក្នុងឆ្នាំ ២០១៧ ។ តាមរយៈការប៉ាន់ស្មានដូចគ្នា ការរួមចំណែកសរុប (ដោយផ្ទាល់ + ដោយប្រយោល) មានប្រមាណជា ២០ ប៊ីលានដុល្លារ ស្មើនឹង ៩% នៃផលិតផលក្នុងស្រុកសរុប។ វិស័យធ្វើដំណើរនិងទេសចរណ៍ ក៏បានបង្កើតការងារដោយផ្ទាល់ និងការងារដោយប្រយោលចំនួន ៣,៥ លានផងដែរ។

### រូបភាព ខ២.២៖ ការរួមចំណែកនៃការធ្វើដំណើរ និងទេសចរណ៍ចំពោះផលិតផលក្នុងស្រុកសរុប GDP (គិតជាភាគរយ)




*ប្រភព៖* ក្រុមប្រឹក្សាការធ្វើដំណើរនិងទេសចរណ៍ពិភពលោក

ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលអនុវត្តវិស័យធ្វើដំណើរ និងទេសចរណ៍របស់វៀតណាម នៅមានសក្តានុពលតិចតួចនៅឡើយ។ ប្រទេសវៀតណាមត្រូវបានចាត់ទុកថាមានកំរិតទាបក្នុងការរួមចំណែក (ដោយផ្ទាល់ និងសរុប) នៃការធ្វើដំណើរ និងទេសចរណ៍ចំពោះកំណើនសេដ្ឋកិច្ចក្នុងចំណោមបណ្តាប្រទេសជិតខាងនៅក្នុងតំបន់ (រូប ខ ២.២) ។

---

១ រៀបចំដោយលោក វៀត ទួនឌីញ សេដ្ឋវិទូជាន់ខ្ពស់ ការិយាល័យធនាគារពិភពលោកប្រចាំប្រទេសវៀតណាម

**រូប ១១៖ ទិន្នផល និងតម្លៃកៅស៊ូ មានភាពប្រសើរឡើង**




*ប្រភព៖* អាជ្ញាធរកម្ពុជា និងធនាគារពិភពលោក
*សម្គាល់៖* RHS ខាងស្តាំ SGP= សិង្ហបុរី MYS= ម៉ាឡេស៊ី

## ខ) វិស័យពាណិជ្ជកម្មក្រៅប្រទេស

**ការនាំចេញទំនិញដ៏រឹងមាំនៅតែបន្ត មានកំណើន ៩,៧ ភាគរយនៅឆ្នាំ ២០១៧ ប៉ុន្តែបានធ្លាក់ចុះបន្តិចពី ១១ ភាគរយ នៅឆ្នាំ ២០១៦។** ការកើនឡើងនៃការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌដទៃទៀតលើសការរំពឹងទុកនៅក្នុងឆមាសទីពីរ ការនាំចេញសរុបបានកើនឡើងយ៉ាងប្រសើរនៅក្នុងឆ្នាំ ២០១៧ ដោយសារមានកំណើននៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសជឿនលឿន។ ការនាំចេញទំនិញកសិកម្មសំខាន់ៗ ដូចជា ស្រូវ កៅស៊ូ និងស្ករ ក៏មានការកើនឡើងផងដែរ (រូប១២) ។

**រូប ១២៖ ការនាំចេញកសិផល ដូចជា អង្ករ និង កៅស៊ូ កំពុងកើនឡើង** (គិតក្នុងឆ្នាំនេះ លានដុល្លារ)




*ប្រភព៖* អាជ្ញាធរកម្ពុជា
*សម្គាល់៖* YTD = Year-to-date.

**តម្រូវការក្នុងស្រុកបានថយចុះដោយសារកំណើនឥណទានក្នុងស្រុកបានកើនយឺតជាងមុន ធ្វើឲ្យការនាំចូលថមថយ។** ដូចករណីនៃការធ្លាក់ចុះនៃការនាំចូលសម្ភារសំណង់ ការនាំចូលទំនិញប្រើប្រាស់ដែលមានអាយុកាលវែង ដូចជា យានយន្ត និងទំនិញដែលមានអាយុកាលប្រើប្រាស់ខ្លី ដូចជា ផលិតផលប្រេងកាតបានកើនយឺតជាងមុន នៅឆ្នាំ ២០១៧ (រូប១៣)។ ដើម្បីលើកកម្ពស់ផលិតកម្មក្នុងស្រុក និងការងារ ទន្ទឹមនឹងការកាត់បន្ថយការនាំចូលទំនិញ ការពង្រីកឧស្សាហកម្មម្ហូបអាហារ និងភេសជ្ជៈដែលកំពុងបំរើដល់វិស័យទេសចរណ៍ កំពុងកើនឡើងជាបន្តនៅក្នុងប្រទេសកម្ពុជា។

**រូប ១៣៖ ការនាំចូលទំនិញប្រើបានយូរ និងទំនិញ ដូចជា ម៉ូតូ និងប្រេងឥន្ធនៈ បានថយចុះ** (គិតក្នុងឆ្នាំនេះ, លានដុល្លារ)




*ប្រភព៖* អាជ្ញាធរកម្ពុជា

**ដោយសារការនាំចេញទំនិញដ៏រឹងមាំ និងការនាំចូលទាប ធ្វើឲ្យឱនភាពពាណិជ្ជកម្មបានរួមតូច។** ឱនភាពពាណិជ្ជកម្មត្រូវបានប៉ាន់ប្រមាណថាបានធ្លាក់ចុះដល់ ១០,៤% នៃ ផសស ក្នុងឆ្នាំ ២០១៧ ធ្លាក់ចុះពី ១១,៤% នៅក្នុងឆ្នាំ ២០១៦។ ដូចគ្នាដែរ ឱនភាពគណនីចរន្តត្រូវបានគេប៉ាន់ស្មានថាថយចុះមកស្មើ ៩,៨% នៃ ផសស ពី ១០,២% ក្នុងឆ្នាំ ២០១៦ (រូប ១៤)។ ឱនភាពនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយការកើនឡើងនៃលំហូរនៃការវិនិយោគទុនពីបរទេសដែលត្រូវបានប៉ាន់ស្មានថាស្មើនឹង ១០.៨% នៃ ផសស នៅឆ្នាំ ២០១៧ គឺដូចគ្នាទៅនឹងកម្រិតដែលបានកត់ត្រាក្នុងឆ្នាំ ២០១៦ ដែរ។

**រូប ១៤៖ ឱនភាពគណនីចរន្តដែលទទួលបានហិរញ្ញប្បទាន ដោយសារលំហូរការវិនិយោគទុនពីបរទេសមិនគ្រប់គ្រាន់**
(គិតជាភាគរយ ផសស)




*ប្រភព៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក*

**លំហូរការវិនិយោគទុនពីបរទេសបានផ្តោតលើវិស័យសេដ្ឋកិច្ចសំខាន់ៗ ប៉ុន្តែវិស័យអចលនទ្រព្យ សំណង់ និងកន្លែងស្នាក់នៅជារួម ទទួលបានចំណែកស្ទើរតែ ១ ភាគ ៣ នៃលំហូរការវិនិយោគទុនពីបរទេសសរុប។** ក្នុងឆ្នាំ ២០១៦ ការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យអចលនទ្រព្យ សកម្មភាពស្ថាបនាលំនៅដ្ឋានរួមបញ្ចូលគ្នាស្មើនឹង ៣០% នៃលំហូរការវិនិយោគទុនពីបរទេសសរុប។ វិស័យហិរញ្ញវត្ថុ (ធនាគារ) គឺជាផ្នែកបន្ទាប់ដែលទទួលបាន ២៨% នៃលំហូរការវិនិយោគទុនពីបរទេសសរុប បន្ទាប់មកផ្នែកកម្មន្តសាល (១៦,៦%) និងកសិកម្ម (១០,៣%)។ គោលនយោបាយពាណិជ្ជកម្មសេរី និងវិនិយោគរបស់ប្រទេសកម្ពុជាបន្តទាក់ទាញលំហូរវិនិយោគផ្ទាល់ពីបរទេសធំៗ ដែលជាកត្តាសំខាន់មួយនៅពីក្រោយវិស័យនាំចេញដ៏រឹងមាំរបស់ប្រទេសកម្ពុជា ហើយថ្មីៗនេះ ផ្នែកអចលនទ្រព្យ

**រូប ១៥៖ លំហូរសុទ្ធនៃវិនិយោគបរទេសផ្ទាល់**
(គិតជាភាគរយនៃចំនួនផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៦)




*ប្រភព៖ សូចនាករអភិវឌ្ឍន៍ពិភពលោក។*

និងសំណង់មានសន្ទុះរីកចម្រើន។ លំហូរវិនិយោគផ្ទាល់ពីបរទេសសុទ្ធមានទំហំធំជាងលំហូរវិនិយោគទៅបណ្តាប្រទេសក្នុងតំបន់ (រូប១៥)។

## អតិផរណា

**ការថមថយនៃការប្រើប្រាស់ឯកជនបានធ្វើឲ្យអតិផរណាធ្លាក់ចុះ។** ការថមថយនៃកំណើនឥណទានក្នុងស្រុកដែលបានកើតឡើងកាលពីឆ្នាំមុនបន្ទាប់ពីមានការដាក់ចេញអត្រាការប្រាក់អតិបរមា ១៨ ភាគរយ បានបន្តធ្វើឲ្យការប្រើប្រាស់ឯកជនធ្លាក់ចុះ។ ជាលទ្ធផលអតិផរណាបានធ្លាក់ចុះដល់ ២,២% នៅចុងឆ្នាំ ២០១៧ ធៀបនឹង ៣,៩% នៅឆ្នាំ ២០១៦ (រូប១៦)។

**រូប ១៦៖ អតិផរណាកាន់តែថយចុះ ដោយសារតម្លៃម្ហូបអាហារធ្លាក់ចុះ។** ចំណែកក្នុងអតិផរណារយៈពេល ១២ ខែ
(គិតជាភាគរយ)




*ប្រភព៖ អាជ្ញាធរកម្ពុជា*

**ការធ្លាក់ចុះនៃថ្លៃម្ហូបអាហារបន្ថែមទៀត បានរួមចំណែកធ្វើឱ្យមានអតិផរណាមានកម្រិតទាប។** នេះគឺដោយសារតែទម្ងន់ (មេគុណ) នៃទំនិញម្ហូបអាហារមានចំនួនស្ទើរតែពាក់កណ្តាលនៃទំងន់(មេគុណ) សរុបនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់របស់កម្ពុជា។ សម្ពាធដែលធ្វើឲ្យតម្លៃស្រូវ ត្រី សាច់ជ្រូក និងបន្លែ ធ្លាក់ចុះ គឺជាកត្តាមួយដែលធ្វើឲ្យសន្ទស្សន៍រងចំណីអាហារធ្លាក់ចុះ (៤៣% នៃទម្ងន់មេគុណអតិផរណាសរុប) ដែលបានធ្លាក់ចុះដល់ ១,៨% នៅចុងឆ្នាំ ២០១៧ ពី ៦.១ ភាគរយនៅឆ្នាំ ២០១៦។ ទោះជាយ៉ាងណាផ្នែកដឹកជញ្ជូនបានកើនឡើង ជាមួយនឹងការងើបឡើងវិញនៃថ្លៃប្រេងអន្តរជាតិ ដែលបានឆ្លងដល់ថ្លៃប្រេងលក់រាយក្នុងស្រុក។

សន្ទស្សន៍រងផ្សេងៗទៀតដែលតំណាងឱ្យភោជនីយដ្ឋាន ការថែទាំសុខភាព គ្រឿងសង្ហារឹម និងផ្នែកសម្លៀកបំពាក់រួមបញ្ចូលគ្នា និងដែលត្រូវបានចាត់ថ្នាក់នៅក្នុង "ផ្នែកដទៃ" នៅតែមានកម្រិតទាប។

**បើទោះជាការថយចុះនៃអតិផរណានៅឆ្នាំ ២០១៧ មួយផ្នែកបណ្ដាលមកពីកំណើននៅផ្នែកផ្គត់ផ្គង់ ដោយសារតែកំណើនផលិតកសិកម្ម វានៅតែជាករណីដែលជំរុញដោយតម្រូវការដដែល។** កំណើនយ៉ាងលឿននៃវិស័យសំណង់បានថយចុះ ហើយកំណើនឥណទានក្នុងស្រុកក៏បានថយចុះដែរ។ ការថយចុះកំណើនទាំងពីរនេះធ្វើឲ្យមានការថយចុះអតិផរណា (រូប ១៧)។ យ៉ាងណាក៏ដោយ កំណើនសម្ពាធទៅលើអតិផរណាហាក់ដូចជាបណ្ដាលមកពីកំណើនតម្លៃប្រេងសាំងឡើងវិញទេ។ អតិផរណាដោយសារតែការនាំចូលបានកើតមានឡើង ដោយសារតែ "ការផ្ទេរ" ពីតម្លៃប្រេងនាំចូលពីអន្តរជាតិដែលមានឥទ្ធិពលទៅលើអតិផរណាក្នុងស្រុក ព្រោះថាកម្ពុជាជាប្រទេសនាំចូលប្រេងសាំង។

**រូប ១៧៖ អត្រាអតិផរណាបានថយចុះ ដោយសារតម្រូវការថយចុះ ខណៈដែលកំណើនឥណទានថយចុះ**
(បម្រែបម្រួលពីមួយឆ្នាំទៅមួយឆ្នាំ គិតជាភាគរយ)




*ប្រភព៖* អាជ្ញាធរកម្ពុជា
*សម្គាល់៖* RHS ខាងស្ដាំ

**អត្រាអតិផរណាក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក នៅតែមានកម្រិតទាបនៅក្នុងប្រទេសភាគច្រើន ទោះបីជាអត្រានេះឈានទៅមានចំនួនជិតស្មើនឹងអត្រាគោលដៅក្ដី** (រូប ១៨)។ ជារួម អតិផរណាបានកើនឡើងតិចតួចចាប់ពីពាក់កណ្ដាលឆ្នាំ ២០១៧ ទោះបីជាតម្លៃប្រេងកើនឡើង បូករួមនឹងការបន្តកំណើន និងកំណើនឥណទានលឿនក្នុងប្រទេសមួយចំនួនក្ដី។ តម្លៃម្ហូបអាហារថេរក្នុងទីផ្សារអន្តរជាតិ និងកំណើនតម្លៃរូបិយប័ណ្ណក្នុងតំបន់ សុទ្ធតែបានរួមចំណែកដល់ស្ថានភាពអតិផរណានេះ។ ក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចធំៗក្នុងតំបន់ អត្រាអតិផរណាបានកើនឡើងនៅប្រទេសហ្វីលីពីន ចិន និងវៀតណាម ប៉ុន្តែប្រទេសថៃនៅតែមានអត្រាអតិផរណាទាបដដែល។ ទោះបីជាមានកំណើនឡើងវិញនៃតម្លៃទំនិញប្រើ ប្រាស់ក្ដី តាមការរំពឹងទុកអតិផរណាថ្លៃទំនិញប្រើប្រាស់នៅតែមានកម្រិតទាប ដោយសារការផ្សារភ្ជាប់ទៅនឹង អតិផរណាយ៉ាងខ្លាំងជាទូទៅ។

**រូប ១៨៖ អតិផរណានៅតែមានកម្រិតទាបក្នុងតំបន់ និងធ្លាក់ចុះក្នុងប្រទេសភាគច្រើននៅចុងឆ្នាំ ២០១៧**
(បម្រែបម្រួលធៀបនឹងឆ្នាំមុន គិតជាភាគរយ)




*ប្រភព៖* អាជ្ញាធរកម្ពុជា និងសេដ្ឋកិច្ចវិទូ

## គ) ភាពក្រីក្រ

**ការផ្លាស់ប្ដូររចនាសម្ព័ន្ធបាន និងកំពុងជួយដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។** នៅតំបន់ជនបទ ពិពិធកម្មនៃប្រភពប្រាក់ចំណូលដោយសារតែការផ្លាស់ប្ដូររចនាសម្ព័ន្ធ និងសេដ្ឋកិច្ច បានធ្វើឲ្យមានកំណើនប្រាក់ឈ្នួល និងប្រាក់បៀវត្សរ៍ ធៀបទៅនឹងប្រាក់ចំណូលរបស់បុគ្គលស្វ័យនិយោជក (សូមមើលប្រអប់ ៣ ស្ដីពីការផ្លាស់ប្ដូររចនាសម្ព័ន្ធ ៖ គោលនយោបាយ យុទ្ធសាស្ត្រ និងកំណែទម្រង់)។ នៅឆ្នាំ ២០១៥ ប្រាក់ចំណូលនៅទីជនបទប្រមាណ ៥០% ទទួលបានពីប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល ដោយចំនួននេះមានត្រឹមតែ ៣០% កាលពីមួយទសវត្សរ៍មុនប៉ុណ្ណោះ (រូប ១៩)។

## ប្រអប់ ៣ ៖ ការផ្លាស់ប្តូររចនាសម្ព័ន្ធ (គោលនយោបាយ យុទ្ធសាស្ត្រ និងកំណែទម្រង់)

ដើម្បីសម្រួលដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច គោលនយោបាយ យុទ្ធសាស្ត្រ និងកំណែទម្រង់ជាច្រើនត្រូវបានបង្កើតឡើង ប៉ុន្តែត្រូវមានការពង្រឹងបន្ថែមទៀតលើភាពពាក់ព័ន្ធ និងប្រទាក់ក្រឡាគ្នារវាងគោលនយោបាយ យុទ្ធសាស្ត្រ និងកំណែទម្រង់ទាំងនេះដើម្បីធានាឲ្យការអនុវត្តជោគជ័យ។

*គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ ៖* គោលនយោបាយសំខាន់បំផុតដែលគាំទ្រការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចគឺគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ ដែលត្រូវបានដាក់ឲ្យប្រើកាលពីខែ មីនា ឆ្នាំ ២០១៥។ គោលនយោបាយនេះដើរតួនាទីជា "យុទ្ធសាស្ត្រកំណើនថ្មី" ដែលឆ្លើយតបទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធជាបន្តបន្ទាប់ ដោយទាញប្រយោជន៍ពីទីតាំងជាយុទ្ធសាស្ត្ររបស់កម្ពុជាតាមរយៈសមាហរណកម្មសេដ្ឋកិច្ច និងឧស្សាហកម្មរបស់កម្ពុជាក្នុងតំបន់។ គោលនយោបាយនេះមានគោលបំណងធ្វើពិពិធកម្មសេដ្ឋកិច្ច (និងការនាំចេញ) តាមរយៈការទាញប្រយោជន៍ពីវិស័យឧស្សាហកម្ម ជាពិសេសឧស្សាហកម្មមិនមែនសម្លៀកបំពាក់ (និងស្បែកជើង) និងឧស្សាហកម្មកម្មន្តសាល (តារាង ខ ៣.១)។ ប៉ុន្តែ ដំណើរការឈានទៅសម្រេចបានចំណុចដៅដែលកំណត់ក្នុងគោលនយោបាយនេះមានភាពច្របូកច្របល់។ នៅឆ្នាំ ២០១៧ ចំណែកនៃការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើង ធៀបនឹងទំនិញនាំចេញសរុប មានកម្រិត ៧២% ធៀបនឹងចំណុចដៅក្រោម ៦០% ដែលធ្វើឲ្យគោលដៅនៃការសម្រេចបានការធ្វើពិពិធកម្មចេញពីវិស័យសម្លៀកបំពាក់ និងស្បែកជើង មានភាពស្រពិចស្រពិល។

**តារាង ខ ៣.១ ៖ ចំណុចដៅសំខាន់ៗក្នុងគោលនយោបាយ អភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥**

| | | | |
|---|---|---|---|
| ***ចំណែកតាមវិស័យនៅក្នុង ផសស (គិតតាមតម្លៃបច្ចុប្បន្ន)*** | | | |
| វិស័យ[១]/ | 2015 | 2020 | 2025 |
| ឧស្សាហកម្ម ដែល ៖ | 26.2% | 28% | 30% |
| កម្មន្តសាល | 16% | 18% | 20% |
| សេវា | 39.4% | 40% | 40% |
| ***ចំណែកនៃផលិតផលនាំចេញធៀបនឹងការនាំចេញសរុប*** | | | |
| វិស័យ[២]/ | 2015 | 2020 | 2025 |
| ផលិតផលកសិកម្មកែច្នៃ | 8% | 10% | 12% |
| កម្មន្តសាល ដែល ៖ | | | |
| សម្លៀកបំពាក់ និងស្បែកជើង | 60% | 55% | 50% |
| មិនមែនសម្លៀកបំពាក់ និងស្បែកជើង | 5% | 10% | 15% |

*ប្រភព៖* អាជ្ញាធរកម្ពុជា

១ វិស័យកសិកម្មគ្របដណ្តប់លើចំណែកដែលនៅសល់។

២ គ្របដណ្តប់តែលើផលិតផលនាំចេញគោលដៅ។

ដើម្បីឲ្យគោលនយោបាយនេះទទួលបានជោគជ័យ វិស័យឧស្សាហកម្មត្រូវជួយរក្សាគន្លងកំណើនខ្ពស់ ក៏ដូចជាស្រូបយកកម្លាំងពលកម្មដែលលើសក្នុងវិស័យកសិកម្ម។ ចំណុចនេះទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការលើកកម្ពស់ឧស្សាហកម្មកម្មន្តសាលថ្មីៗ (ដែលមានតម្លៃបន្ថែមខ្ពស់) ដើម្បីប៉ះប៉ូវកំណើនប្រាក់ឈ្នួលយ៉ាងលឿន។ ទន្ទឹមនឹងនេះ ចាំបាច់ត្រូវបំផុសការបង្កើតការងារនៅគ្រប់ទីកន្លែង ព្រោះ វិស័យឧស្សាហកម្មកម្មន្តសាលមិនសូវប្រើប្រាស់កម្លាំងពលកម្មឡើយ ធៀបនឹងវិស័យសម្លៀកបំពាក់។

*គោលនយោបាយជាតិសម្រាប់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ* ២០១៧-២០២៥ មានគោលបំណងគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥។ គោលនយោបាយនេះមានបំណងលុបបំបាត់ការខ្វះខាតជំនាញ (ជាបុរេលក្ខខណ្ឌមួយដែលត្រូវបានពិភាក្សាក្នុងផ្នែកខាងលើសម្រាប់ការឆ្ពោះទៅរកសង្វាក់តម្លៃដែលគាំទ្រការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការនាំចេញ ដូចមានកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម)។

ដោយសារតែកង្វះកម្លាំងពលកម្មជំនាញយ៉ាងច្រើន ក្រុមហ៊ុនផលិតដែលមានតម្លៃបន្ថែមខ្ពស់ និងទំនើប ត្រូវចំណាយពេលវេលា និងធនធានយ៉ាងច្រើនក្នុងការបណ្តុះបណ្តាលអ្នកដែលនឹងក្លាយជាកម្មករនិយោជិតរបស់ខ្លួន (មុនពេលផ្តល់ការងារដល់ពួកគេ) ដើម្បីធ្វើអាជីវកម្មជោគជ័យនៅកម្ពុជា។ បញ្ហានេះគឺដោយសារតែបរាជ័យទីផ្សារ (ឧទាហរណ៍ ចំណាយក្នុងវិស័យឯកជនលើសពីអត្ថប្រយោជន៍) ដែលក្រុមហ៊ុនមិនវិនិយោគគ្រប់គ្រាន់លើការបណ្តុះបណ្តាលកម្មករនិយោជិតរបស់ខ្លួន នៅពេលអត្រាផ្លាស់ចេញ-ចូលមានកម្រិតខ្ពស់ (សម្រាប់ព័ត៌មានលម្អិត មើលអត្ថបទជម្រើសស្តីពីការងារនាពេលអនាគតនៅកម្ពុជា)។ បញ្ហាបង្កឡើងដោយកង្វះកម្លាំងពលកម្មមានចំណេះដឹងគ្រប់គ្រាន់នៅកម្ពុជា ត្រូវបានរកឃើញថាជាឧបសគ្គធ្ងន់ធ្ងរបំផុតទីពីរសម្រាប់ប្រតិបត្តិការរបស់សហគ្រាសកម្មន្តសាល (យោងតាមការអង្កេតសហគ្រាសដោយក្រុមធនាគារពិភពលោក ២០១៦) (រូប ខ ៣.១)។ អស្ថិរភាពនយោបាយ (បញ្ហាចម្បង) និងតម្លៃអគ្គិសនី (បញ្ហាទី ៥) ក៏ជាបញ្ហាគួរឲ្យបារម្ភផងដែរ។

## ប្រអប់ ៣ ៖ ការផ្លាស់ប្តូររចនាសម្ព័ន្ធ (គោលនយោបាយ យុទ្ធសាស្ត្រ និងកំណែទម្រង់) (បន្ត)

**រូប ខ៣.១ ៖ ឧបសគ្គធំៗទាំង ១០ ក្នុងវិស័យកម្មន្តសាល**




*ប្រភព៖* ការអង្កេតសហគ្រាសដោយក្រុមធនាគារពិភពលោក

ការដោះស្រាយបញ្ហាចំណាយខ្ពស់លើមធ្យោបាយដឹកជញ្ជូន និងភ័ស្តុភារ ជាសេចក្តីត្រូវការចាំបាច់ព្រោះមានការព្យាករណ៍ថា ក្រុមហ៊ុននៅកម្ពុជានឹងចរាចរណ៍ទំនិញរបស់ខ្លួនច្រើនជាងមុនស្មើ ៤,១ ដងនៅឆ្នាំ២០៣០។ ប្រសិនបើនិន្នាការបច្ចុប្បន្ននៅតែបន្ត ការនាំចេញ (គិតតាមតម្លៃឆ្នាំ ២០១៦) នឹងកើនឡើងពី ១០,១ ប៊ីលានដុល្លារនៅឆ្នាំ ២០១៦ រហូតដល់ ៤១,៥ ប៊ីលានដុល្លារ នៅឆ្នាំ ២០៣០។ ដើម្បីសម្រួលដល់ការពង្រីកពាណិជ្ជកម្ម ការតភ្ជាប់គ្នា ដូចជា ទំនើបកម្មមធ្យោបាយដឹកជញ្ជូន និងភ័ស្តុភារ ត្រូវបានដាក់ចូលក្នុងផែនការភ័ស្តុភារថ្នាក់ជាតិ និងការបង្កើតក្រុមប្រឹក្សាភ័ស្តុភារជាតិ។ ពាក់ព័ន្ធនឹងសមត្ថភាពផ្នែកភ័ស្តុភារ កម្ពុជាជាប់លំដាប់ទី ៧៣ ក្នុងចំណោមប្រទេស ១៥៩ (យោងតាមសន្ទស្សន៍អនុវត្តន៍ភ័ស្តុភារ ២០១៦)។ ជាមធ្យម ក្រុមហ៊ុនជោគជ័យមួយចំនួនដែលនាំចេញផលិតផលអេឡិចត្រូនិក ដូចជា ក្រុមហ៊ុននៅប្រទេសថៃ និងម៉ាឡេស៊ី ជាប់លំដាប់ ២១-២៦ លើកម្ពុជា។

សម្រាប់គោលនយោបាយរូបិយវត្ថុ ដុល្លាររូបនីយកម្មខ្ពស់បានរាំងស្ទះលទ្ធភាពរបស់ធនាគារកណ្តាលក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុដោយរលូន។ លទ្ធភាពទទួលបានហិរញ្ញវត្ថុគឺជាឧបសគ្គធ្ងន់ធ្ងរបំផុតទី ៤ សម្រាប់ប្រតិបត្តិការក្រុមហ៊ុននៅកម្ពុជា (យោងតាមការអង្កេតសហគ្រាសដោយក្រុមធនាគារពិភពលោកឆ្នាំ ២០១៦)។ កម្ពុជាទើបតែសម្រេចបានកំណើនហិរញ្ញវត្ថុយ៉ាងលឿន ដែលសម្រួលដល់លទ្ធភាពទទួលបានហិរញ្ញវត្ថុកាន់តែប្រសើរ។ ប៉ុន្តែ អត្រាការប្រាក់ (ទោះធ្លាក់ចុះក្តី) ធ្វើឲ្យថ្លៃហិរញ្ញប្បទាននៅតែថ្លៃ នៅតែមានកម្រិតខ្ពស់ (សម្រាប់ព័ត៌មានលម្អិត មើលផ្នែកស្តីពីវិស័យរូបិយវត្ថុ) ដែលជាហេតុផលធ្វើឲ្យធនាគារជាតិកំណត់អត្រាការប្រាក់មិនឲ្យលើសពី ១៨% នៅខែ មេសា ឆ្នាំ ២០១៧។ ចំណុចនេះ បូករួមនឹងឧបសគ្គផ្សេងទៀត បានរាំងស្ទះដល់ការពង្រីកអាជីវកម្មខ្នាតតូច ជាពិសេសសហគ្រាសខ្នាតតូច និងមធ្យម។ សហគ្រាសទាំងនេះនៅកម្ពុជានៅតែបំពេញមុខងារមិនបានល្អប្រសើរ ទោះបីជាវិស័យនេះដើរតួនាទីដ៏សំខាន់សម្រាប់កម្ពុជាក្តី។ នៅទូទាំងពិភពលោក សហគ្រាសនេះមានចំនួនជាង ៩៥% នៃក្រុមហ៊ុនចុះបញ្ជី ផ្តល់ការងារជាង ៥០% និងរួមចំណែកជាង ៣៥% នៃ ផសស ក្នុងទីផ្សារដែលកំពុងរីកចម្រើនជាច្រើន។ អាជីវកម្មខ្នាតតូចបានបង្កើតការងារថ្មីៗភាគច្រើន និងជួយធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេស។ ចំណាយហិរញ្ញប្បទានដ៏ខ្ពស់នេះធ្វើឲ្យការវិនិយោគដែលមានផលិតភាព មិនសូវទទួលបានផ្លែផ្កា ក៏ដូចជា ជំរុញសកម្មភាពទិញទុកដើម្បីកេងចំណេញ ដូចជា ក្នុងទីផ្សារអចលនទ្រព្យ។

*ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥៖* ដើម្បីគាំទ្រកំណើនកម្លាំងពលកម្មកាន់តែច្រើនក្នុងវិស័យឧស្សាហកម្មក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ត្រូវបានអនុម័តនៅខែ មីនា ឆ្នាំ ២០១៧។ កម្មវិធីជំនួយជាបន្តបន្ទាប់ ជាពិសេសមូលនិធិសមធម៌សុខភាព អាហារូបករណ៍ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងត្រូវបានពង្រីកដើម្បីគាំទ្រដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធ។ មកទល់បច្ចុប្បន្ន មានការផ្តួចផ្តើមជាច្រើនដើម្បីបង្កើនសុខុមាលភាព និងកាត់បន្ថយចំណាយលើការរស់នៅ ជាពិសេសសម្រាប់កម្មកររោងចក្រ។ ការផ្តួចផ្តើមទាំងនេះរួមមាន លទ្ធភាពទទួលបានការថែទាំសុខភាពដោយឥតគិតថ្លៃ កំណើនប្រាក់ឈ្នួលក្នុងពេលសម្រាកលំហែមាតុភាព ជំនួយហិរញ្ញវត្ថុដល់ការសម្រាលកូន ការបញ្ចុះតម្លៃទឹកភ្លើង និងការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈដោយឥតគិតថ្លៃ។ ក្នុងរយៈពេលវែង ការអនុវត្តកម្មវិធីជំនួយសង្គម (គ្រោះអាសន្ន ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសុខុមាលភាព) នឹងបង្កើនចល័តភាព និងអភិវឌ្ឍបណ្តុំជំនាញកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្ម។ ការអនុវត្តកម្មវិធីសន្តិសុខសង្គម (ប្រាក់សោធន ការធានារ៉ាប់រងសុខភាព និងការធានារ៉ាប់រងគ្រោះថ្នាក់ការងារ និងពិការភាព) ជួយធានាសុខុមាលភាព ជាពិសេសនៅពេលកម្មករនិយោជិតចាកចេញពីការងារ។ ប្រព័ន្ធប្រាក់សោធនសម្រាប់វិស័យឯកជនត្រូវបានលើកឡើងថានឹងបង្កើតឡើងនៅឆ្នាំ ២០១៩។

ការពិនិត្យតាមដាន និងវាយតម្លៃដោយប្រសិទ្ធភាព គឺជាគន្លឹះក្នុងការធានាភាពជោគជ័យនៃគោលនយោបាយទាំងនេះ។ ក្នុងន័យនេះ កិច្ចសហការអន្តរភ្នាក់ងារយ៉ាងស្អិតរមួតនឹងធានាបានការអនុវត្តជាបន្តបន្ទាប់ ទំនាក់ទំនង និងភាពប្រទាក់ក្រឡាគ្នានៃគោលនយោបាយ យុទ្ធសាស្ត្រ និងកំណែទម្រង់ទាំងនោះ។

**រូប ១៩៖ កំណើនប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួលរបស់គ្រួសារនៅជនបទ** (គិតជាភាគរយ)




*ប្រភព៖* ការអង្កេតសេដ្ឋកិច្ចសង្គម

**ស្របទៅនឹងវឌ្ឍនភាពវិជ្ជមាននៃម៉ាក្រូសេដ្ឋកិច្ចក្នុងឆមាសទីពីរឆ្នាំ ២០១៧ ភាពក្រីក្រនឹងត្រូវបានរំពឹងថានឹងថយចុះ។** ការបន្តកំណើននៃការនាំចេញផលិផលកម្មន្តសាល និងសម្លៀកបំពាក់ និងការងើបឡើងវិញនៃវិស័យទេសចរណ៍ និងកសិកម្ម ជាពិសេសការកើនឡើងបន្តិចម្តងៗនៃថ្លៃផលិតផលកសិកម្ម បានផ្តល់ផលវិជ្ជមានទៅលើប្រាក់ចំណូលរបស់គ្រួសារក្រីក្រ។ ក្រៅពីនេះ ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរ និងស្បែកជើង ត្រូវបានបង្កើនជាផ្លូវការដល់ ១៧០ ដុល្លារក្នុងមួយខែ នៅឆ្នាំ ២០១៨ ដែលកើនឡើងចំនួន ១១% លើសពីឆ្នាំ ២០១៧។ ប្រាក់ឈ្នួលក្នុងវិស័យសាធារណៈក៏កើនឡើងផងដែរ។ រួមជាមួយនឹងការផ្តួចផ្តើមថ្មីៗមួយចំនួនរបស់អាជ្ញាធរកម្ពុជាក្នុងការកាត់បន្ថយការចំណាយលើជីវភាពរស់នៅរបស់កម្មកររោងចក្រ កំណើនប្រាក់ឈ្នួលនេះ នឹងបន្តធ្វើឲ្យភាពក្រីក្រធ្លាក់ចុះក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ នៅពេលដែលប្រាក់ចំណូលកើនឡើង កម្លាំងទិញក៏កើនឡើងផងដែរ ហើយនាំឲ្យមានកំណើននៃការប្រើប្រាស់ និងការចាយវាយប្រាក់នៅទីជនបទ។ ការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមប្រកបដោយជោគជ័យ (ដូចមានកំណត់ក្នុងក្របខណ្ឌគោលនយោបាយគាំពារសង្គមឆ្នាំ ២០១៦-២០២៥) អាចជួយមិនឲ្យគ្រួសារនៅជនបទធ្លាក់ចូលទៅក្នុងភាពក្រីក្រជាថ្មីឡើយ ។ បច្ចុប្បន្ននេះ សកម្មភាពសេដ្ឋកិច្ចដែលមិនមែនជាការងារកសិដ្ឋាននៅជនបទ (វាយនភ័ណ្ឌ សេវា និងការផ្ញើរប្រាក់) បានក្លាយជាកត្តាដ៏សំខាន់ដែលជួយកាត់បន្ថយភាពក្រីក្រ។

## ឃ) វិស័យរូបិយវត្ថុ

**ជាការគាំទ្រដល់កំណើនសេដ្ឋកិច្ច ការផ្គត់ផ្គង់សាច់ប្រាក់មានការកើនឡើង ប៉ុន្តែអតិផរណានៅតែមានកម្រិតទាប។** កំណើនរូបិយវត្ថុទូលាយត្រូវបានរំពឹងថានឹងជួយដល់សកម្មភាពសេដ្ឋកិច្ចក្នុងវិស័យផលិត។ ក្នុងបរិបទសេដ្ឋកិច្ចកម្ពុជាដែលមានអត្រាដុល្លារូបនីយកម្មខ្ពស់ កំណើនរូបិយវត្ថុទូលាយនៅតែត្រូវបានជំរុញជាសំខាន់ដោយអត្រាបញ្ញើដែលជារូបិយបណ្ណបរទេស ដែលកើតឡើងដោយកំណើននៃទំនុកចិត្តរបស់សាធារណជន។ លើសពីនេះទៀត ចរាចរណ៍រូបិយវត្ថុក្នុងស្រុកក៏កើនឡើងផងដែរ ដែលឆ្លុះបញ្ចាំងពីភាពជោគជ័យរបស់ធនាគារជាតិក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក។ កំណើនឥណទានក្នុងស្រុកបានថយចុះបន្តិច ប៉ុន្តែនៅតែមានកំណើនកើនឡើងដដែល ដោយបានកើនឡើងខ្ពស់ជាងកំណើនណូមីណាល (Real) នៅឆ្នាំ ២០១៧ (សូមមើលផ្នែកខាងក្រោមស្តីពីវិស័យធនាគារ)។ ជាលទ្ធផល ផលធៀបប្រាក់កម្ចី-ប្រាក់បញ្ញើ (អត្រាដុល) បានថយចុះពី ១០០% នៅឆ្នាំ ២០១៦ មកត្រឹម ៩៨% នៅឆ្នាំ ២០១៧។

### ក. រូបិយវត្ថុសរុប អត្រាការប្រាក់ និងអត្រាប្តូរប្រាក់

**កំណើនរូបិយវត្ថុទូលាយបានកើនឡើងយ៉ាងលឿនដោយមានចំនួនខ្ពស់បំផុតក្នុងរយៈពេល ២,៥ ឆ្នាំ ដោយសារតែកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។** រូបិយវត្ថុទូលាយបានកើនឡើងយ៉ាងឆាប់រហ័ស ដោយបានកើនឡើងចំនួន ២៣,៨ % (ធៀបនឹងឆ្នាំមុន) នៅអំឡុងខែ ធ្នូ ឆ្នាំ ២០១៧។ ចំនួននេះជាអត្រាកំណើនលឿនបំផុតចាប់តាំងពីខែ ឧសភា ឆ្នាំ ២០១៥ និងត្រូវបានជំរុញដោយកំណើនយ៉ាងលឿននៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (១៩,៦%) និងកំណើនចរាចរណ៍រូបិយវត្ថុក្នុងស្រុកយ៉ាងឆាប់រហ័ស (៣,២%) និងប្រាក់បញ្ញើជាប្រាក់រៀល (១,០%) (រូប ២០)។ នៅឆ្នាំ ២០១៦ រូបិយវត្ថុទូលាយមាន កំណើនតែ ១៧,៩% ប៉ុណ្ណោះ ដែលរួមចំណែកដោយប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (១៥,២%) ចរាចរណ៍ប្រាក់រៀល (១,១%) និងប្រាក់បញ្ញើជាប្រាក់រៀល (១,៦%)។

**រូប ២០៖ បញ្ញើជារូបិយប័ណ្ណបរទេស នៅតែបន្តជំរុញធ្វើឲ្យមានកំណើនរូបិយវត្ថុទូលាយ។** ចំណែកដែលធ្វើអោយមានកំណើន M2 (ចំនួនគិតជាភាគរយ)




*ប្រភព៖* អាជ្ញាធរកម្ពុជា

**រូប ២១៖ ទុនបម្រុងអន្តរជាតិសរុបបានកើនឡើងបន្ថែមទៀត** (គិតជាពាន់លានដុល្លារ និងចំនួនខែនាំចូល)




*ប្រភព៖* អាជ្ញាធរកម្ពុជា
*សម្គាល់៖ RHS ខាងស្តាំ*

**កំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបង្ហាញពីទំនុកចិត្តច្រើនជាងមុនទៅលើប្រព័ន្ធធនាគារ និងលំហូរមូលធនល្អប្រសើរ។** ស្ថានភាពនេះបានជួយឲ្យធនាគារជាតិនៃកម្ពុជាបង្កើនទុនបម្រុងបរទេសសរុប ដែលកើនដល់ ៨,៧ ប៊ីលានដុល្លារ ឬស្មើនឹងរយៈពេល ៦,៨ ខែនៃចំនួននាំចូលដែលរំពឹងទុកនៅឆ្នាំ ២០១៧ (រូប ២១)។ ជោគជ័យដំបូងក្នុងការលើកកម្ពស់ប្រាក់រៀលបានធ្វើឲ្យមានកំណើនចរាចរណ៍ប្រាក់រៀលដោយគ្មានសម្ពាធទៅលើការធ្លាក់ថ្លៃរបស់ប្រាក់រៀល។ ជាលទ្ធផល ការទិញប្រាក់ដុល្លាររបស់ធនាគារកណ្តាលបានកើនឡើងបន្ថែមទៀតនៅឆ្នាំ ២០១៧ ហើយការទិញសរុបបានកើនឡើងដល់ ៩១៤,៦ លានដុល្លានៅឆ្នាំ ២០១៧ ឬស្មើនឹងកំណើន ១១,៤%[៩]។ តម្រូវការរូបិយវត្ថុក្នុងស្រុករបស់ធនាគារពាណិជ្ជបានកើនឡើងយ៉ាងខ្លាំង ដោយបានស្រូបយកជាង ៥០% នៃរូបិយវត្ថុក្នុងស្រុកសរុបដែលធនាគារកណ្តាលបានដាក់ចេញនៅឆ្នាំ ២០១៧។

**ប្រតិបត្តិការផ្តល់សាច់ប្រាក់ងាយស្រួល ដោយមានវត្ថុបញ្ចាំដែលបានណែនាំកាលពីឆ្នាំមុនដើម្បីកំណត់អត្រាគោលដៅសម្រាប់កម្ចីរូបិយវត្ថុក្នុងស្រុកក្នុងទីផ្សារ បច្ចុប្បន្ន កំពុងជំរុញការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក[១០]។** ការអនុវត្តនេះបានធ្វើឡើងបន្ទាប់ពីមានការណែនាំឲ្យប្រើប្រាស់វិញ្ញាបនប័ត្របញ្ញើដែលអាចជួញដូរបានដែលជាកម្ចីមានការប្រាក់រយៈពេលខ្លីដែលធនាគារជាតិចេញឲ្យដើម្បីបង្កើនប្រាក់កម្ចីរវាងធនាគារនឹងធនាគារ។ ប្រតិបត្តិការផ្តល់សាច់ប្រាក់ងាយស្រួលដោយមានវត្ថុបញ្ចាំ “កាត់បន្ថយ” ការផ្តល់សាច់ប្រាក់ងាយស្រួលច្រើន នៅពេលដែលតម្រូវការប្រាក់រៀលបន្ថែមក្នុងទីផ្សារ ត្រូវបានធនាគារជាតិផ្តល់ឲ្យ។ ប្រតិបត្តិការផ្តល់សាច់ប្រាក់ងាយស្រួលដោយមានវត្ថុបញ្ចាំ ជួយឲ្យធនាគារជាតិបង្កើនចរាចរណ៍បរិមាណប្រាក់រៀលទៅក្នុងរូបិយវត្ថុទូលាយរហូតដល់ ៣,២% នៅឆ្នាំ ២០១៧ ដែលកើនឡើងពី ១,១% នៅឆ្នាំ ២០១៦ ដោយរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារ (រូប ២២)។ ដូច្នេះ វិធានការទាំងនេះអាចជួយឲ្យកម្ពុជាទទួលបានឯករាជ្យភាពខ្លះៗលើ គោលនយោបាយរូបិយវត្ថុ រួមទាំង ការកំណត់គោលដៅលើការប្រាក់រយៈពេលខ្លី និងការបង្កើនការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ដែលមានកម្រិតទាបនាពេលបច្ចុប្បន្នដោយសារតែកម្រិតដុល្លារូបនីយកម្មខ្ពស់។

---

៩ របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ឆ្នាំ ២០១៧ ។

១០ យោងតាមធនាគារជាតិនៃកម្ពុជាប្រតិបត្តិការផ្តល់សាច់ប្រាក់ងាយស្រួលដោយមានវត្ថុបញ្ចាំ មានគោលបំណង (ក) បង្កើតគោលដៅសម្រាប់ទីផ្សារសំដៅជួយដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ ដោយផ្អែកលើយន្តការទីផ្សារ (ខ) លើកកម្ពស់វិញ្ញាបនប័ត្របញ្ញើដែលអាចជួញដូរបាន ដែលអាចប្រើប្រាស់ជាវត្ថុបញ្ចាំក្នុងប្រតិបត្តិការទីផ្សារអន្តរធនាគារ (គ) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល (ឃ) គាំទ្រការអភិវឌ្ឍវិស័យកសិកម្ម និង (ង) ចូលរួមចំណែកកាត់បន្ថយអត្រាការប្រាក់ខ្ពស់សម្រាប់ប្រាក់រៀលបច្ចុប្បន្ន។ អត្រាការប្រាក់របស់ប្រតិបត្តិការផ្តល់សាច់ប្រាក់ងាយស្រួលដោយមានវត្ថុបញ្ចាំ ត្រូវបានកំណត់ត្រឹម ៣% ក្នុងមួយឆ្នាំ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ ៖ https://www.nbc.org.kh/english/news_and_events/news_info.php?id=230។

**រូប ២២៖ ថ្មីៗនេះ ចរាចរណ៍ប្រាក់រៀលបានកើនឡើងនាពេលថ្មីៗនេះដោយមិនបានដាក់សម្ពាធឲ្យអត្រាប្តូរប្រាក់រៀល/ដុល្លារថយចុះ។** (បម្រែបម្រួលពីមួយឆ្នាំទៅមួយឆ្នាំ គិតជាភាគរយ)




*ប្រភព៖* អាជ្ញាធរកម្ពុជា
*សម្គាល់៖* RHS ខាងស្តាំ

**អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក បានកើនឡើងតិចតួចដោយកើនដល់ ៤.០០០ រៀល/ដុល្លានៅចុងខែ មីនា ឆ្នាំ ២០១៨** ធៀបនឹងអត្រាប្តូរប្រាក់រៀលចំនួន ៤.០៣៧ រៀល/ដុល្លា នៅខែ ធ្នូ ឆ្នាំ ២០១៦ (រូប ២៣)។ តម្លៃប្រាក់រៀលក៏កើនឡើងផងដែរបើធៀបនឹងប្រាក់ដុងវៀតណាម ប៉ុន្តែធ្លាក់ថ្លៃបើធៀបនឹងប្រាក់បាតថៃ។ ធៀបនឹងរូបិយវត្ថុនៃទីផ្សារនាំចេញធំៗរបស់ខ្លួន (ក្រៅពីប្រាក់ដុល្លារអាមេរិក) ប្រាក់រៀលកំពុងធ្លាក់ថ្លៃ (ធៀបនឹងប្រាក់អឺរ៉ូ ដុល្លារកាណាដា និងប្រាក់ផោនអង់គ្លេស)។

**រូប ២៣៖ ប្រាក់រៀលបានធ្លាក់ចុះបន្តិចធៀបនឹងប្រាក់បាតថៃ**




*ប្រភព៖* អាជ្ញាធរកម្ពុជា ធនាគារថៃ និងការិយាល័យស្ថិតិវៀតណាម

ទាំងកម្ចីប្រាក់ដុល្លារអាមេរិករយៈពេលខ្លី (១២ ខែ) និងអត្រាការប្រាក់បញ្ញើ សុទ្ធតែធ្លាក់ចុះបន្តិច (រូប ២៤) ដោយធ្លាក់ចុះមកត្រឹម ១១,៧% សម្រាប់ប្រាក់កម្ចីដុល្លារអាមេរិក និង ៤,៤២% ការប្រាក់បញ្ញើ នៅឆ្នាំ ២០១៧ (ចុះពី ១១,៩% និង ៤,៤៤% នៅឆ្នាំ ២០១៦)។ ការថយចុះនេះអាចបណ្តាលមកពីការអនុវត្តវិធានការម៉ាក្រូសេដ្ឋកិច្ចប្រយ័ត្នប្រយែងនាពេលថ្មីៗនេះ រួមទាំង ការកំណត់អត្រាការប្រាក់។

**រូប ២៤៖ មធ្យមភាគអត្រាការប្រាក់ដុល្លារអាមេរិករយៈពេលខ្លី (១២ ខែ)** (គិតជាភាគរយក្នុងមួយឆ្នាំ)




*ប្រភព៖* អាជ្ញាធរកម្ពុជា
*សម្គាល់៖* RHS ខាងស្តាំ

**ការធ្លាក់ចុះបញ្ញើប្រាក់រៀលរយៈពេលខ្លី (១២ ខែ) និងអត្រាកម្ចី ដែលវិស័យហិរញ្ញវត្ថុបានជួប ប្រទះ ក្រោយពីការបញ្ចប់ការអនុវត្តការកំណត់អត្រាការប្រាក់នៅខែ មេសា ឆ្នាំ ២០១៧។** ជាលទ្ធផល ភាពប្រសព្វគ្នានៃអត្រាប្រាក់បញ្ញើជាប្រាក់រៀល និងប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក (និងកម្ចី) បានថយចុះ (រូប ២៥)។ ភាពខុសគ្នារវាងអត្រានៃកម្ចី (បញ្ញើ) ជាប្រាក់រៀល និងកម្ចីជាប្រាក់ដុល្លារអាមេរិក អាចឆ្លុះបញ្ចាំងពីការចំណាយខ្ពស់ជាងមុននៃកម្ចីប្រាក់រៀលធៀបនឹងកម្ចីជាប្រាក់ដុល្លារអាមេរិក នៅក្នុងកម្មវិធីប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដែលតម្រូវឲ្យមានវត្ថុបញ្ចាំដើម្បីទទួលបានប្រាក់រៀលដែលត្រូវការ។ លក្ខខណ្ឌតម្រូវដែលធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុបង្កើនប្រាក់កម្ចីជាប្រាក់រៀល ដែលបានកើនឡើងប្រមាណ យ៉ាងតិច ១០% នៃប្រាក់កម្ចីសរុបរបស់ខ្លួននៅបំណាច់ឆ្នាំ ២០១៩ បានបង្កើនតម្រូវការប្រាក់រៀល។ ស្ថានភាពនេះបានជួយរក្សាស្ថិរភាពនៃអត្រាប្តូរប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក នៅពេលប្រាក់រៀលដែលមានចរាចរណ៍កើនឡើង[១១]។

---

១១ ប្រកាស ប៧-០១៦-៣៣៤-ផ-ក ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ធនាគារជាតិកម្ពុជា ដែលចូលជាធរមាននៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ហើយត្រូវអនុវត្តពេញលេញនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩។

**រូប ២៥៖ ភាពប្រសព្វគ្នារវាងអត្រាប្រាក់បញ្ញើ** (និងប្រាក់កម្ចី) **ជាប្រាក់រៀល និងដុល្លារ បានបញ្ឈប់** (ជាភាគរយក្នុងមួយឆ្នាំ)




*ប្រភព៖ អាជ្ញាធរកម្ពុជា*

**ការបញ្ចុះអត្រាប្រាក់កម្ចីជាប្រាក់រៀល ជាមួយនិងការរក្សាស្ថិរភាពនៃអត្រាប្តូរប្រាក់រៀលនឹងដុល្លារអាមេរិក អាចជួយឲ្យធនាគារជាតិទទួលបានឯករាជ្យភាពនៃគោលនយោបាយរូបិយវត្ថុរបស់ខ្លួនឡើងវិញ។** គោលនយោបាយរូបិយវត្ថុរបស់កម្ពុជា តែងត្រូវបានជួបប្រទះបញ្ហាដោយសារតែកម្រិតដុល្លាររូបនីយកម្មខ្ពស់ ។ ថ្មីៗនេះ វត្ថុប្រចាំបានក្លាយជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ដោយសារតែវត្ថុប្រចាំនេះជួយជំរុញទីផ្សាររវាងធនាគារ និងធនាគារ។ នៅឆ្នាំ ២០១៧ នៅពេលដែលតម្រូវការវិញ្ញាបនប័ត្របញ្ញើដែលអាចជួញដូរបាន កើនឡើង (ដោយធនាគារពាណិជ្ជ) បរិមាណទឹកប្រាក់ (មិនទាន់ទូទាត់) ជាប្រាក់ដុល្លារអាមេរិក ដែលបានផ្តល់ជូន បានកើនឡើងយ៉ាងខ្លាំងរហូតដល់ ២០,៨ ប៊ីលានដុល្លារ ឬស្មើនឹងកំណើន ៩៣%[១២]។ ដូចគ្នានេះដែរ បរិមាណវិញ្ញាបនប័ត្របញ្ញើដែលអាចជួញដូរបានជាប្រាក់រៀល ក៏កើនឡើងដែរ ដែលមានចំនួនរហូតដល់ ១៥,៥ ទ្រីលានរៀល (ស្មើនឹង ៣,៨៧ ពាន់លានដុល្លារ) ឬស្មើនឹងកំណើន ២៩%។

## ខ. វិស័យធនាគារ

**វឌ្ឍនភាពថ្មីៗក្នុងវិស័យធនាគាររួមមានកំណើនប្រាក់បញ្ញើ និងកំណើនឥណទានតិចតួច** (រូប ២៦)។ ជារួម ឥណទានរបស់វិស័យធនាគារបានថយចុះយ៉ាងច្រើន ទោះបីជានៅតែមានការកើនឡើងក្តី ដោយសារតែការអនុវត្តការកំណត់អត្រាការប្រាក់នៅខែ មេសា ឆ្នាំ ២០១៧។ កំណើនឥណទានរបស់វិស័យធនាគារបានថយចុះមកត្រឹម ១៩,៦% (ធៀបនឹងឆ្នាំមុន) នៅខែធ្នូ ឆ្នាំ ២០១៧ ដោយចុះពី ២៥,៨ % នៅឆ្នាំ ២០១៦។

**រូប ២៦៖ កំណើនឥណទានមានការថយចុះ តែកំណើនប្រាក់បញ្ញើនៅតែរឹងមាំ។** (គិតពីដើមឆ្នាំមកដល់បច្ចុប្បន្ន បម្រែបម្រួលពីមួយឆ្នាំទៅមួយឆ្នាំ គិតជាភាគរយ)




*ប្រភព៖ អាជ្ញាធរកម្ពុជា*
*សម្គាល់៖ PS វិស័យឯកជន*

**ទំនុកចិត្តកាន់តែមានច្រើនជាងមុនលើវិស័យធនាគារ បានបង្កើនប្រាក់បញ្ញើក្នុងវិស័យឯកជនថែមទៀត។** ប្រាក់បញ្ញើវិស័យឯកជនបានកើនឡើងចំនួន ២៣,០ % នៅឆ្នាំ ២០១៧ ដោយកើនឡើងពី ១៩,៣ % នៅឆ្នាំ ២០១៦ (និង ១៦,៦% នៅឆ្នាំ ២០១៥) ដែលបង្ហាញពីភាពទាក់ទាញកាន់តែខ្លាំង ដោយសារតែគោលនយោបាយសេដ្ឋកិច្ចសេរីរបស់កម្ពុជា។ យ៉ាងណាក៏ដោយ ផលធៀបប្រាក់កម្ចី នឹងប្រាក់បញ្ញើ នៅតែមានកម្រិតខ្ពស់គឺ ៩៥% នៅឆ្នាំ ២០១៧។

**កំណើនឥណទានយ៉ាងលឿននៅក្នុងរយៈពេលប៉ុន្មានឆ្នាំមុនទៅនេះ បានជំរុញឲ្យមានឥណទានមិនទាន់ទូទាត់ ដែលវិស័យធនាគារបានផ្តល់ ដើម្បីសម្រេចបានអត្រាជាង ១០០% នៃ ផសស** (រូប ២៧)។ ដូចគ្នានេះដែរ ប្រាក់បញ្ញើវិស័យឯកជនបានកើនឡើងដល់ ១០០% នៃ ផសស នៅឆ្នាំ ២០១៧។ កំណើននេះមានន័យថា វិស័យហិរញ្ញវត្ថុបានដើរតួនាទីកាន់តែសំខាន់ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច។ អាចលើកឡើងម្យ៉ាងទៀតថា គោលនយោបាយវិស័យហិរញ្ញវត្ថុ និងធនាគារ កំពុងក្លាយជាឧបករណ៍ ដ៏សំខាន់សម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។ ទោះបីជាមានការចូលជ្រៅផ្នែកហិរញ្ញវត្ថុយ៉ាងលឿនក្តី ក៏អត្រាប្រាក់កម្ចីមិនដំណើរការដែលបានរាយការណ៍ សម្រាប់វិស័យធនាគារ នៅតែមានកម្រិតថេរត្រឹម ២,៤% នៅឆ្នាំ ២០១៧ ធៀបនឹងអត្រា ២,៥% នៅឆ្នាំ ២០១៦។

---

១២ របាយការណ៍ធនាគារជាតិនៃកម្ពុជាឆ្នាំ ២០១៧ ។

ទោះជាយ៉ាងនេះក៏ដោយ អត្រាប្រាក់កម្ចីដែលមិនដំណើរការទាំងនេះ គួរតែមានការបកស្រាយដោយប្រយ័ត្នប្រយែង។ មានភាពមិនស៊ីសង្វាក់គ្នារវាងចំណាត់ថ្នាក់ប្រាក់កម្ចី និងការផ្ទេរ ការផ្តល់ហិរញ្ញប្បទានឡើងវិញនៃប្រាក់កម្ចី ដែលអាចបិទបាំងបញ្ហាជ្រៅជាងនេះ។

**រូប ២៧៖ ឥណទាន និងប្រាក់បញ្ញើរបស់វិស័យធនាគារបានកើនឡើងយ៉ាងឆាប់រហ័ស** (គិតជាភាគរយ ផសស)




*ប្រភព៖ អាជ្ញាធរកម្ពុជា*

**ផ្ទុយទៅនឹងការថយចុះនាពេលថ្មីៗនេះ នៃកំណើនវិស័យហិរញ្ញវត្ថុ ឥណទានសម្រាប់វិស័យសំណង់ និង អចលនទ្រព្យ បានកើនឡើងបន្ថែមទៀតនៅឆមាសទីពីរនៃឆ្នាំ ២០១៧** (រូប ២៨)។ ឥណទានក្នុងស្រុកសម្រាប់វិស័យនេះ បានកើនឡើងប្រមាណ ៣៦,១% ធៀបនឹងឆ្នាំមុន នៅខែ ធ្នូ ឆ្នាំ ២០១៧ ដោយកើនឡើងពី ២៨,៤% នៅខែ មីនា ឆ្នាំ ២០១៧ ដោយសារមានកំណើនវិនិយោគលើវិស័យសំណង់ និងអចលនទ្រព្យសារជាថ្មី។ ការចូលរួមចំណែករបស់វិស័យនេះសម្រាប់កំណើនឥណទានសរុប បានកើនឡើងយ៉ាងខ្លាំង ស្មើនឹង ៨,១% (នៃអត្រាសរុប ១៨,៦%) នៅឆ្នាំ ២០១៧ ដោយកើនឡើងពី ៦,៤% (នៃអត្រាសរុប ២០,១%) នៅឆ្នាំ ២០១៦។ វិស័យនេះបានចូលរួមចំណែកដល់ឥណទានសរុបប្រមាណ ២៦% នៅឆ្នាំ ២០១៧ ដោយកើនឡើងពីចំនួន ២២% នៅឆ្នាំ ២០១៦។ ជារួម ឥណទានសរុបមិនទាន់ទូទាត់ក្នុងវិស័យសំណង់ និងអចលនទ្រព្យ និងការបញ្ចាំមានចំនួន ៩,១ ប៊ីលានដុល្លារនៅឆ្នាំ ២០១៧ ដោយកើនឡើងពី ៣,០ ប៊ីលានដុល្លារនៅឆ្នាំ ២០១៦។

**រូប ២៨៖ ការរួមចំណែកចំពោះកំណើនឥណទានក្នុងស្រុក** (គិតជាភាគរយ)




*ប្រភព៖ អាជ្ញាធរកម្ពុជា*

**ចំណែកឥណទានក្នុងស្រុកសម្រាប់វិស័យពាណិជ្ជកម្ម (លក់ដុំលក់រាយ) វិស័យកម្មន្តសាល និងសណ្ឋាគារ បានធ្លាក់ចុះ ដែលជាសញ្ញាបង្ហាញភាពធ្លាក់ចុះជាបន្តទៀតនៃការប្រកួតប្រជែងក្នុងវិស័យកម្មន្តសាល និងវិស័យពាណិជ្ជកម្ម។** ការថយចុះភាពប្រកួតប្រជែងអាចធ្វើឲ្យវិស័យកម្មន្តសាល និងពាណិជ្ជកម្មមានភាពទាក់ទាញតិចជាងមុនសម្រាប់វិនិយោគិន និងអ្នកផលិត។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសទៅក្នុងវិស័យកម្មន្តសាល បានថយចុះក្នុងរយៈពេលពីរបីឆ្នាំកន្លងទៅនេះ (រូប ២៩)។ ស្ថានភាពនេះអាចបណ្តាលមកពីកំណើនប្រាក់ឈ្នួលយ៉ាងលឿន និងចំណាត់ថ្នាក់ទាបរបស់កម្ពុជា នៅក្នុងរបាយការណ៍ស្តីពីការធ្វើអាជីវកម្ម[១៣] ។ ស្ថានភាពនេះមិនមានភាពប្រសើរសម្រាប់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ទេ។

---

១៣ចំណាត់ថ្នាក់នៃការធ្វើអាជីវកម្មរបស់កម្ពុជានៅតែមានកម្រិតទាប។ កម្ពុជាស្ថិតនៅលំដាប់ទី ១៣១ ក្នុងចំណោមប្រទេស ១៩០ នៅឆ្នាំ ២០១៧ ធៀបនឹងលំដាប់ទី ៨២ សម្រាប់វៀតណាម និងលំដាប់ទី ៤៦ សម្រាប់ប្រទេសថៃ។ ការចាប់ផ្តើមអាជីវកម្មស្ថិតក្នុងចំណាត់ថ្នាក់ទាបបំផុត (ទី ១៨០) ចំណែកថិរវេលាក្នុងការចុះបញ្ជីអាជីវកម្មមានអត្រា ៤ ដងយូរជាងមធ្យមភាគរបស់បណ្តាប្រទេសនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។

**រូប ២៩ ៖ ឥណទានក្នុងស្រុកដែលផ្ដល់ហិរញ្ញប្បទានដល់ពាណិជ្ជកម្ម កម្មន្តសាល និងសណ្ឋាគារ** (គិតជាភាគរយនៃចំនួនសរុប)




*ប្រភព៖* អាជ្ញាធរកម្ពុជា *សម្គាល់៖* RHS ខាងស្ដាំ

## ង) វិស័យសារពើពន្ធ

**ដំណើរការសារពើពន្ធបច្ចុប្បន្ននេះឆ្លុះបញ្ចាំងពីគោលនយោបាយពង្រីកសារពើពន្ធរបស់អាជ្ញាធរកម្ពុជា។** សេចក្ដីសម្រេចរបស់អាជ្ញាធរកម្ពុជាក្នុងការបង្កើនប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ បានបង្កើនការចំណាយ ប៉ុន្តែឥទ្ធិពលរបស់វាលើឱនភាពសារពើពន្ធត្រូវបានដោះស្រាយដោយការប្រមូលប្រាក់ចំណូលដ៏រឹងមាំ។ ការប្រមូលប្រាក់ចំណូលដ៏រឹងមាំបំផុតនៅឆ្នាំ ២០១៧ ដែលមកពីកំណើនការអនុលោមតាមការបង់ពន្ធ បានជួយកាត់បន្ថយឱនភាពនេះ។

### ក. ការប្រមូលប្រាក់ចំណូល

**ការបន្តប្រមូលប្រាក់ចំណូលដ៏រឹងមាំមានកម្រិតលើសពីការរំពឹងទុក។** ប្រាក់ចំណូលក្នុងស្រុកជារួមរបស់រដ្ឋាភិបាលត្រូវបានរំពឹងថានឹងកើនឡើងលឿនជាងការរំពឹងទុក ដោយសារដំណើរការដ៏រឹងមាំ រយៈពេលយូរនៃការប្រមូលប្រាក់ចំណូលរដ្ឋ។ នៅឆ្នាំ ២០១៧ ប្រាក់ចំណូលក្នុងស្រុកបានកើនឡើងដល់ ១៨% ដែលកើនឡើងពី ១៦% នៅឆ្នាំ ២០១៦។ ប្រាក់ចំណូលក្នុងស្រុកត្រូវបានប៉ាន់ស្មានថាកើនឡើងដល់ ១៧,៦ ទ្រីលានរៀល (៤,៤ ប៊ីលានដុល្លារ) ឬស្មើនឹង ១៩,៧% នៃ ផសស។ កំណើននេះស្មើនឹងទឹកប្រាក់ចំនួន ១៧,៥ ទ្រីលានរៀល ឬ ៦៦២ លានដុល្លាច្រើនជាងការប្រមូលប្រាក់ចំណូលនៅឆ្នាំ ២០១៦។ ប្រាក់ចំណូលក្នុងស្រុកបានកើនឡើងយ៉ាងលឿន ក្នុងមធ្យមភាគ ១៥% ក្នុងមួយឆ្នាំ នៅក្នុងអំឡុងពីឆ្នាំ ២០១៣ ដល់ ២០១៧ ដែលធ្វើឲ្យមានកំណើន ៥% នៃ ផសស នៅពេលដែលផលធៀបរវាងប្រាក់ចំណូល-ផសស កើនឡើងដល់ ១៩,៧% នៅឆ្នាំ ២០១៧ ដែលកើនពី ១៤,៦ % នៃ ផសស នៅឆ្នាំ ២០១៣។

**ក្នុងចំណោមនេះ ចំណូលពន្ធបានកើនឡើងគួរឲ្យកត់សម្គាល់** ដែលបានធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមបណ្ដាប្រទេសដែលមានការប្រមូលចំណូលពន្ធបានល្អបំផុត ដោយធៀបនឹងភាគរយ ផសស (រូប ៣០)។ នៅអំឡុងពីឆ្នាំ ២០១៣ ដល់ ២០១៧ ចំណូលពន្ធបានកើនឡើងជាង ៤% នៃ ផសស ដោយកើនដល់ ១៦% នៃ ផសស នៅឆ្នាំ ២០១៧។ ការប្រៀបធៀបក្នុងតំបន់បង្ហាញថា ចំណូលពន្ធរបស់កម្ពុជាធៀបនឹងភាគរយ ផសស នៅឆ្នាំ ២០១៧ ស្ថិតក្នុងចំណោមប្រទេសដែលមានការប្រមូលចំណូលពន្ធបានល្អបំផុត។

**រូប ៣០៖ ការប្រៀបធៀបប្រាក់ចំណូលពន្ធក្នុងតំបន់** (គិតជាភាគរយ ផសស)




*ប្រភព៖* សូចនាករអភិវឌ្ឍន៍ពិភពលោក និងអាជ្ញាធរកម្ពុជា។ ទិន្នន័យថ្មីបំផុតតាមឆ្នាំដែលមាន។

**សមាសភាពធំបំផុតនៃចំណូលពន្ធនៅតែជាពន្ធប្រយោល ដែលមានចំនួន ៦០% នៃចំណូលពន្ធសរុប។** ជាមួយនឹងពន្ធតម្លៃបន្ថែមដែលមានអត្រាខ្ពស់ជាងគេ ដោយមានចំណែកពន្ធតម្លៃបន្ថែមក្នុងស្រុកកើនឡើង នៅពេលកំណើនការចំណាយលើការប្រើប្រាស់ពន្ធប្រយោលបានកើនឡើងយ៉ាងខ្លាំង ដោយកើនដល់ ៩,៦% នៃ ផសស នៅឆ្នាំ ២០១៧ ពី ៨,៨% នៅឆ្នាំ ២០១៦ (រូប ៣១)។ ការប្រមូលពន្ធប្រយោលត្រូវបានប៉ាន់ស្មានថានឹងកើនឡើងយ៉ាងលឿនដល់ ១៩% នៅឆ្នាំ ២០១៧ ពី ១៤% នៅឆ្នាំ ២០១៦។

**រូប ៣១៖ ផ្នែកសំខាន់ៗនៃចំណូលទូទៅរបស់រដ្ឋាភិបាល** (គិតជាភាគរយ ផសស)




*ប្រភព៖* អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់៖* e ការប៉ាន់ស្មាន

**ពន្ធដោយផ្ទាល់ក៏មានស្ថានភាពល្អប្រសើរដែរ ដោយកើនឡើងដល់ ៤,២% នៃ ផសស នៅឆ្នាំ ២០១៧ ធៀបនឹងចំនួន ៣,៦% នៃ ផសស នៅឆ្នាំ ២០១៦**[១៤]**។** នៅអំឡុងពីឆ្នាំ ២០១៣ ដល់ ២០១៧ ពន្ធដោយផ្ទាល់បានកើនឡើងលឿនបំផុតក្នុងកម្រិត ៦៥% ទោះបីជាវាផ្អែកលើមូលដ្ឋានដ៏តិចតួចក្តី។ ពន្ធប្រយោលស្ថិតនៅលំដាប់ទីពីរដែលមានកម្រិត ៤០%។ ទោះជាយ៉ាងណាក៏ដោយ ចំណែកពន្ធដោយផ្ទាល់ធៀបនឹងចំណូលពន្ធសរុបកើនឡើងយឺតក្នុងកម្រិត២៦% នៅឆ្នាំ២០១៧ ធៀបនឹង ២២% នៅឆ្នាំ២០១៣។ ដោយសារការប្តេជ្ញាចិត្តរបស់កម្ពុជា នៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន ពន្ធពាណិជ្ជកម្មបានថយចុះពី ២១% មកត្រឹម ១៤%។ ដូច្នេះ ប្រព័ន្ធពន្ធរបស់កម្ពុជានៅតែពឹងផ្អែកលើពន្ធប្រយោល ហើយការប្រៀបធៀបក្នុងតំបន់បង្ហាញថា ការប្រមូលប្រាក់ចំណូលពន្ធដោយផ្ទាល់របស់កម្ពុជាធៀបនឹងប្រាក់ចំណូលក្នុងស្រុកសរុប នៅតែមានទំហំតូចដដែល (រូប ៣២)។

**រូប ៣២៖ ការប្រមូលពន្ធផ្ទាល់-ការប្រៀបធៀបក្នុងតំបន់** (គិតជាភាគរយនៃប្រាក់ចំណូល)




*ប្រភព៖* សូចនាករអភិវឌ្ឍន៍ពិភពលោក និងអាជ្ញាធរកម្ពុជា។ ទិន្នន័យថ្មីបំផុតតាមឆ្នាំដែលមាន។

**ផ្នែកសំខាន់ៗនៃប្រាក់ចំណូល (លើកលែងតែផ្នែកមិនមែនពន្ធ) បានបង្ហាញពីកំណើនគ្រប់ផ្នែក ហើយធ្វើឲ្យការប្រមូលប្រាក់ចំណូលក្នុងស្រុកមានភាពល្អប្រសើរនៅឆ្នាំ ២០១៧** (រូប ៣៣)។ កំណើន នេះបង្ហាញពីតួនាទីដ៏សំខាន់នៃការគ្រប់គ្រងចំណូល ដែលជាសសរស្តម្ភមួយនៃយុទ្ធសាស្ត្រប្រមូលពន្ធ ពីឆ្នាំ ២០១៤ ដល់ ២០១៨ ដែលជាការគាំទ្រឲ្យកម្ពុជាសម្រេចបានការប្រមូលប្រាក់ចំណូលដោយជោគជ័យក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ ទោះបីជានៅតែអាចមានចំណុចត្រូវកែលម្អទៅលើការគ្រប់គ្រងពន្ធក្តី ក៏មានការរំពឹងថា ប្រសិនបើមានការអនុវត្តយុទ្ធសាស្ត្រប្រមូលប្រាក់ចំណូលថ្មី យុទ្ធសាស្ត្រនោះត្រូវផ្តោតលើការកែលម្អពន្ធដោយផ្ទាល់ ដែលកំពុងប្រឈមនឹងបញ្ហានៃការលើកទឹកចិត្តពន្ធរួមទាំងរយៈពេលរួចពន្ធយូរផងដែរ។

**រូប ៣៣៖ ការរួមចំណែកចំពោះការប្រមូលប្រាក់ចំណូលក្នុងស្រុកកើនឡើង** (គិតជាភាគរយ ផសស)




*ប្រភព៖* អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់៖* InD ពន្ធប្រយោល

## ខ.ចំណាយសាធារណៈ

**សេចក្តីសម្រេចរបស់អាជ្ញាធរកម្ពុជាក្នុងការបង្កើនបៀវត្សរ៍មន្ត្រីរាជការ បានបង្កើនការចំណាយ។** បញ្ជីចំណាយលើប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈបានកើនឡើងយ៉ាងលឿន ចាប់តាំងពីឆ្នាំ ២០១៣ ហើយត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ ៧,៧% នៃ ផសស នៅឆ្នាំ ២០១៧ ដោយសារការខិតខំសម្រេចបានគោលដៅប្រាក់បៀវត្សរ៍អប្បបរមារបស់មន្ត្រីរាជការឲ្យបានយ៉ាងហោចណាស់ ១ លានរៀល (ប្រហែល ២៥០ ដុល្លារ) ក្នុងមួយខែត្រឹមឆ្នាំ ២០១៨។ ប្រាក់បៀវត្សរ៍អប្បបរមារបស់មន្ត្រីរាជការនៅឆ្នាំ ២០១៨ កើនឡើងស្ទើរតែបីដងបើធៀបនឹងប្រាក់ឈ្នួលឆ្នាំ

---

១៤ ពន្ធដោយផ្ទាល់រួមមានពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ និងពន្ធលើមូលធន។

២០១៣[១៥]។ ជាលទ្ធផល ចំណាយសាធារណៈបានកើនឡើងដល់ទៅ ២២,៣% នៃ ផសស នៅឆ្នាំ ២០១៧ ដែលកើនឡើងពី ២១,១% នៅឆ្នាំ ២០១៥ (រូប ៣៤)។

**រូប ៣៤ ៖ ដោយសារកំណើនប្រាក់ឈ្នួលក្នុងវិស័យសាធារណៈ ការចំណាយបាន និងកំពុងកើនឡើងតាំងពីឆ្នាំ ២០១៥** (គិតជាភាគរយ ផសស)




*ប្រភព៖* អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់៖* NSDP ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

**ចំណាយលើការវិនិយោគមូលធនសរុបគិតជាភាគរយនៃ ផសស មាននិន្នាការថយចុះ សំខាន់ ដោយសារតែការថយចុះជាបន្តបន្ទាប់នៃផ្នែកដែលទទួលបានហិរញ្ញប្បទានក្រៅប្រទេស ។** ចំណាយមូលធននៅឆ្នាំ ២០១៧ ត្រូវបានប៉ាន់ស្មានថា នៅតែមានកម្រិតទាបជាងកម្រិតកំណត់ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤ ដល់ ២០១៨។ បើទោះជាកម្រិតនៃការវិនិយោគមូលធនសាធារណៈបច្ចុប្បន្ន អាចប្រហាក់ប្រហែលគ្នានឹងប្រទេសក្នុងតំបន់ គុណភាពហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជានៅក្រោមគេនៅឡើយ ដែលបង្ហាញពីប្រសិទ្ធភាពទាបនៃការវិនិយោគវិស័យសាធារណៈ (តារាង ១)។ ដូច្នេះ ចាំបាច់ត្រូវមានការបង្កើនការចំណាយមូលធនដែលទទួលបានហិរញ្ញប្បទានពីរដ្ឋាភិបាលដើម្បីបង្កើនការវិនិយោគប្រកបដោយផលិតភាព ទន្ទឹមនឹងការបង្កើនផលនៃការចំណាយ។

**តារាង ១ ៖ គុណភាពហេដ្ឋារចនាសម្ព័ន្ធ (២០១៤)**

| | លទ្ធភាពទទួលបានអគ្គិសនីប្រើប្រាស់ | ចំណាយក្នុងការនាំចេញ | គុណភាពហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ |
|---|---|---|---|
| ម៉ាឡេស៊ី | 100.0 | 525.0 | 5.6 |
| សិង្ហបុរី | 100.0 | 460.0 | 6.7 |
| ថៃ | 100.0 | 595.0 | 4.5 |
| វៀតណាម | 99.2 | 610.0 | 3.7 |
| ឥណ្ឌូណេស៊ី | 97.0 | 571.8 | 4.0 |
| អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក (លើកលែងតែប្រទេសមានប្រាក់ចំណូលខ្ពស់) | 96.2 | 923.5 | 3.5 |
| ហ្វីលីពីន | 89.1 | 755.0 | 3.5 |
| ម៉ុងហ្គោលី | 85.6 | 2745.0 | 1.7 |
| ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប | 79.5 | 1712.2 | 3.3 |
| ឡាវ | 78.1 | 1950.0 | 2.6 |
| កម្ពុជា | 56.1 | 795.0 | 3.6 |
| មីយ៉ាន់ម៉ា | 52.0 | 620.0 | 2.6 |

*ប្រភព៖* សូចនាករអភិវឌ្ឍន៍ពិភពលោក។ ទិន្នន័យថ្មីបំផុត តាមឆ្នាំដែលមាន។
លទ្ធភាពទទួលបានអគ្គិសនីប្រើប្រាស់ (គិតជាភាគរយនៃចំនួនប្រជាជន)
ចំណាយក្នុងការនាំចេញ (គិតជាដុល្លារក្នុងមួយកុងតឺន័រ)
គុណភាពហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ វេទិកាសេដ្ឋកិច្ចពិភពលោក (១=គ្មានការអភិវឌ្ឍន៍ រហូតដល់ ៧=ជឿនលឿន)

១៥ សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុម័តសេចក្តីព្រាងថវិកាឆ្នាំ ២០១៨ ដោយគណៈរដ្ឋមន្ត្រី ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧។

### គ. តុល្យភាពសារពើពន្ធ

**ឱនភាពសារពើពន្ធជារួមត្រូវបានប៉ាន់ស្មានថានៅថេរ ដោយសារតែភាពរឹងមាំនៃការប្រមូលចំណូល។** បើទោះជាការសម្រេចរបស់អាជ្ញាធរកម្ពុជាក្នុងការឡើងប្រាក់បៀវត្សរ៍មន្ត្រីរាជការ បានបង្កើនការចំណាយក្តី ឥទ្ធិពលនៃការចំណាយនេះលើឱនភាពសារពើពន្ធ ត្រូវបានដោះស្រាយដោយការប្រមូលប្រាក់ចំណូលដ៏រឹងមាំ។ ឱនភាពសារពើពន្ធ (មិនរាប់បញ្ចូលជំនួយឥតសំណង) ត្រូវបានប៉ាន់ស្មានថាបានថយមកត្រឹម ២,៧% នៃ ផសស នៅឆ្នាំ ២០១៧ ធៀបនឹងអត្រា ៣,៦% នៅឆ្នាំ ២០១៦ (រូប ៣៥)។ យ៉ាងណាក៏ដោយ កំណើនប្រាក់បៀវត្សរ៍វិស័យសាធារណៈយ៉ាងលឿន អាចបន្ថយមូលនិធិរដ្ឋាភិបាលសម្រាប់គម្រោងមូលធន ដែលកាន់តែធ្វើឲ្យ គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលទទួលហិរញ្ញប្បទានកាន់តែតិចពីម្ចាស់ជំនួយមានទំហំកាន់តែតូច។

**រូប ៣៥៖ ឱនភាពសារពើពន្ធរបស់រដ្ឋាភិបាលនៅតែបន្តស្ថិតក្រោមការគ្រប់គ្រងបាន** (គិតជាភាគរយ ផសស)




*ប្រភព៖* អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់៖* e = ការប៉ាន់ស្មាន

**នៅដំណាច់ឆ្នាំ ២០១៧ ប្រាក់បញ្ញើសរុបរបស់រដ្ឋាភិបាលនៅក្នុងប្រព័ន្ធធនាគារ បានកើនឡើងប្រមាណ ៣៤,៦% ឡើងដល់ចំនួន ២,៨ ប៊ីលានដុល្លារ ឬស្មើនឹង ១២,៧ % នៃ ផសស** ដោយសារតែកំណើនសារពើពន្ធក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រាក់បញ្ញើមួយភាគ (ប្រមាណ ២% នៃ ផសស) ត្រូវបានអាជ្ញាធរប្រើប្រាស់ជាការជំរុញសារពើពន្ធដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកល ឆ្នាំ២០០៨-២០០៩។ នៅកម្ពុជា គោលនយោបាយសារពើពន្ធនៅតែជាឧបករណ៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចតែមួយគត់ ដោយសារតែគោលនយោបាយរូបិយវត្ថុត្រូវបានរាំងស្ទះដោយសារតែដុល្លារូបនីយកម្មខ្ពស់នោះ។

### ឃ. ថវិកាឆ្នាំ ២០១៨

**នេះជាលើកដំបូងក្នុងរយៈពេលជាច្រើនឆ្នាំមកហើយដែលមានកំណើនសារពើពន្ធខ្ពស់ ដែលបង្កើន ទាំងចំណាយចរន្ត និងការវិនិយោគមូលធនក្នុងថវិកាឆ្នាំ ២០១៨។** ចំណាយសាធារណៈសរុបសម្រាប់ឆ្នាំ ២០១៨ ស្មើនឹង ២៤,០% នៃ ផសស ដែលបានកើនឡើងខ្ពស់ជាងចំណាយសាធារណៈ ដែលប៉ាន់ស្មានចំនួន ២២,៣% នៅឆ្នាំ ២០១៧។ ការបង្កើនចំណាយសាធារណៈភាគច្រើនទទួលបានហិរញ្ញប្បទានពីការដកប្រាក់បញ្ញើរដ្ឋាភិបាល ។ ថវិកាឆ្នាំ ២០១៨ មានគោលដៅដកប្រាក់បញ្ញើ (រូប ៣៦) ចាប់តាំងពីការជំរុញសារពើពន្ធក្នុងអត្រា ២% នៃ ផសស នៅឆ្នាំ ២០០៩ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៨-២០០៩។ ការបង្កើននេះបានពង្រីកទាំងការវិនិយោគសាធារណៈ និងប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈ។

**រូប ៣៦ ៖ ការដកប្រាក់ពីប្រាក់បញ្ញើរបស់រដ្ឋាភិបាលសម្រាប់រដ្ឋាភិបាលជាតិ** (គិតជាភាគរយ ផសស)




*ប្រភព៖* អាជ្ញាធរកម្ពុជា

**នេះជាលើកដំបូងក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក ដែលមានការបង្កើនការវិនិយោគមូលធនដែលទទួលបានហិរញ្ញប្បទានក្នុងស្រុកយ៉ាងច្រើនក្នុងថវិកាឆ្នាំ ២០១៨** (រូប ៣៧)។ ការបង្កើនសារពើពន្ធយ៉ាងច្រើនបានបង្កើនការចំណាយមូលធនដែលទទួលបានហិរញ្ញប្បទានក្នុងស្រុកពី ២,៣% នៅឆ្នាំ២០១៧ ទៅ ៣,២% នៃផសស ទៅឆ្នាំ២០១៨។ ជាលទ្ធផល ការចំណាយ មូលធនសរុប (ហិរញ្ញប្បទានក្នុង និងក្រៅប្រទេស) បានឈានដល់កម្រិតកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ (រូប ៣៨)។ ថវិកាសម្រាប់ចំណាយលើប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈក៏កើនឡើងផងរហូតដល់ ៨,៤% នៃ ផសស (កើនពី ៧,៧% នៅឆ្នាំ ២០១៧)។

### **រូប ៣៧៖ មានកំណើនយ៉ាងច្រើននៃមូលធនដែលទទួលបានហិរញ្ញប្បទានពីក្នុងស្រុក ក្នុងថវិកាឆ្នាំ ២០១៨** (គិតជាភាគរយផសស)




*ប្រភព៖* អាជ្ញាធរកម្ពុជា
*សម្គាល់៖* b ថវិកា, e ការប៉ាន់ស្មាន

### **រូប ៣៨៖ កំណើនសារពើពន្ធច្រើនគ្រាន់បើបានជំរុញការចំណាយមូលធនថវិកាក្នុងឆ្នាំ ២០១៨**




*ប្រភព៖* អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់៖* e ប៉ាន់ស្មាន, b ថវិកា

**ប្រាក់ចំណូលក្នុងស្រុកដែលបានកំណត់នៅឆ្នាំ ២០១៨ ហាក់ដូចជាមានលក្ខណៈអភិរក្ស បើប្រៀបទៅនឹងលទ្ធផលការប្រមូលប្រាក់ចំណូលបានល្អនៅឆ្នាំ ២០១៧។** ប្រាក់ចំណូលរដ្ឋត្រូវបានកំណត់ឲ្យកើនឡើងត្រឹមតែ ១៨,៥% នៃ ផសស ប៉ុណ្ណោះនៅឆ្នាំ ២០១៨ ដែលនៅក្រោមកម្រិត ១៩,៧% ដែលបានប៉ាន់ស្មាននៅឆ្នាំ ២០១៧ (រូប ៣៩)។ ដូចដែលបានពិភាក្សាខាងលើ ការប្រមូលប្រាក់ចំណូលដែលមានកំណើនយ៉ាងលឿនក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ អាចនឹងថយចុះ។ ដូច្នេះ គប្បីមានផែនការដើម្បីដាក់ចេញនូវយុទ្ធសាស្ត្រប្រមូលប្រាក់ចំណូលថ្មីក្នុងការប្រមូលចំណូលសម្រាប់រយៈពេល ៥ ឆ្នាំខាងមុខនេះ។

### **រូប ៣៩៖ ដោយសារដំណើរការល្អនៅឆ្នាំ ២០១៧ ចំណូលក្នុងស្រុកក្នុងកញ្ចប់ថវិកាឆ្នាំ ២០១៨ ហាក់មានកម្រិតទាប** (គិតជាភាគរយ ផសស)




*ប្រភព៖* អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់៖* e ប៉ាន់ស្មាន, b ថវិកា

**ឱនភាពសារពើពន្ធរួមត្រូវបានកំណត់ថានឹងកើនដល់ ៥,៤% នៃ ផសស ក្នុងថវិកាឆ្នាំ ២០១៨** ដែលកើនពី ២,៧% នៅឆ្នាំ ២០១៧ (រូប ៤០)។ ហិរញ្ញប្បទានពីក្រៅប្រទេសត្រូវបានកំណត់ថាមានចំនួន ៤,១% នៃ ផសស នៃចំនួន ៥,៤% នៃឱនភាពសារពើពន្ធ ផសស ដោយចំនួន ១,៣% នៃ ផសស ដែលនៅសល់ត្រូវបានកំណត់ថានឹងទទួលបានហិរញ្ញប្បទានក្នុងស្រុក ដោយភាគច្រើនត្រូវដកចេញពីប្រាក់បញ្ញើរដ្ឋាភិបាលនៅធនាគារជាតិ។ ដូចបានលើកឡើងខាងលើ ប្រាក់បញ្ញើរដ្ឋាភិបាលសរុបនៅធនាគារជាតិមានចំនួន ១២,៧% នៃ ផសស នៅបំណាច់ឆ្នាំ ២០១៧។

### **រូប ៤០៖ ការដកប្រាក់បញ្ញើរបស់រដ្ឋាភិបាលគឺដើម្បីផ្ដល់ហិរញ្ញប្បទានដល់ឱនភាពដែលមានទំហំធំគ្រាន់បើ** (គិតជាភាគរយ ផសស)




*ប្រភព៖* អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់៖* e ប៉ាន់ស្មាន, b ថវិកា

**ក្រសួងអប់រំ យុវជន និងកីឡា ទទួលបានអត្ថប្រយោជន៍ច្រើនជាងគេពីការបង្កើនការចំណាយថវិកា។** ក្រសួងបានទទួលចំណែកថវិកាវិនិយោគឆ្នាំ ២០១៨ ច្រើនបំផុត (រូប ៤១) ដើម្បីបំពេញ តម្រូវការសាងសង់សាលារៀនបន្ថែមនៅតាមខេត្ត។ ថវិកាវិនិយោគរបស់ក្រសួងមានចំនួន ៤២០ ទ្រីលានរៀល (ឬ ០,៥% នៃ ផសស) នៅឆ្នាំ ២០១៨ ដោយកើនពី ៩០ ទ្រីលានរៀលនៅឆ្នាំ ២០១៧។ មូលនិធិវិនិយោគលើគម្រោង (មិនបែងចែកតាមក្រសួង) និងថវិកាសម្រាប់ក្រសួងសាធារណការ និងដឹកជញ្ជូន ក៏ទទួលបានកំណើនថវិកាច្រើនដែរ។

**រូប ៤១៖ វិស័យអប់រំទទួលបានកំណើនការវិនិយោគមូលធនច្រើនជាងគេក្នុងកញ្ចប់ថវិកាឆ្នាំ ២០១៨** (គិតជាភាគរយ ផសស)




*ប្រភព៖ អាជ្ញាធរកម្ពុជា*

**ថវិកាសរុបរបស់ក្រសួងអប់រំ ដែលរួមទាំងផ្នែកហិរញ្ញប្បទានក្នុងស្រុក (ថវិកាចរន្ត និងមូលធន) និងផ្នែកហិរញ្ញប្បទានពីក្រៅប្រទេស បានកើនដល់ ៣,៥២ % នៃ ផសស ដែលកើនពី ៣,០៥ % នៅឆ្នាំ ២០១៧** (រូប ៤២)។ គិតជាតួលេខ ថវិកាសរុបបានកើនឡើងយ៉ាងខ្លាំង រហូតដល់ ៣,៤៣ ទ្រីលានរៀល (ស្មើនឹង ៨៦០ លានដុល្លារ) ដែលមានកំណើន ២៥,៥%។

**រូប ៤២៖ កញ្ចប់ថវិកាឆ្នាំ ២០១៨ សរុបរបស់ក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបង្កើន** (គិតជាភាគរយ ផសស)




*ប្រភព៖ អាជ្ញាធរកម្ពុជា*

**ក្រៅពីនេះទៀត ដើម្បីបំពេញតម្រូវការកើនឡើងនៃការវិនិយោគសាធារណៈ ថវិកាឆ្នាំ ២០១៨ បានបង្កើនចំនួនកំណត់នៃប្រាក់កម្ចី (សម្បទាន) ទៅដល់ ១ ប៊ីលានសិទ្ធិដកប្រាក់ពិសេស** ដែលកើនពី ០,៧ ពាន់លាននៃសិទ្ធិដកប្រាក់ពិសេសនៅឆ្នាំ ២០១៧។ ចំណុចសំខាន់ៗផ្សេងទៀតនៃថវិកាឆ្នាំ ២០១៨ រួមមាន វិសោធនកម្មទៅលើច្បាប់ស្តីពីសារពើពន្ធ ដើម្បីបញ្ចូលបទប្បញ្ញត្តិស្តីពីសារពើពន្ធសម្រាប់ការធ្វើអាជីវកម្មប្រេង និងរ៉ែ។ វិធានការនេះមានគោលបំណងបញ្ជាក់ពីបទប្បញ្ញត្តិស្តីពី សារពើពន្ធរបស់កម្ពុជាសម្រាប់ការធ្វើអាជីវកម្ម ប្រេង ឧស្ម័ន និងរ៉ែ។

## ២. ទស្សនវិស័យ និងហានិភ័យ

**ដំណើរនៃកំណើនខ្ពស់របស់កម្ពុជាត្រូវបានរំពឹងថានឹងបន្តទៅមុខទៀត។** កំណើនក្នុងឆ្នាំ ២០១៨ ត្រូវបានព្យាករថានឹងកើនឡើងបន្តិចដល់ ៦,៩% (តារាង ២) ដែលទទួលបានការគាំទ្រដោយកំណើននៃការចំណាយរបស់រដ្ឋាភិបាល និងស្ថានភាពអំណោយផលក្នុងពិភពលោក រួមទាំង តម្រូវការខ្ពស់ក្នុងប្រទេសជឿនលឿន។ យ៉ាងណាក៏ដោយ អត្រាកំណើនរបស់កម្ពុជាត្រូវបានរំពឹងថានឹងថយចុះបន្តិចម្តងៗ ប្រសិនបើបញ្ហារចនាសម្ព័ន្ធ (ឧ. ការបាត់បង់ភាពប្រកួតប្រជែង) មិនត្រូវបានដោះស្រាយនោះទេ។ គេរំពឹងថាការប្រកាសយុទ្ធសាស្រ្តចតុកោណថ្មីក្រោយការបោះឆ្នោតនឹងធ្វើឲ្យកំណែទម្រង់មានភាពប្រសើរឡើង។

**ក្នុងរយៈពេលមធ្យម លំហូរវិនិយោគបរទេសយ៉ាងច្រើន និងកំណើនការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធត្រូវបានរំពឹងថានឹងជួយពង្រីកសមត្ថភាពផលិតកម្មនៃសេដ្ឋកិច្ចកម្ពុជា។** ការនាំចេញរបស់កម្ពុជាត្រូវបានរំពឹងថា នឹងបន្តទទួលបានអត្ថប្រយោជន៍ពីកម្មវិធីអនុគ្រោះល្អដែលមាននៅក្នុង ប្រព័ន្ធអនុគ្រោះពន្ធរបស់សហភាពអឺរ៉ុប ដែលមានឈ្មោះថា “អ្វីៗគ្រប់យ៉ាង លើកលែងតែអាវុធ” ក្នុងរយៈពេលជាច្រើនឆ្នាំខាងមុខ[១៦]។

**តារាង ២ ៖ អនាគតម៉ាក្រូសេដ្ឋកិច្ចវិជ្ជមាននៅតែមាន ទោះបីជាកំណើនមានការថយចុះបន្តិចក៏ដោយ**

| | 2018 | 2019 |
|---|---|---|
| **កំណើន ផសស** | 6.9 | 6.7 |
| **តម្រូវការក្នុងស្រុក (% បម្រែបម្រួលពីមួយឆ្នាំទៅមួយឆ្នាំ)** | 8.1 | 9.7 |
| **អតិផរណា (% បម្រែបម្រួល មធ្យមភាគ)** | 3.2 | 3.4 |
| **តុល្យភាពសារពើពន្ធរួម (% ផសស)** | -5.9 | -5.4 |
| **បំណុលរដ្ឋាភិបាល (% ផសស)** | 35.3 | 36.1 |
| **កំណើនការនាំចេញ** | 10.6 | 11.8 |
| **កំណើនការនាំចូល** | 9.2 | 10.0 |
| **គណនីចរន្ត (% ផសស)** | -9.4 | -9.2 |
| **វិនិយោគផ្ទាល់ពីបរទេស (% ផសស)** | 10.9 | 10.6 |
| **ទុនបម្រុងបរទេសសរុប (ចំនួនខែនៃការនាំចូលនាពេលអនាគត)** | 6.9 | 6.9 |

*ប្រភព៖* ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

**ស្ថានភាពនេះ ជាមួយនឹងកំណែទម្រង់រចនាសម្ព័ន្ធជាច្រើនដែលត្រូវបានរៀបចំឡើងជាចម្បងដើម្បីបង្កើនភាពប្រកួតប្រជែងខាងក្រៅប្រទេសរបស់កម្ពុជា អាចជួយជំរុញល្បឿនកំណើនក្នុងរយៈពេលវែង។** កំណែទម្រង់ថ្មីៗដើម្បីបង្កើនគុណភាព និងលទ្ធភាពទទួលបានការអប់រំជាមូលដ្ឋាន ក៏អាចបង្កើនលទ្ធផលសិក្សា និងបង្កើនគុណភាពកម្លាំងពលកម្មឲ្យកាន់តែល្អប្រសើរផងដែរ។ ការកាត់បន្ថយភាពក្រីក្រត្រូវបានរំពឹងថានឹងបន្តទៅមុខទៀតជាមួយនឹងការពង្រីកវិស័យសេវា និងកម្មន្តសាល។

**ស្ថានភាពសារពើពន្ធរបស់កម្ពុជា ត្រូវបានរំពឹងថានៅតែមាននិរន្តរភាព។** ឱនភាពសារពើពន្ធរួម និងបំណុលសាធារណៈ បើទោះជាកំពុងកើនឡើងដោយសារអាជ្ញាធរកម្ពុជាអនុវត្តគោលនយោបាយពង្រីកសារពើពន្ធ នឹងបន្តស្ថិតក្រោមការគ្រប់គ្រងបាន។

**ហានិភ័យចំពោះចក្ខុវិស័យនេះនៅតែមានទិសដៅឆ្ពោះទៅរកការថយចុះ។** នៅក្នុងស្រុក ហានិភ័យមានទំនាក់ទំនងជាមួយនឹងកំណើនរយៈពេលវែងផ្អែកសំណង់ ភាពមិនច្បាស់លាស់ដែលអាចទាក់ទងនឹងការបោះឆ្នោតសកលនាខែ កក្កដា ឆ្នាំ ២០១៨ និងការថយចុះភាពប្រកួតប្រជែងក្រៅប្រទេសដោយសារតែកំណើនប្រាក់ឈ្នួលពិត។ នៅក្រៅស្រុក ហានិភ័យមានទំនាក់ទំនងជាមួយនឹងពាណិជ្ជកម្មសកលលោកដែលមានភាពមិនប្រាកដប្រជាដោយសារគោលនយោបាយគាំពារនិយម មានការកើនឡើង។ លើសពីនេះទៀត ក្តីសង្ឃឹមក្នុងការទទួលបានកំណើនការងារហាក់ដូចជាមិនច្បាស់លាស់។ ដោយសារតែប្រាក់ឈ្នួលពិតបានកើនឡើងយ៉ាងឆាប់រហ័ស ភាពប្រកួតប្រជែងនៅក្រៅប្រទេសរបស់កម្ពុជាដែលពឹងផ្អែកជាចម្បងលើកម្លាំងពលកម្មថោក កំពុងបាត់បង់។ ជាលទ្ធផល ផលប៉ះពាល់អវិជ្ជមានដែលអាចមាននៃកំណើនយឺតក្នុងវិស័យកម្មន្តសាល និងសំណង់ ទៅលើការកាត់បន្ថយភាពក្រីក្រ អាចកើតមាន។

# ៣. អនុសាសន៍សំខាន់ៗ

**ការវិនិយោគលើការអភិវឌ្ឍធនធានមនុស្សជាការចាំបាច់ទាំងសម្រាប់ជំនាញដែលមានស្រាប់ និងជំនាញ “ថ្មី”។** ត្រង់ចំណុចនេះ ជោគជ័យនៃការអន្តរាគមន៍នៃគោលនយោបាយណាមួយអាចពឹងផ្អែក លើប្រសិទ្ធិភាពនៃការលើកទឹកចិត្ត និងដំណើរការនានា ដើម្បីសម្រួលដល់តួនាទីរបស់វិស័យសហគ្រាសក្នុងការផ្តល់ការណែនាំ និងជំរុញឲ្យមានប្រព័ន្ធអភិវឌ្ឍជំនាញដែលឆ្លើយតបទៅនឹងតម្រូវការរបស់ឧស្សាហកម្ម (សូមមើលផ្នែកស្តីពីការងារនាពេលអនាគតនៅកម្ពុជា)។ កំលាំងពលកម្មជំនាញដែលជួយជំរុញកំណើនផលិតភាព ជួយប៉ះប៉ូវចំពោះការតម្លើងប្រាក់ឈ្នួលពិត

១៦ កម្មវិធី “អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ” ផ្តល់លទ្ធភាពដល់ប្រទេសមានការអភិវឌ្ឍតិចបំផុត រួមទាំងកម្ពុជា ក្នុងការនាំចេញទំនិញគ្រប់យ៉ាង លើកលែងតែអាវុធ និងសព្វាវុធ ទៅកាន់សហភាពអឺរ៉ុបដោយមិនជាប់ពន្ធ។ មើល http://ec.europa.eu/trade/policy/countries-and-regions/countries/cambodia/។

ឆាប់រហ័ស និងគាំទ្រដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធដែលកំពុងមាន។ ដូច្នេះ ការដោះស្រាយឧបសគ្គផ្នែកជំនាញ ដូចដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០២៥ គឺជាការងារអាទិភាពមួយ។ ការសម្របសម្រួលល្អរវាងអង្គភាពសាធារណៈ និងឯកជន នឹងមានសារៈសំខាន់ចំពោះការអនុវត្តក្របខណ្ឌនេះដោយជោគជ័យ។

**ការដោះស្រាយបញ្ហាប្រឈមចំពោះអាជីវកម្មខ្នាតតូច និងមធ្យម និងសហគ្រាសតាមគ្រួសារមិនមែនកសិដ្ឋាន អាចគាំទ្រដល់ការធ្វើពិពិធកម្ម និងជំរុញកំណើនការងារ។** កិច្ចការចំបាច់គឺការកាត់បន្ថយថ្លៃដើម្បីធ្វើអោយសហគ្រាសមានលក្ខណៈផ្លូវការ ថ្លៃដំណើរការ និងថ្លៃហិរញ្ញប្បទានមានសារៈសំខាន់ រួមទាំងការផ្តល់ការលើកទឹកចិត្ត និង លទ្ធភាពទទួលបានកម្មវិធីគាំទ្រផ្សេងៗ។ ការណែនាំនូវការគាំទ្រផ្នែកគោលនយោបាយដើម្បីលើកកម្ពស់សហគ្រាសខ្នាតតូច និងមធ្យម និងសហគ្រាសគ្រួសារមិនមែនកសិដ្ឋាន នឹងជួយបង្កើតការងារ។ ដូច្នេះ ការគាំទ្រផ្នែកគោលនយោបាយដែលអាចមានអាចរួមទាំង ការអភិវឌ្ឍជំនាញ សម្រាប់ម្ចាស់ក្រុមហ៊ុន និងការអភិវឌ្ឍ ព្រមទាំងការទទួលបានបច្ចេកវិទ្យាឌីជីថល និងអ៊ិនធើណិត។ ការជំរុញការវិនិយោគក្នុងស្រុក រួមទាំងការកែច្នៃកសិផល ក៏អាចជួយពង្រឹងទំនាក់ទំនងទៅអាជីវកម្ម និងក្រុមហ៊ុននាំចេញរបស់ជនបរទេសផងដែរ។

**សន្ទុះរីកចម្រើននៃវិស័យសំណង់ និងអចលនទ្រព្យដែលកំពុងមានតម្រូវឲ្យមានការពិនិត្យឲ្យបានដិតដល់។** កំណើនឥណទានសម្រាប់វិស័យសំណង់ និងអចលនទ្រព្យ បានកើនឡើងថែមទៀតក្នុងរយៈពេល ប៉ុន្មានឆ្នាំចុងក្រោយនេះ។ ដូច្នេះ ជាការចាំបាច់ត្រូវកាត់បន្ថយសកម្មភាពប្រថុយប្រថាន។ នៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ជាការសំខាន់ត្រូវមានគោលការណ៍ណែនាំស្តីពីការផ្តល់ឥណទាន និងធានាឲ្យមានការពិនិត្យឱ្យបានគ្រប់គ្រាន់ នៅពេលពិនិត្យឡើងវិញទៅលើឥណទានមិនដំណើរការ រួមទាំងនិន្នាការថ្មីៗនៃការផ្តល់ហិរញ្ញប្បទានឡើងវិញ និងការផ្ទេរប្រាក់កម្ចី។ ការធ្វើបែបនេះក៏ជួយបញ្ចៀសការជំពាក់បំណុលច្រើនលើសលប់ ក្រោយការបង្កើនប្រាក់កម្ចីយ៉ាងលឿនជាច្រើនឆ្នាំ និងការបង្កើនលទ្ធភាពទទួលបានប្រាក់កម្ចីដល់គ្រួសារ។



# ផ្នែកទី ២ ៖ អត្ថបទជម្រើស ការងារនាពេលអនាគត នៅកម្ពុជា[១៧]

## ១.សេចក្តីផ្តើម

**កម្ពុជាអាចរក្សាកំណើនសេដ្ឋកិច្ចខ្ពស់របស់ខ្លួន ប៉ុន្តែកម្ពុជាកំពុងប្រឈមនឹងកំណើនការងារយឺត ជាពិសេសចាប់តាំងពីឆ្នាំ ២០១២ មក។** សេដ្ឋកិច្ចកម្ពុជាបានកើនឡើងក្នុងអត្រាមធ្យមប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ៗចំនួន ៥,៣ % នៅអំឡុងពីឆ្នាំ ២០០៥ ដល់ ២០១៥ ដែលធ្វើឲ្យកម្ពុជាស្ថិតក្នុងចំណោមប្រទេសមានសេដ្ឋកិច្ចឈានមុខទាំង ១៤ ក្នុងពិភពលោក និងក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ ២០១៥។ កម្ពុជាមានប្រជាជនសរុបចំនួន ១៦,១ លាននាក់ ហើយចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ ១.៣០០ ដុល្លារនៅឆ្នាំ២០១៧។ កម្ពុជានៅតែបន្តអនុវត្តគោលនយោបាយកំណើនខ្ពស់របស់ខ្លួន ដែលគាំទ្រដោយគោលនយោបាយវិនិយោគ និងពាណិជ្ជកម្មសេរី ដែលសំដៅសម្រេចបានអត្រាកំណើនពិតប្រមាណ៧% ក្នុងមួយឆ្នាំ។ នៅពេល ដែលការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចមានកាន់តែច្រើន ហើយសេដ្ឋកិច្ចកម្ពុជាបានផ្លាស់ពីវិស័យកសិកម្មឆ្ពោះទៅវិស័យឧស្សាហកម្ម និងសេវាកម្ម ដែលភាគច្រើនគឺជាការងារដែលមានតម្លៃបន្ថែម កម្រិតទាប។ ការងារថ្មីប្រមាណ ២ ភាគ ៣ ស្ថិតក្នុងវិស័យសំណង់ បដិសណ្ឋារកិច្ច និងសេវាផ្សេងៗ។ ដូច្នេះ គោលនយោបាយបច្ចុប្បន្នកំពុងបង្កើតការងារ ប៉ុន្តែមិនមែនការងារល្អៗដែលជួយជំរុញផលិតភាព និងការចម្រើនឡើយ។

**ការផ្លាស់ប្តូរទំរង់ពាណិជ្ជកម្ម កំណើនប្រជាជនវណ្ណៈកណ្តាលនៅអាស៊ី ការផ្លាស់ប្តូរប្រជាសាស្ត្រ បច្ចេកវិទ្យា និងនគរូបនីយកម្មយ៉ាងលឿន កំពុងផ្លាស់ប្តូរសមាសភាគ និងលក្ខណៈនៃការងារ។** បរិយាកាសភូមិសាស្ត្រនយោបាយសកលបច្ចុប្បន្នកំពុងមានឥទ្ធិពលទៅលើស្ថានភាពការងារនាពេលអនាគតនៅកម្ពុជា។ ដំណើរការសេដ្ឋកិច្ចសកលកំពុងបង្កើតតុល្យភាពឡើងវិញឆ្ពោះទៅអាស៊ី ទាំងផ្នែកផលិតកម្ម និងការប្រើប្រាស់។ កិច្ចខិតខំធ្វើសមាហរណកម្មក្នុងតំបន់ ដូចជា សហគមសេដ្ឋកិច្ចអាស៊ាន និងភាពជាដៃគូសេដ្ឋកិច្ចទូលាយក្នុងតំបន់ កំពុងបង្កើតសន្ទុះនៃសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញ និងសេវាដែលនឹងទាក់ទាញការវិនិយោគយ៉ាងច្រើនក្នុងតំបន់។ បច្ចេកវិទ្យាកំពុងបង្កើតឧស្សាហកម្មថ្មីៗ និងមិនទាន់គំរាមកំហែងដល់ឧស្សាហកម្មនាំចេញរបស់កម្ពុជាឡើយ។ ប្រជាជនវណ្ណៈកណ្តាលដែលកំពុងលេចឡើង ជាពិសេសក្នុងប្រទេសចិន នឹងបង្កើនតម្រូវការទំនិញកែច្នៃ និងសេវាកម្ម។ ចំណុចវិវត្តទាំងនេះនឹងផ្តល់ឱកាសឲ្យកម្ពុជាទាក់ទាញការវិនិយោគ ពង្រីកទីផ្សារនាំចេញរបស់ខ្លួនតាមរយៈទំនាក់ទំនងឧស្សាហកម្ម និងពាណិជ្ជកម្ម ព្រមទាំងការតភ្ជាប់ផ្នែករូបវន្ត និងស្ថាប័នរបស់កម្ពុជាទៅនឹងបណ្តាញផលិតកម្ម និងសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់។ និន្នាការធំៗទាំងនេះអាចបង្កើតការងារល្អៗ ប្រសិនបើកម្ពុជាកំណត់យក "ការងារ" ជាចំណុចអាទិភាពជាតិ។

---

១៧ បញ្ហាដែលត្រូវបានជ្រើសរើសស្តីពីការងារនាពេលអនាគតនៅកម្ពុជា គឺជាខ្លឹមសារសង្ខេបពីលទ្ធផលរកឃើញបឋមក្នុងការសិក្សាពីការងារនាពេលអនាគតនៅកម្ពុជាដែលដឹកនាំដោយ Drs. Wendy Cunningham និង Claire Honore Hollweg។ អ្នកចូលរួមចំណែកក្នុងការសិក្សានេះរួមមាន Sodeth Ly, Miguel Sanchez, Une Lee, Johanne Buba, Mahesh Shrestha, Marong Chea, Dilaka Lathapipat, Lan Van Nguyen និង Anne Lopez។

**ការកំណត់រកគោលនយោបាយ និងឱកាសសម្រាប់ភាពជោគជ័យនៃការងារនៅកម្ពុជាដើម្បីឲ្យស្របនឹងភាពជោគជ័យផ្នែកសេដ្ឋកិច្ច គឺជាការចាំបាច់។** គោលនយោបាយពាក់ព័ន្ធនឹងតម្រូវការ និងការផ្គត់ផ្គង់ សុទ្ធតែដើរតួនាទីជួយគ្នាទៅវិញទៅមក។ គោលនយោបាយពាក់ព័ន្ធនឹងតម្រូវការ ជំរុញកំណើនការងារដោយបង្កើនសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យដែលអាចនឹងផ្តល់ការងារល្អប្រសើរ។ គោលនយោបាយពាក់ព័ន្ធនឹងការផ្គត់ផ្គង់ ព្យាយាមបង្កើនការត្រៀមខ្លួនអ្នកដែលប្រឡូកក្នុងទីផ្សារការងារ និងជួយពួកគេឲ្យរកបានការងារត្រឹមត្រូវសម្រាប់កម្រិតជំនាញរបស់ខ្លួន (ប្រសិទ្ធភាពក្នុងការបែងចែក)។ គោលនយោបាយម៉ាក្រូគាំទ្រគោលនយោបាយទាំងនេះ តាមរយៈការបង្កើតលក្ខខណ្ឌសម្រាប់ឲ្យក្រុមហ៊ុន និងកម្មករនិយោជិត វិនិយោគ និងចូលរួមក្នុងទីផ្សារ និងធ្វើការជាមួយគ្នា។

**ដើម្បីជួយដល់អ្នកតាក់តែងគោលនយោបាយ ធនាគារពិភពលោកបានធ្វើការវិភាគការងារ ដើម្បីកំណត់គោលនយោបាយ និងឱកាសកែលម្អគុណភាព និងការចូលរួមការងារនៅក្នុងបរិបទនិន្នាការធំៗដែលកំពុងមាន។** ការសិក្សានេះមានគោលបំណងកំណត់កត្តាដែលជំរុញឲ្យមានការបង្កើតការងារល្អៗ និងកំណត់កម្រងគោលនយោបាយផ្សេងៗ ដែលជារួមនឹងជួយបង្កើតការងារល្អប្រសើរ។ ក្នុងគោលបំណងវិភាគនេះ ការងារត្រូវបានកំណត់ថាជាសកម្មភាពស្របច្បាប់ដែលបង្កើត (ប្រាក់ ឬវត្ថុ) ប្រាក់ចំណូល ចំណែកការងារល្អគឺជាការងារដែលមានផលិតភាព ផ្តល់តម្លៃបន្ថែមខ្ពស់ ផ្តល់ប្រាក់ ឈ្នួលច្រើន និងអត្ថប្រយោជន៍ការងារ និងលក្ខខណ្ឌការងារល្អប្រសើរ (ទៅដល់ប្រជាជនជាច្រើនក្នុងពេលវេលាសមស្រប)[១៨]។ ផ្នែកខាងក្រោមសង្ខេបពីអនុសាសន៍ថ្មីៗមួយចំនួន។

**របកគំហើញមួយក្នុងចំណោមរបកគំហើញដែលបានពិភាក្សាក្នុងការវិភាគការងារ លើកឡើងថា ត្រូវលើកកម្ពស់ការបង្កើត និងបង្កើនសហគ្រាសខ្នាតតូច និងមធ្យម** ដែលមានប្រមាណ ៩០% នៃក្រុមហ៊ុនសរុប។ ការធ្វើបែបនេះអាចលុបបំបាត់គម្លាតផលិតភាពរបស់កម្មករនិយោជិត ក៏ដូចជាការធ្វើឲ្យមានឥទ្ធិពលប្រយោល និងការផ្ទេរបច្ចេកវិទ្យា ដូចជា ជំនាញគ្រប់គ្រង និងជំនាញសហគ្រិនភាពពីវិស័យទំនើបទៅវិស័យការងារសាមញ្ញ។

**ការវិនិយោគដើម្បីអភិវឌ្ឍធនធានមនុស្ស គឺជាអាទិភាព។** ក្នុងន័យនេះ ជោគជ័យនៃអន្តរាគមន៍គោលនយោបាយណាមួយទំនងជាពឹងផ្អែកលើប្រសិទ្ធភាពនៃការលើកទឹកចិត្ត និងដំណើរការនានាដើម្បីសម្រួលដល់តួនាទីរបស់វិស័យសហគ្រាស ក្នុងការផ្តល់ការណែនាំ និងការជំរុញឲ្យមានប្រព័ន្ធអភិវឌ្ឍន៍ជំនាញដែលឆ្លើយតបទៅនឹងតម្រូវការរបស់វិស័យឧស្សាហកម្ម។ ដូច្នេះ ការអភិវឌ្ឍ និងលទ្ធភាពទទួលបានវគ្គអភិវឌ្ឍន៍ជំនាញលឿន និងឆាប់រហ័ស គឺជាការចាំបាច់។

# ២.ស្ថានភាពការងារបច្ចុប្បន្ន

## ក) ការផ្លាស់ប្តូររចនាសម្ព័ន្ធ

**ខុសពីបណ្តាប្រទេសដែលមានប្រជាជនអាយុចាស់នៅអាស៊ីបូព៌ា កម្ពុជាកំពុងទទួលបានអត្ថប្រយោជន៍ពីភាគលាភប្រជាសាស្ត្រ។** ប្រជាជនគ្រប់អាយុធ្វើការនៅកម្ពុជា (១៥-៦៤ ឆ្នាំ) កំពុងកើនឡើងលឿនជាងកំណើនប្រជាជនទូទៅ (២,៤% ធៀបនឹង ១,៩% នៅអំឡុងឆ្នាំ ២០០៧-២០១៥) ដោយបានផ្តល់ធនធានមនុស្សកាន់តែច្រើនសម្រាប់ការវិនិយោគ និងកំណើនប្រាក់ចំណូលគ្រួសារ។

ផ្អែកលើបម្រែបម្រួលប្រជាជនកន្លងមក កម្ពុជាមានឱកាសសម្រេចបានកំណើនសេដ្ឋកិច្ចយ៉ាងលឿននៅរយៈពេល ៣០ ឆ្នាំក្រោយ រហូតដល់អត្រាប្រជាជនគ្រប់អាយុធ្វើការថយចុះ (រូប ស ១)[១៩]។ ប្រជាជនគ្រប់អាយុធ្វើការនៅកម្ពុជាបានកើនឡើងដល់ ១០,១ លាននាក់នៅឆ្នាំ ២០១៥ ដោយកើនឡើងពី ៨,៣ លាននាក់នៅឆ្នាំ ២០០៧ ហើយនេះជាអត្រាកំណើនខ្ពស់ជាងកម្លាំងពលកម្ម

---

១៨ និយមន័យការងារ “ល្អ” នៅកម្ពុជានេះ ត្រូវបានប្រើប្រាស់សម្រាប់ការវិភាគក្នុងរបាយការណ៍នេះ។ និយមន័យការងារ “ល្អ” បែងចែករវាងកម្មករនិយោជិត និងក្រុមហ៊ុន និងតាមប្រភេទឧស្សាហកម្ម មុខរបរ តំបន់ និងចំណុចជាច្រើនទៀត។

១៩ បន្ទាប់ពីការស្តារឡើងវិញក្រោយរបបខ្មែរក្រហម ហើយ “កំណើនទារក” ការបង្កកំណើតបានចាប់ផ្តើមថយចុះនៅកម្ពុជាចាប់ពីដើមទសវត្សរ៍ឆ្នាំ ១៩៩០។ សូមមើលនិន្នាការបង្កកំណើតនៅកម្ពុជា Dasvarm និង Neupert (២០០២)។

សរុប (ប្រជាជនដែលកំពុងធ្វើការ ឬកំពុងស្វែងរកការងារ)[២០] ដែលកើនឡើង ១,៣ លាននាក់ក្នុងអំឡុងពេលដូចគ្នា។ ជាមធ្យម កម្ពុជាមានប្រជាជនគ្រប់អាយុធ្វើការថ្មីប្រហែល ១៦៤.០០០ នាក់/ឆ្នាំ។

**រូប ស១៖ ការព្យាករណ៍បម្រែបម្រួលប្រចាំឆ្នាំនៃចំនួនប្រជាជនគ្រប់អាយុធ្វើការ** (អាយុ ១៥-៦៤ឆ្នាំ)




*ប្រភព៖ ទស្សនវិស័យរបស់អង្គការសហប្រជាជាតិស្តីពីចំនួនប្រជាជនពិភពលោក-ការកែសម្រួលឆ្នាំ ២០១៥*

**ទន្ទឹមនឹងកំណើននៃការផ្លាស់ប្តូររចនាសម្ព័ន្ធ កម្ពុជាកំពុងប្រឈមនឹងការថយចុះយ៉ាងខ្លាំងនៃចំនួនប្រជាជនមានការងារធ្វើក្នុងវិស័យកសិកម្ម** (រូប ស២) ហើយការថយចុះខ្លាំងបំផុតកើតឡើងនៅឆ្នាំ ២០១២ (រូប ស ៣)។ ការបង្កើតការងារក្នុងវិស័យកសិកម្មតាមរដូវកាល កើនឡើងប្រមាណ ២,៨% នៅអំឡុងពីឆ្នាំ ២០០៧ ដល់ ២០១១ ដែលជំរុញដោយការអភិវឌ្ឍកសិកម្មដោយផ្អែកលើកំណើនថ្លៃទំនិញកសិកម្ម និងការពង្រីកផ្ទៃដីដាំដុះ។ នៅឆ្នាំ ២០០៩ វិស័យកសិកម្មអាចស្រូបយកកម្មកររោងចក្រជាច្រើនដែលបានបាត់បង់ការងារ ដោយសារការថមថយនៃវិស័យឧស្សាហកម្ម[២១] ព្រោះថាវិស័យសម្លៀកបំពាក់ និងស្បែកជើងប្រឈមនឹងបញ្ហានៅអំឡុងពេលកើតមានវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៨-២០០៩។ ប៉ុន្តែ នៅអំឡុងឆ្នាំ ២០១១-២០១៥ ការបង្កើតការងារក្នុងវិស័យកសិកម្មបានថយចុះមកត្រឹម ៥,៨% ក្នុងមួយឆ្នាំ ដោយសារគ្រោះរាំងស្ងួត និងការថយចុះនៃតម្លៃទំនិញកសិកម្ម។ ខណៈដែលវិស័យកសិកម្មចូលរួមចំណែកប្រមាណ ១ ភាគ ៤ នៃ ផសស រាល់ឆ្នាំ វិស័យនេះផ្តល់អត្រាការងារសរុប ៤១,៨%។

**រូប ស២៖ ការងារតាមវិស័យ** (គិតជាភាគរយ)




*ប្រភព៖ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា*

**រូប ស៣៖ ការរួមចំណែកក្នុងការបង្កើតការងារ** (គិតជាពាន់ការងារ)




*ប្រភព៖ ការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជា*

**ផ្ទុយទៅវិញ សេដ្ឋកិច្ចកម្ពុជាកាន់តែពឹងផ្អែកខ្លាំងលើវិស័យឧស្សាហកម្ម និងសេវា ទាំងសម្រាប់កំណើនសេដ្ឋកិច្ច និងការផ្តល់ការងារដើម្បីស្រូបយកប្រជាជនថ្មីៗដែលប្រឡូកក្នុងទីផ្សារការងារ។** ដូចការរៀបរាប់ក្នុងរូប ស ៣ វិស័យមិនមែនកសិកម្មគឺជាប្រភពកំណើនការងារដ៏សំខាន់តាំងពីឆ្នាំ ២០១២ ដែលគាំទ្រដោយកំណើនក្នុងវិស័យកម្មន្តសាល ទេសចរណ៍ និង (ថ្មីៗនេះ) វិស័យសំណង់។

**តាំងពីឆ្នាំ ២០១១ មក កម្លាំងពលកម្មបានដើរតួនាទីកាន់តែតិចក្នុងកំណើន ផសស។** ខណៈដែលមូលធននៅតែជាកម្លាំង

---

២០ និយមន័យនេះផ្អែកតាមការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាដែល “មនុស្សគ្រប់អាយុធ្វើការ” ត្រូវបានកំណត់ជាអ្នក (អាយុ ១៥ ឆ្នាំឡើងទៅ) ដែលធ្វើការរកប្រាក់ (ឬវត្ថុ) រយៈពេលយ៉ាងតិច ១ ម៉ោងក្នុងកំឡុង ១ សប្តាហ៍ មុនការអង្កេតនេះ ចំណែកអ្នកមានអាយុច្រើនជាង ១៥ ឆ្នាំ ដែលស្វែងរកការងារក្នុងរយៈពេលយ៉ាងតិច ១ ម៉ោងកាលពីសប្តាហ៍មុន (ប៉ុន្តែមិនមែនកំពុងឈប់សម្រាកបណ្តោះអាសន្ន) ត្រូវបានកំណត់ថាជា “មនុស្សកំពុងស្វែងរកការងារ”។

២១ នៅឆ្នាំ ២០០៩ កំណើនតម្លៃបន្ថែមរបស់វិស័យឧស្សាហកម្មមានដំណើរអវិជ្ជមាន ធៀបនឹងតម្លៃថេរ និងតម្លៃទីផ្សារ។

ចលករសម្រាប់កំណើនសេដ្ឋកិច្ច ការងារបានដើរតួនាទីយ៉ាងសំខាន់ (តាំងពីឆ្នាំ ១៩៩៣) រហូតដល់ឆ្នាំ ២០១១។ ផ្ទុយទៅវិញ គុណភាពកម្លាំងពលកម្ម និងកត្តាផលិតភាពសរុបបានកើនឡើងនៅអំឡុងឆ្នាំ ២០០៧-២០១១។ ស្ថានភាពនេះអាចដោយសារតែការងាកចេញពីវិស័យកសិកម្ម ដែលមានលក្ខណៈអតិពលកម្ម ទៅរកវិស័យកម្មន្តសាល និងសេវា ដែលផ្តោតចម្បងលើជំនាញ និងផលិតភាព។

**នៅពេលអនាគត កត្តាដែលបង្កើតការងារយ៉ាងច្រើននៅកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក អាចមិនមែនជាកត្តាដែលនឹងជំរុញកំណើនការងារដែលមានគុណភាពនៅថ្ងៃអនាគតឡើយ។** និន្នាការធំៗថ្មីៗ ដែលរួមមាន ការបង្កើតតុល្យភាពសេដ្ឋកិច្ចសកលឡើងវិញឆ្ពោះទៅរកតំបន់អាស៊ី រួមទាំង សមាហរណកម្មក្នុងតំបន់ និងកំណើនទ្រព្យសម្បត្តិ ការងាកទៅរកផលិតកម្មឆ្លាតវ័យ និងសង្វាក់តម្លៃ និងក្រុមហ៊ុន និងកម្មករនិយោជិតថ្មីៗដែលមានផលិតផល និងជំនាញថ្មីៗ នឹងកែប្រែ ទិដ្ឋភាពការងារនៅកម្ពុជា។

## ខ) ទិដ្ឋភាពការងារ

**ទិដ្ឋភាពការងារនៅកម្ពុជាមានលក្ខណៈចម្រុះ។** ការងារពាក់កណ្តាលស្ថិតក្នុងវិស័យដែលមាន ភាពសាមញ្ញ ចំណែកការងារពាក់កណ្តាលទៀតជាវិស័យទំនើប (រូប ស ៤)។ វិស័យសាមញ្ញគ្របដណ្តប់លើការងារយ៉ាងហោចណាស់ចំនួន ៤,២ លានក្នុងកសិកម្មគ្រួសារ (១ ភាគ ៣ នៃការងារទាំងអស់) និងសហគ្រាសគ្រួសារមិនមែនកសិដ្ឋាន (១៨%)។ ប្រជាជន ៣,៣ លាននាក់ផ្សេងទៀតចូលរួមក្នុងការងារទទួលបានប្រាក់ឈ្នួល។ ប្រជាជន ១ ភាគ ៣ ក្នុងចំណោមនេះ (១ លាននាក់) ធ្វើការក្នុងក្រុមហ៊ុនបរទេសដែលភាគច្រើនគោរពតាមច្បាប់ការងារ និងមានកម្រិតផលិតភាពខ្ពស់ជាងក្រុមហ៊ុនក្នុងស្រុក និងអាចចាត់ចំណាត់ថ្នាក់ជាការងារ “ល្អ”។ ប៉ុន្តែគ្មានព័ត៌មានស្តីពីគុណភាពរបស់ការងារទទួលបានប្រាក់ឈ្នួលចំនួន ២,២៦ លានផ្សេងទៀតឡើយ។ ប្រជាជនមួយចំនួនអាចកំពុងធ្វើការក្នុងក្រុមហ៊ុនចុះបញ្ជី និងទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍តាមការកំណត់ ខណៈដែលអ្នកផ្សេងទៀតគឺជាអ្នកធ្វើការយកប្រាក់ឈ្នួលតាមកសិដ្ឋាន សហគ្រាសគ្រួសារ ឬគ្មានកិច្ចសន្យាការងារ។ នៅឆ្នាំ ២០១៥ ប្រាក់ចំណូលគ្រួសារនៅកម្ពុជាប្រហែល ៥០% ទទួលបានពីប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល ធៀបនឹងអត្រាត្រឹមតែ ៣០% កាលពីមួយទសវត្សរ៍មុន (រូប ស ៥)។

**រូប ស៤៖ ទិដ្ឋភាពការងារជាទូទៅនៅកម្ពុជា**




*ប្រភព៖* ការគណនារបស់អ្នកនិពន្ធ

**រូប ស៥៖ កំណើនចំណែកការងារទទួលបានប្រាក់ឈ្នួល និងប្រាក់បៀវត្សរ៍** (គិតជាភាគរយនៃការងារសរុប)




*ប្រភព៖* ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា

**ការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យឯកជន ដូចជា វិស័យសម្លៀកបំពាក់ និងស្បែកជើង បាន និងកំពុងជំរុញកំណើនពីការនាំចេញរបស់កម្ពុជា។** នៅឆ្នាំ ២០១៥ វិស័យសម្លៀកបំពាក់ និងស្បែកជើងបានរួមចំណែក ១០,៦% នៃ ផសស និង ៧,៣% នៃការងារសរុប។ ចំណុចនេះគឺផ្ទុយពីឧស្សាហកម្មដែលប្រើទុនក្នុងស្រុកដែលមានកំណើនលឿនបំផុត ដូចជា វិស័យសំណង់ដែលរួមចំណែក ៩,៨% នៃ ផសស ប៉ុន្តែ រួមចំណែកតែ ៦,៥% នៃការងារសរុបប៉ុណ្ណោះ។

**ដើម្បីធ្វើឲ្យគោលនយោបាយស្តីពីការងារស្របទៅនឹងគោលនយោបាយស្តីពីកំណើន ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើវិស័យឯកជនក្នុងស្រុក និងបរទេស។** ការជំរុញកំណើនការងារក្នុង

វិស័យឯកជន ជាពិសេសវិស័យឯកជនក្នុងស្រុក ដូចជា សហគ្រាស ខ្នាតតូច និងមធ្យម នឹងជួយស្រូបយកកម្មករនិយោជិតចេញពី វិស័យសាមញ្ញ គឺកសិកម្មគ្រួសារ (កម្មករជំនាញក្នុងផ្នែកកសិកម្ម ព្រៃឈើ និងនេសាទ)។ ដូចគ្នានេះដែរ ត្រូវលើកកម្ពស់សហគ្រាស គ្រួសារមិនមែនកសិដ្ឋានដែលនៅតែផ្ដល់ ការងារយ៉ាងច្រើន ប៉ុន្តែ មិនទាន់សម្រេច សក្ដានុពលនៅឡើយទេ។

## គ) ការចូលរួមរបស់កម្លាំងពលកម្ម

អត្រាចូលរួមកម្លាំងពលកម្មរបស់កម្ពុជាមានកម្រិតខ្ពស់ធៀប នឹងស្តង់ដារសកល។ ដោយសារកម្រិតនៃការអភិវឌ្ឍនៅកម្ពុជា អត្រាចូលរួមកម្លាំងពលកម្មត្រូវបានរំពឹងថានឹងស្ថិតលើបន្ទាត់ និន្នាការ ក្នុងរូប ស ៦។ ផ្ទុយទៅវិញ និន្នាការជាក់ស្តែងនៅខ្ពស់ ឆ្ងាយពីបន្ទាត់និន្នាការក្នុងរយៈពេលជាច្រើនឆ្នាំ។ ចំណុចនេះឆ្លុះ បញ្ចាំងពីការចូលរួមខ្ពស់របស់ស្ត្រីក្នុងកម្លាំងពលកម្ម ទាំងក្នុងវិស័យ ទំនើប និងវិស័យសាមញ្ញ ជាពិសេសវិស័យសម្លៀកបំពាក់ និងស្បែក ជើង និងសហគ្រាសគ្រួសារមិនមែនកសិដ្ឋាន។ អត្រាចូលរួមរបស់ ស្ត្រីក្នុងកម្លាំងពលកម្មនៅកម្ពុជា ស្ថិតក្នុងចំណោមអត្រាខ្ពស់បំផុត ក្នុងតំបន់ និងពិភពលោក (រូប ស ៧)។ និន្នាការនេះប្រហែលជា រឿងធម្មតា ដោយសារតែសារៈសំខាន់នៃឧស្សាហកម្មសាមញ្ញ "ដែល មានស្ត្រីច្រើន" ក្នុងសេដ្ឋកិច្ចកម្ពុជា (វិស័យសម្លៀកបំពាក់ និង ទេសចរណ៍)។

**រូប ស៦៖ កម្ពុជាមានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ជាង ប្រទេសជិតខាង**




*ប្រភព៖* ការប៉ាន់ស្មានរបស់អ្នកនិពន្ធដោយប្រើប្រាស់ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០០៧-១៥ និងសូចនាករអភិវឌ្ឍន៍ពិភពលោក

**រូប ស៧៖ អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្ត្រី** (ភាគរយ ស្ត្រីដែលមានអាយុ ១៥ ឆ្នាំឡើង)




*ប្រភព៖* សូចនាករអភិវឌ្ឍន៍ពិភពលោក

**តារាង ស ១ ៖ ការងារតាមមុខរបរសំខាន់ៗ** (គិតជាភាគរយ)

| មុខរបរសំខាន់ៗ | 2004 | 2015 |
|---|---|---|
| កងកម្លាំងប្រដាប់អាវុធ | 0.9 | 0.8 |
| ប្រធានគ្រប់គ្រង | 1.3 | 0.9 |
| អ្នកជំនាញ | 3.8 | 3.2 |
| អ្នកបច្ចេកទេស និងអ្នកជំនាញកម្រិតទីពីរ | 0.6 | 1.3 |
| បុគ្គលិកជំនួយការ | 0.2 | 3.6 |
| បុគ្គលិកផ្នែកសេវា និងលក់ | 13.6 | 16.1 |
| បុគ្គលិកជំនាញផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 58.7 | 33.7 |
| សិប្បករ និងកម្មករពាក់ព័ន្ធ | 6.1 | 23.5 |
| ការីម៉ាស៊ីន និងរោងចក្រ និងជាងផ្គុំតម្លើង | 6.1 | 3.9 |
| មុខរបរធម្មតា | 8.4 | 12.9 |
| | 100 | 100 |

*ប្រភព៖* ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា

**ទីផ្សារការងារមានការវិវត្តិយ៉ាងខ្លាំងក្នុងរយៈពេល ១០ ឆ្នាំកន្លងមក ភាគច្រើនគឺដោយសារការផ្លាស់ប្តូររចនាសម្ព័ន្ធ** (តារាង ស ១)។ ខណៈដែលអត្រាអ្នកធ្វើការ ស្ថិតក្នុងវិស័យកសិកម្ម ព្រៃឈើ និងនេសាទមាន៥៨,៧% នៅឆ្នាំ ២០០៤ អត្រានេះបានធ្លាក់មកត្រឹម ៣៣,៧% នៅឆ្នាំ ២០១៥។ ទោះបីជាកម្លាំងពលកម្មនៅក្នុងវិស័យនេះនៅតែជាចំណែកភាគច្រើនបំផុតក្តី ប៉ុន្តែកម្លាំងនេះ កំពុងមាននិន្នាការថយចុះ។ ទន្ទឹមនឹងនេះ ការផ្លាស់ប្តូរឆ្ពោះទៅរកវិស័យកាន់តែមានផលិតភាព បានធ្វើឲ្យមានចំណែកការងាររបស់កម្មករនិយោជិតក្នុងវិស័យសេវា លក់ និងផ្នែកជំនួយការ មានទំហំធំជាងមុន។ ការឆ្ពោះទៅរកឧស្សាហូបនីយកម្ម ធ្វើឲ្យមានតម្រូវការអ្នកជំនាញ និងអ្នកជំនាញកម្រិតទីពីរ មានកាន់តែច្រើន។ ទិន្នន័យបែងចែកតាមការងារផ្សេងៗបង្ហាញថា ការងារដែលមានកំណើនលឿនបំផុតចំនួន ៣ រួមមាន សម្លៀកបំពាក់ និងរបរពាក់ព័ន្ធ ការតម្លើងស៊ុម និងរបរពាក់ព័ន្ធ និងជំនួយការការិយាល័យទូទៅ (តារាង ស២) ខណៈដែលការងារ ៨ ក្នុងចំណោមការងារ ១០ ដែលមានការថយចុះលឿនបំផុត រួមមាន កសិកម្ម ព្រៃឈើ ឬនេសាទ។

**តារាង ស ២ ៖ មុខរបរ ១០ ដែលមានកំណើនលឿនបំផុត**

| | ចំណែកឆ្នាំ ២០០៩ | ចំណែក ឆ្នាំ២០១៤ | កំណើន មធ្យម |
|---|---|---|---|
| កម្មករកាត់ដេរ និងកម្មករក្នុងពាណិជ្ជកម្មពាក់ព័ន្ធ | 4.4 | 10.2 | 1.1 |
| កម្មករសាងសង់គ្រោងអាគារ និងកម្មករក្នុងពាណិជ្ជកម្មពាក់ព័ន្ធ | 0.5 | 2.8 | 0.7 |
| ជំនួយការទូទៅតាមការិយាល័យ | 0.8 | 2.6 | 0.3 |
| កម្មករផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 6.3 | 6.9 | 0.2 |
| បុគ្គលិកលក់តាមហាង | 5.0 | 6.0 | 0.1 |
| អ្នករត់តុ និងលាយស្រា | 0.3 | 0.80 | 0.1 |
| កម្មករសាងសង់អគារបញ្ចប់ និងកម្មករក្នុងពាណិជ្ជកម្មពាក់ព័ន្ធ | 0.2 | 0.8 | 0.1 |
| អ្នកគិតប្រាក់ អ្នកប្រមូលប្រាក់ និងជំនួយការពាក់ព័ន្ធ | 0.2 | 0.7 | 0.1 |
| អ្នកសម្អាតសណ្ឋាគារ និងការិយាល័យ និងអ្នកជំនួយការផ្សេងៗ អ្នកថែទាំអាគារ | 0.1 | 0.3 | 0.1 |
| អ្នករត់ម៉ូតូឌុប និងអ្នករត់ឡឺម៉ក | 1.2 | 1.5 | 0.1 |

*ប្រភព៖* ការប៉ាន់ស្មានរបស់អ្នកនិពន្ធដោយប្រើប្រាស់ទិន្នន័យស្តីពីការអង្កេតសេដ្ឋកិច្ចសង្គម ឆ្នាំ ២០០៩-២០១៥
*សម្គាល់៖* មុខរបរទាំងឡាយស្ថិតក្នុង ISCO ៣ ខ្ទង់ ដែលមានចំណែកការងារយ៉ោងហោចណាស់ ០,១ %

**ទោះជាយ៉ាងនេះក្តី ការធ្វើឲ្យប្រសើរឡើងនូវគុណភាពការងាររបស់កម្មករ នៅតែជាសេចក្តីត្រូវការចាំបាច់ជាបន្ត។** កំណើនផលិតភាពការងារដែលមានកំណើនលឿនបំផុត ដូចជា សម្លៀកបំពាក់ និងរបរពាក់ព័ន្ធ ស្ថិតក្នុងចំណោមការងារដែលមានកំណើនទាបបំផុត (រូប ស ៨)។ ផលិតភាពមានកម្រិតខ្ពស់បំផុតក្នុងការងារក្នុងវិស័យអចលនទ្រព្យ និងជំនួញ ដោយសារសន្ទុះកំណើនវិស័យអចលនទ្រព្យ ហើយពាណិជ្ជកម្ម និងកសិកម្ម មានផលិតភាពកម្រិតខ្ពស់បន្ទាប់ពីប្រភេទការងារទាំងនោះ។ សម្រាប់កម្មករនិយោជិត ទោះបីជាប្រាក់ឈ្នួលជាមធ្យមកើនឡើងក្តី (ជាពិសេសសម្រាប់ប្រជាជនក្រីក្រ) ក៏នៅតែមានបញ្ហាប្រឈមផ្សេងៗទៀត ឧទាហរណ៍ នៅតែមានគម្លាតយេនឌ័រយ៉ាងធំចំពោះប្រាក់ឈ្នួលគិតតាមម៉ោង (រូប ស៩)។ បើទោះជាត្រូវមានការសិក្សាបន្ថែមទៀតដើម្បីប្រាប់ពីគម្លាតដ៏ធំនៃប្រាក់ឈ្នួលរវាងបុរស និងស្ត្រីនេះ កម្រិតអប់រំអាចជាកត្តាជះឥទ្ធិពលមួយធ្វើឲ្យមានបញ្ហានេះ។

**រូប ស៨៖ កំណើនផលិតភាពប្រចាំឆ្នាំ (២០០៧-២០១៤) សម្រាប់វិស័យសំខាន់ៗនៅតែមានកម្រិតទាប។**




*ប្រភព៖* ការប៉ាន់ស្មានរបស់អ្នកនិពន្ធដោយប្រើប្រាស់ទិន្នន័យពីអាជ្ញាធរកម្ពុជា

### រូប ស៩៖ គម្លាតយេនឌ័រសម្រាប់ប្រាក់ឈ្នួលគិតតាមម៉ោង




*ប្រភព៖* ការប៉ាន់ស្មានរបស់អ្នកនិពន្ធដោយប្រើប្រាស់ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា

**លទ្ធផលនៃការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាបង្ហាញថា អត្រាកាន់តែខ្ពស់របស់ស្ត្រីក្នុងកម្លាំងពលកម្ម (១៥-៦៤ ឆ្នាំ) "គ្មាន ឬមានកម្រិតអប់រំទាប" ធៀបនឹងបុរស** (រូប ស ១០)។ នៅឆ្នាំ ២០១៥ ១៧% នៃស្ត្រីដែលចូលរួមក្នុងកម្លាំងពលកម្ម "គ្មាន ឬមានកម្រិតអប់រំទាប" ហើយស្ត្រី ៣៤,៩% "មិនបានបញ្ចប់ថ្នាក់បឋមសិក្សា" ខណៈដែលអត្រានេះមានប្រមាណតែ ១០,៣% និង ៣០,២% សម្រាប់បុរស។ ភាពខុសគ្នានេះលេចឡើងយ៉ាងច្បាស់នៅពេលកម្រិតអប់រំឈានដល់"ការបញ្ចប់ថ្នាក់បឋមសិក្សា" និង"អនុវិទ្យាល័យ"។ អត្រាកម្លាំងពលកម្មជាបុរស ដែលមានកម្រិតអប់រំ "បញ្ចប់ថ្នាក់បឋមសិក្សា" និង "អនុវិទ្យាល័យ" មានប្រមាណ ២៨,២% និង ១៦,៣% ធៀបនឹងអត្រា ២៧,៣% និង ១១,៦% សម្រាប់ស្ត្រី។ ចំណុចនេះឆ្លុះបញ្ចាំងពីចំនួនតិចនៃសិស្សស្រីដែលបញ្ចប់ថ្នាក់បឋមសិក្សាឡើងទៅ ធៀបនឹងសិស្សប្រុស។

### រូប ស១០៖ អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ (១៥-៦៤ ឆ្នាំ) កម្រិតអប់រំ និងភេទ (គិតជាភាគរយ ឆ្នាំ២០១៥)




*ប្រភព៖* ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ ២០១៥

# ៣.ការងារនៅពេលអនាគត

## ក) ឱកាស និងឧបសគ្គ

**ដូចបានពិភាក្សាខាងលើ តម្រូវការការងារ ដូចជា កម្មករនិយោជិតជំនាញក្នុងផ្នែកកសិកម្ម ព្រៃឈើ និងនេសាទ ដែលមានអត្រាច្រើនលើសលប់កាលពីមួយទសវត្សរ៍មុន និងជាកត្តាចម្បងដែលជំរុញកំណើនការងារយ៉ាងច្រើននៅកម្ពុជា ជាពិសេសនៅពេលតម្លៃទំនិញកសិកម្មកើនឡើង ប្រហែលមិនទំនងនៅជាការងារដែលនឹងជំរុញកំណើនការងារទៅថ្ងៃអនាគតទៀតឡើយ។** បរិយាកាសម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការផ្លាស់ប្តូររចនាសម្ព័ន្ធជាបន្តបន្ទាប់ បង្កផលវិបាកលើលក្ខណៈនៃការងារនៅកម្ពុជា។ ចំណាត់ថ្នាក់ជាប្រទេសមានប្រាក់ចំណូលមធ្យមខ្ពស់ដែលកម្ពុជាចង់សម្រេចបាននៅរយៈពេល ១២-១៥ ឆ្នាំក្រោយ អាចកាត់បន្ថយចំណែកការងារក្នុងវិស័យកសិកម្មថែមទៀតមកត្រឹម ២០% ដែលថយចុះពីអត្រា ៤០% បច្ចុប្បន្ន[២២]។ ដូច្នេះ បញ្ហាប្រឈមគឺការកំណត់ប្រភពការងារថ្មីៗ។

**ការងារក្នុងវិស័យសម្លៀកបំពាក់ និងរបរពាក់ព័ន្ធ (វិស័យដែលផ្តល់ការងារច្រើនបំផុត) ត្រូវបានរំពឹងថានឹងបន្តកើនឡើងក្នុងសង្វាក់តម្លៃតំបន់ និងសកល។** ទោះបីជាប្រាក់ឈ្នួលអប្បបរមាកំពុងកើនឡើងយ៉ាងលឿន ហើយថ្លៃឈ្នួលកម្លាំងពលកម្មគិតជាបរិមាណផលិតផលសម្រាប់កម្មករម្នាក់ៗ មានកម្រិតខ្ពស់ជាងប្រទេសប្រកួតប្រជែងដែលមានឧស្សាហកម្មដូចគ្នាក្តី ក៏ការងារនេះនឹងនៅតែបន្តកើនឡើងក្នុងរយៈពេលជាច្រើនឆ្នាំទៀត ដោយសារតែកម្ពុជាទទួលបានការអនុគ្រោះពន្ធក្នុងទីផ្សារសហភាពអឺរ៉ុបក្រោមកម្មវិធី "អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ" (រូប ស ១១)។ ក្រៅពីនេះ កំណើនប្រាក់ឈ្នួលនៅចិន ការរើរោងចក្រពីចិនទៅកាន់ប្រទេសយកប្រាក់ឈ្នួលទាប នឹងផ្តល់ឱកាសឲ្យកម្ពុជាទាក់ទាញឧស្សាហកម្មថ្មីៗ និងពង្រីក/កែលម្អឧស្សាហកម្មដែលមានស្រាប់។ កត្តាទាំងនេះធ្វើឲ្យមានកំណើនតម្រូវការកម្លាំងពលកម្មជំនាញ ដូចជា អ្នកបច្ចេកទេស និងការីម៉ាស៊ីន និងជាង ផ្គុំតម្លើង។

---

២២ ការប្រែប្រួលលក្ខណៈការងារ (២០១៩) របាយការណ៍អភិវឌ្ឍន៍ពិភពលោក។

**រូប ស១១៖ ការនាំចេញសំលៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌផ្សេងទៀត** (បម្រែបម្រួលធៀបនឹងឆ្នាំមុន គិតជាភាគរយ)




*ប្រភព៖* អាជ្ញាធរកម្ពុជា

**ការផ្លាស់ប្តូរទម្រង់ពាណិជ្ជកម្ម ដែលចិននឹងក្លាយទៅជាទីផ្សារអ្នកប្រើប្រាស់ដ៏សំខាន់ក្នុងពិភពលោក** ធ្វើឲ្យមានតម្រូវការនាំចូលទំនិញ និងសេវា។ កម្ពុជាព្រមទាំងប្រទេសក្នុងតំបន់កំពុងប្រកួតប្រជែងគ្នាទាក់ទាញភ្ញៀវទេសចរណ៍ចិន។ កំណើនតម្រូវការរបស់អ្នកចូលនិវត្តន៍នៅអាស៊ី និងអឺរ៉ុបពាក់ព័ន្ធនឹងដំណើរទេសចរណ៍តាមតម្រូវការ និងសកម្មភាពពាក់ព័ន្ធផ្សេងៗ គឺជាឱកាសថ្មីមួយទៀត។ ដូចគ្នានេះដែរ ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ និងការរិចរឹលបរិស្ថាន នឹងបង្កើនតម្រូវការអេកូទេសចរណ៍ (សក្តានុពលទេសចរណ៍ដែលមិនទាន់ទាញយកផលនៅកម្ពុជា)។ ដើម្បីជួយដល់ប្រទេសមានប្រជាជនចំណាស់ជាច្រើនក្នុងតំបន់ ដូចជា កូរ៉េ សិង្ហបុរី និងអូស្ត្រាលី ការថែទាំមនុស្សត្រូវបានរំពឹងថានឹងក្លាយជាការងារដ៏សំខាន់ដែលកម្ពុជាអាចចាប់យក ដោយសារកម្ពុជាមានឧត្តមភាពប្រកួតប្រជែងលើផ្នែកជំនាញភាសាអង់គ្លេស។ ប៉ុន្តែ មាននិន្នាការថ្មីៗដែលអាចបង្កផលប៉ះពាល់អវិជ្ជមានលើការងារ ដូចជា កំណើនទាបនៃពាណិជ្ជកម្មសកល និងកំណើនការអនុវត្តការគាំពារនិយមនៅសហរដ្ឋអាមេរិក និងប្រទេសផ្សេងៗទៀត។

**កត្តាផ្សេងៗទៀត ដូចជា ការដែលកម្ពុជា និងប្រទេសអាស៊ីប៉ូព៌ាផ្សេងទៀតមានជីវភាពធូរធារជាងមុន និងការផ្លាស់ប្តូរទម្រង់ពាណិជ្ជកម្ម បានធ្វើឲ្យមានកំណើនការងារផ្សេងទៀត** (រូប ស ១២)។ ដូចរៀបរាប់ក្នុងតារាង ស ១ និង ស ២ ការងារពាក់ព័ន្ធនឹងសេវា ដូចជា ការងារជំនាញទំនាក់ទំនង គឺភ្នាក់ងារលក់ក្នុងហាង ជំនួយការការិយាល័យ បុគ្គលិកសណ្ឋាគារ/ការិយាល័យ និងការងារជាច្រើនទៀត កំពុងមានសន្ទុះកើនឡើង។ នៅពេលប្រាក់ចំណូលកើនឡើង អ្នកប្រើប្រាស់ស្វែងរកសេវាកំសាន្ត និងសេវាផ្ទាល់ខ្លួនកាន់តែច្រើន ឬប្រើប្រាស់ផលិតផលកែច្នៃ និងផលិតផលផ្តល់សេវាកាន់តែច្រើន ខណៈដែលអ្នកផលិតខិតខំស្វែងរកធនធានជំនាញ និងឯកទេស និងប្រឹក្សាលក្ខណៈអាជីព[២៣]។ សេដ្ឋកិច្ចតំបន់បានបង្ហាញពីការរួមចំណែកកាន់តែច្រើនរបស់វិស័យសេវា ដែលស្មើនឹង ៥០% នៃ ផសស សរុប និង ៦០% នៃលំហូរវិនិយោគផ្ទាល់ពីបរទេសសរុបក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។

**រូប ស១២៖ កត្តាជំរុញកំណើនការងារថ្មីៗ**




*ប្រភព៖* ការវាយតម្លៃរបស់អ្នកនិពន្ធ

**ការយល់ដឹងកាន់តែច្រើនស្តីពីសេដ្ឋកិច្ច និងការអភិវឌ្ឍនៃបច្ចេកវិទ្យាឌីជីថល ដូចជា បណ្តាញអ៊ីនធើណិត នឹងផ្តល់ការងារថ្មីៗ និងផ្លាស់ប្តូរលក្ខណៈការងារក្នុងវិស័យផ្សេងៗ។** ផ្អែកលើនិន្នាការបច្ចេកវិទ្យាបច្ចុប្បន្ន វិស័យមួយចំនួននឹងនៅតែបន្តពឹងផ្អែកលើកម្លាំងពលកម្មជាកត្តាផលិតកម្មចម្បង។ ក្នុងវិស័យទាំងនោះ កំណើនតាមវិស័យនឹងធ្វើឲ្យមានកំណើនការងារ[២៤]។ ប៉ុន្តែ ភាគច្រើននៃការងារទាំងនេះ គឺការងារនៅកម្ពុជា នឹងមានបច្ចេកវិទ្យាកាន់តែច្រើនទៅក្នុងការងាររបស់ខ្លួន។ ដូច្នេះ កិច្ចការដែលអាចធ្វើដោយដៃនឹងត្រូវជំនួសដោយម៉ាស៊ីន ដែលធ្វើឲ្យកម្មករនិយោជិតមានពេលវេលាកាន់តែច្រើនក្នុងការបំពេញកិច្ចការដែលមានតម្លៃបន្ថែមកាន់តែខ្ពស់ដែលម៉ាស៊ីនមិនអាចជួយបាន។ ឧ. ម៉ាស៊ីន ATM ដែលផ្តល់ពេលទំនេរឲ្យអ្នកធ្វើការនៅធនាគាមានពេលធ្វើការជាមួយអតិថិជន កុំព្យូទ័រដែលអាចឲ្យគណនេយ្យករធ្វើការកាន់តែច្បាស់លាស់ និងមានប្រសិទ្ធភាព ឬការប្រើប្រាស់ PassApp ដើម្បីហៅតាក់ស៊ីជាជាងតាក់ស៊ីបើកឆ្វែលទៅមករកអ្នកដំណើរ (មើលប្រអប់ ស ១៖ តាក់ស៊ី PassApp ផ្តល់ដំណោះស្រាយឈ្នះ-ឈ្នះសម្រាប់អ្នកបើកតាក់ស៊ី និងអតិថិជនរបស់ខ្លួន)។ ការងារដែលបង្កើតបច្ចេកវិទ្យា ដូចជា អាជីពបង្កើត app ក្នុងទូរស័ព្ទចល័ត នឹងកើនឡើង ប៉ុន្តែការងារទាំងនេះនឹងមានចំណែកតិចតួចក្នុងបរិបទទីផ្សារការងារធំទូលាយ។ ក្រៅពីនេះ បច្ចេកវិទ្យាកំពុងដោះស្រាយឧបសគ្គថ្មីៗលើការបង្កើត

២៣ របាយការណ៍សមាហរណកម្មសេវាអាស៊ាន (២០១៥) របាយការណ៍រួមរបស់លេខាធិការដ្ឋានអាស៊ាន និងធនាគារពិភពលោក។
២៤ ការប្រែប្រួលលក្ខណៈការងារ (២០១៩) របាយការណ៍អភិវឌ្ឍន៍ពិភពលោក។

ការងារ។ ឧ. ការពង្រីកប្រព័ន្ធសាច់ប្រាក់ចល័តដែលកម្ពុជាបានអនុវត្តកាលពីប៉ុន្មានឆ្នាំមុន មិនត្រឹមតែជួយបង្កើតការងារប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងសម្រួលការផ្ញើប្រាក់ បង្កើនលទ្ធភាពទទួលបានឥណទាន និងបង្កើនផលិតភាព ក៏ដូចជាសហគ្រិនភាពទៀតផង។

**បើទោះជាមិនមែនជាការគំរាមកំហែងភ្លាមៗសម្រាប់កម្ពុជា ការងារមួយចំនួននឹងលែងមានតទៅទៀតដោយសារស្វ័យប្រវត្តិកម្ម។** ការងារផ្សេងទៀតនឹងមិនត្រូវបានបង្កើតឡើងឡើយ ដោយសារការរើទីតាំងរោងចក្រកម្មន្តសាលទៅកាន់ប្រទេសជឿនលឿន និងចិនវិញ ដែលជំរុញដោយកំណើនបច្ចេកវិទ្យាកាន់តែទំនើប ដូចជា ឧបករណ៍យន្តទំនើប ការបំពាក់អ៊ីនធើណិតលើអ្វីគ្រប់យ៉ាង ការព្រីន 3-D។ល។ ឧ. ការប្រើប្រាស់សេវាអនឡាញសម្រាប់សេវាធនាគារចល័ត ការកក់ និងការរៀបចំដំណើរទេសចរណ៍ផ្សេងទៀត ក៏ដូចជាការទទួលបានសេវាសាធារណៈដែលសម្រួលដោយ រដ្ឋាភិបាលអេឡិចត្រូនិក បង្កផលប៉ះពាល់អវិជ្ជមានលើការងារប្រើជំនាញមធ្យម និងតាមទម្លាប់ ដូចជា អ្នកបើក ឬទទួលប្រាក់នៅធនាគារ និងការងារជំនួយការងារ។ កំណើនប្រាក់ឈ្នួលនឹងបង្កើនល្បឿនស្វ័យប្រវត្តិកម្មហើយកម្មករនៅកម្ពុជានឹងត្រូវមានការបណ្តុះបណ្តាល ឬការបណ្តុះបណ្តាលឡើងវិញលើជំនាញរបស់ខ្លួន ដើម្បីឲ្យស្របទៅនឹងកំណើនការងារថ្មី។

**ទន្ទឹមនឹងនេះ វឌ្ឍនភាពបច្ចេកវិទ្យានឹងបង្កើតការងារថ្មីៗជាច្រើនដែលមិនទាន់មាននៅកម្ពុជា។** ឱកាសថ្មីៗសម្រាប់សហគ្រិនភាព និងស្វ័យនិយោជក កំពុងកើនឡើងយ៉ាងច្រើនក្នុងសេដ្ឋកិច្ចឌីជីថល។ មជ្ឈមណ្ឌលព័ត៌មានរដ្ឋរបស់ចិនប៉ាន់ស្មានថា សន្ទុះកើនឡើងថ្មីៗក្នុងវិស័យពាណិជ្ជកម្មតាមអ៊ីនធើណិត បានបង្កើតការងារ ១០ លាន នៅតាមហាងអនឡាញ និងសេវាពាក់ព័ន្ធ ដែលស្មើនឹង ១,៣% នៃការងារក្នុងប្រទេស។ នៅប្រទេសកេនយ៉ា ប្រព័ន្ធទូទាត់ប្រាក់ឌីជីថល M-Pesa បានបង្កើតប្រាក់ចំណូលបន្ថែមសម្រាប់ភ្នាក់ងារជាង ៨០.០០០ នាក់។ ហាង Samasource និង Rural ផ្សារភ្ជាប់អតិថិជនក្នុងសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ជាមួយនឹងកម្មករនិយោជិតនៅប្រទេសហ្កាណា ហៃទី ឥណ្ឌា កេនយ៉ា និងអ៊ុយហ្គែនដា។ ក្នុងចំណោមកម្មករនិយោជិតអនឡាញទូទាំងពិភពលោកដែលស្ថិតក្នុងវេទិកាអនឡាញ Elance ដែលជាផ្នែកមួយនៃ Upwork កម្មករនិយោជិត ៤៤% គឺជាស្ត្រី ហើយពួកគេភាគច្រើនចង់រក្សាតុល្យភាពជីវិតការងារ និងជីវិតគ្រួសារ។ លើសពីនេះទៀត ការងារក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ហាក់ទទួលបានប្រាក់ឈ្នួលល្អប្រសើរ ហើយការងារប្រើបច្ចេកវិទ្យាខ្ពស់នីមួយៗ បង្កើតការងារបន្ថែមចំនួន ៤,៩ ទៀតក្នុងវិស័យផ្សេងទៀតនៅសហរដ្ឋអាមេរិក[២៥]។

### ប្រអប់ ស១ ៖ តាក់ស៊ី PassApp ផ្តល់ដំណោះស្រាយឈ្នះ-ឈ្នះ ទាំងសម្រាប់អ្នករត់តាក់ស៊ី និងអតិថិជន

តាក់ស៊ី PassApp កំពុងទទួលបានប្រជាប្រិយភាពយ៉ាងឆាប់រហ័សនៅរាជធានីភ្នំពេញ។ គ្រាន់តែចុចលើកម្មវិធី PassApp ក្នុងទូរស័ព្ទស្មាតហ្វូនប៉ុណ្ណោះ តាក់ស៊ីនឹងមកដល់ទីតាំងរបស់អ្នកភ្លាម ចំណែកថ្លៃដឹកថោកខ្លាំង ជាពិសេសបើប្រៀបទៅនឹងការជិះតុក-តុក។ តម្លៃថោកនេះគឺដោយសារតែ (១) អ្នករត់តុក-តុក ប្រើហ្គាស (និងសាំង) (២) អ្នកបើកបរគ្រាន់តែរង់ចាំសារពីអ្នកដំណើរដោយប្រើទូរស័ព្ទចល័ត (ជំនួសឲ្យការជិះឆ្វែលរកអតិថិជន) (៣) ថ្លៃឈ្នួលមានតម្លាភាព គឺផ្អែកតាមចម្ងាយផ្លូវធ្វើដំណើរដែលបង្ហាញដោយ GPS គុណនឹងថ្លៃសេវាមួយគីឡូម៉ែត្រ និងបង្ហាញលើទូរស័ព្ទចល័តរបស់អ្នកបើកបរ និងអ្នកដំណើរ។

កត្តាឈ្នះ-ឈ្នះ គឺថ្លៃឈ្នួលមានតម្លាភាពដែលផ្តល់ដោយ PassApp និងបង្ហាញលើទូរស័ព្ទរបស់អ្នកបើកតាក់ស៊ី និងអតិថិជន។ រ៉ឺម៉កកង់បីបែបប្រពៃណី (ម៉ូតូសណ្តោងរ៉ឺម៉ក) គ្មានចំណុចពិសេសដូច្នេះទេ។ ទោះជាប្រព័ន្ធតាក់ស៊ីម៉ែត្រហាក់ផ្តល់ការគណនាថ្លៃឈ្នួលដែលមានតម្លាភាពស្រដៀងគ្នា អតិថិជនអាចនឹងគ្មានទំនុកចិត្តទាំងស្រុងលើសុក្រិតភាពនៃប្រព័ន្ធម៉ែត្រនោះទេ។

**ប៉ុន្តែ កម្ពុជាត្រូវត្រៀមខ្លួនសម្រាប់ការងារនៅពេលអនាគត។** ប្រព័ន្ធអប់រំនៅកម្ពុជា ត្រូវធ្វើបច្ចុប្បន្នភាពដើម្បីបណ្តុះជំនាញត្រឹមត្រូវសម្រាប់មនុស្សជំនាន់ក្រោយ ចំណែកកម្មករនិយោជិតបច្ចុប្បន្នត្រូវបំប៉នជំនាញរបស់ខ្លួនលើការងារ តាមរយៈការបណ្តុះបណ្តាលក្នុងពេលកំពុងបម្រើការ ឬវគ្គបណ្តុះបណ្តាលខ្លីដើម្បីរៀនសូត្រពីជំនាញចាំបាច់នៅកន្លែងការងារដែលប្រើបច្ចេកវិទ្យា។ ប្រសិនបើកម្ពុជាចង់ធ្វើពិពិធកម្មការនាំចេញសេវាដែលមានតម្លៃបន្ថែមកាន់តែខ្ពស់ ដូចជា ទេសចរណ៍មានតម្លៃខ្ពស់ និងសេវាធ្វើការនៅការិយាល័យ កម្ពុជាត្រូវរៀបចំកម្លាំងពលកម្មរបស់ខ្លួនឲ្យមានជំនាញភាសាបរទេសកាន់តែច្រើនបន្ថែមលើភាសាអង់គ្លេស និងចិន។ យ៉ាងនេះក្តី ល្បឿនសមាហរណកម្មក្នុងតំបន់បច្ចុប្បន្ននៅតែមានកម្រិតយឺត ព្រោះជាមធ្យម ប្រទេសសមាជិកអាស៊ានមានគោលនយោបាយរឹតបន្តឹងសេវាជាងតំបន់ផ្សេងទៀតក្នុងពិភពលោក លើកលែងតែ

[២៥] របាយការណ៍អភិវឌ្ឍន៍ពិភពលោក (២០១៦) ៖ ចំណែកឌីជីថល។

រដ្ឋនៅតាមឈូងសមុទ្រ។ ចំណែកវិស័យសេវាក្នុង ផសស មានទំហំតិចជាង ៥០% នៃ ផសស ធៀបនឹងអត្រាជាង ៦០% នៅអាមេរិកឡាទីន អឺរ៉ុបខាងកើត និងមជ្ឈិមបូព៌ា[២៦]។

## ខ) សហគ្រាសៈ កង្វះខ្នាតមធ្យម

**សហគ្រាសនៅកម្ពុជាមានកង្វះខ្នាតមធ្យម ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់កំណើនការងារ។** ជាង ៨០% ជាសហគ្រាសខ្នាតតូច (មីក្រូ) ដែលផ្តល់ការងារដល់និយោជិតតិចជាង ១០ នាក់ ចំណែកសហគ្រាសតិចជាង ១ ភាគ ៥ ជាសហគ្រាសខ្នាតធំ (សហគ្រាសមួយផ្តល់ការងារដល់និយោជិតជាង ១០០ នាក់) ដែលផ្តល់ការងារសរុបប្រមាណ ៥០% ក្នុងវិស័យឯកជន (រូប ស ១៣)។ កង្វះសហគ្រាសខ្នាតមធ្យមនេះបានធ្វើឲ្យប៉ះពាល់ដល់ការបង្កើតការងារ និងបង្ហាញពីគម្លាតដ៏ធំនៃផលិតភាពកម្មករនិយោជិតដែលបណ្តាលមកពីឥទ្ធិពលប្រយោលមានកម្រិតទាប និងការផ្ទេរបច្ចេកវិទ្យាពីវិស័យទំនើបទៅវិស័យសាមញ្ញ។ សហគ្រាសធំៗដែលផ្តោតលើការនាំចេញ អាចលូតលាស់ដោយពឹងផ្អែកលើផលិតភាពខ្ពស់ ប៉ុន្តែ ក្រុមហ៊ុនតូចៗភាគច្រើនដែលប្រឡូកក្នុងទីផ្សារក្នុងស្រុក ធ្វើអាជីវកម្មទាំងត្រដរ។ ក្នុងផ្នែកសម្លៀកបំពាក់ និងវាយនភ័ណ្ឌដែលជាកត្តាជម្រុញកំណើនដ៏សំខាន់ កំណើនការងារធៀបនឹងកំណើនលក់ មានកម្រិតទាប។ ភាពយឺត (Elasticity)នៃការងារធៀបនឹងកំណើនសេដ្ឋកិច្ច មានកម្រិតទាបដោយសារតែខ្វះទំនាក់ទំនងជាមួយនឹងការវិនិយោគពីបរទេស (រូប ស ១៤)។ កំណើនប្រាក់ឈ្នួលបានធ្វើឲ្យវិស័យសម្លៀកបំពាក់ដែលស្រូបយកកម្មករនិយោជិតទទួលបានប្រាក់ឈ្នួលប្រមាណ ១ ភាគ ៣ មិនសូវមានភាពប្រកួតប្រជែង ហើយចំណុចនេះបានបង្កហានិភ័យដល់កំណើនការងារ។

**រូប ស១៣៖ របាយការងារ (ខាងឆ្វេង) និងក្រុមហ៊ុន (ខាងស្តាំ)**




*ប្រភព៖* ការគណនារបស់អ្នកនិពន្ធ ផ្អែកតាមជំរឿន និង ICES
*សម្គាល់៖* ទម្ងន់ទំហំអប្បរមា ១

**រូប ស១៤៖ ភាពយឺតនៃការងារ (Elasticity) និងកំណើនមានកម្រិតទាប**




*ប្រភព៖* ការអង្កេតសហគ្រាសរបស់ធនាគារពិភពលោក
*សម្គាល់៖* មេគុណ- វិស័យផ្សេងៗ $p<0,05$

**ផលិតភាពទាបធ្វើឲ្យប៉ះពាល់ដល់គុណភាពការងារ។** ក្រុមហ៊ុនចង់បានកម្លាំងពលកម្មមានផលិតភាពខ្ពស់ និងត្រូវមានការបង្កើនប្រាក់ឈ្នួល ទន្ទឹមគ្នានឹងការកែលម្អផលិតភាព។ ប៉ុន្តែនៅច្រើនឆ្នាំកន្លងមក ប្រាក់ឈ្នួលអប្បបរមាបានកើនឡើងលឿនជាងផលិតភាព ដែលធ្វើឲ្យមានចំណាយខ្ពស់លើកម្លាំងពលកម្មក្នុងមួយឯកតារបស់ក្រុមហ៊ុនវាយនភ័ណ្ឌនៅកម្ពុជាជាងប្រទេសជិតខាង (រូប ស ១៥)។ ជាលទ្ធផល កម្ពុជាមានឱកាសតិចតួចក្នុងការបង្កើនឈ្នួលបន្ថែមទៀត ប្រសិនបើកម្ពុជាចង់រក្សាភាពប្រកួតប្រជែងក្នុងវិស័យសម្លៀកបំពាក់ និងវាយនភ័ណ្ឌ។ ថ្មីៗនេះ ប្រាក់ឈ្នួលអប្បបរមា (មិនគិតប្រាក់ឧបត្ថម្ភ) សម្រាប់វិស័យសម្លៀកបំពាក់ និងស្បែកជើង គឺ ១៧០ ដុល្លា/ខែ[២៧]។ តាំងពីឆ្នាំ ២០១៣ មក ប្រាក់ឈ្នួលអប្បបរមាបាន និងកំពុងកើនឡើងយ៉ាងលឿន គឺកើនឡើងជាមធ្យម ១៧,៦% ក្នុងមួយឆ្នាំនៅអំឡុងឆ្នាំ ២០១៣-២០១៧ ធៀបនឹងអត្រាត្រឹមតែ ៧,៤% នៅអំឡុងឆ្នាំ ២០០៨-២០១៣។ កំណើនផលិតភាពយឺតធ្វើឲ្យមានការកែលម្អតិចតួចលើគុណភាពការងារ។

**រូប ស ១៥៖ មធ្យមភាគ និងមេដ្យ៉ានសម្រាប់ចំណាយតាមឯកតាកម្លាំងពលកម្ម** (គិតជា % នៃតម្លៃបន្ថែម) **របស់ក្រុមហ៊ុនវាយនភ័ណ្ឌក្នុងបណ្តាប្រទេសដែលយកមកប្រៀបធៀប**




*ប្រភព៖* ទិន្នន័យការអង្កេតសហគ្រាសដោយធនាគារពិភពលោក
*សម្គាល់៖* ulc ចំណាយតាមឯកតាកម្លាំងពលកម្ម (ទម្ងន់ ឆ្នាំចុងក្រោយនៃការអង្កេតសហគ្រាសដែលមាន)។

---

២៦ របាយការណ៍សមាហរណកម្មសេវាអាស៊ាន (២០១៥) ៖ របាយការណ៍រួមរបស់លេខាធិការដ្ឋានអាស៊ាន និងធនាគារពិភពលោក។
២៧ សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១៧ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## គ) ពាណិជ្ជកម្ម និងការវិនិយោគផ្ទាល់ពីបរទេស

**ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា និងការវិនិយោគពីបរទេសក្នុងវិស័យឯកជន មានទំនាក់ទំនងគ្នាជិតស្និទ្ធ។** វិស័យនាំចេញ លើកលែងតែការជួញដូរទំនិញកសិកម្ម មានសមាសភាគភាគច្រើនក្នុងវិស័យការវិនិយោគផ្ទាល់ពីបរទេស។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេស គាំទ្រដល់កំណើននាំចេញរបស់កម្ពុជា និងការបង្កើតការងារសម្រាប់ប្រជាជនក្នុងប្រទេស។ ក្នុងតារាង ស ៣ វិស័យនាំចេញ ជាពិសេសសម្លៀកបំពាក់ និងទេសចរណ៍ ដើរតួនាទីដ៏សំខាន់ក្នុងការបង្កើតការងារ។ ជាច្រើនឆ្នាំកន្លងមក លំហូរការវិនិយោគផ្ទាល់ពីបរទេសបានជួយជំរុញវិស័យសំណង់ និងអចលនទ្រព្យ ហើយវិស័យទាំងពីរនេះបានធ្វើឲ្យមានការពង្រីកសេដ្ឋកិច្ច និងកំណើនការងារ។ លំហូរការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល កន្លែងស្នាក់នៅ សំណង់ និងអចលនទ្រព្យបញ្ចូលគ្នា ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ជិត ៥០% នៃលំហូរសរុបនៅឆ្នាំ ២០១៦[២៨]។

**តារាង ស ៣ ៖ ការងារក្នុងវិស័យកសិកម្មដែលថយចុះ ត្រូវបានដោះស្រាយដោយកំណើនការងារខ្ពស់តែក្នុងវិស័យកាត់ដេរ និងសំណង់ ដែលធ្វើឲ្យមានការបង្កើតការងារតិច**

| | 2004-07 | 2007-11 | 2011-15 |
|---|---|---|---|
| កសិកម្ម | 433,572 | 533,124 | -945,646 |
| វាយនភ័ណ្ឌ ស្បែក និងស្បែកជើង | 16,477 | 307,737 | 335,156 |
| សំណង់ | 95,047 | -1,190 | 358,734 |
| ឧស្សាហកម្មផ្សេងៗ | 98,252 | -24,162 | 1,218 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 2,710 | 130,892 | 132,612 |
| ពាណិជ្ជកម្ម | -3,514 | 121,663 | -6,364 |
| អចលនទ្រព្យ និងសេវាជំនាញផ្សេងៗ | 137,944 | 82,003 | 109,978 |
| សេវាកម្មផ្សេងៗ | -37,345 | 8,901 | 274,457 |
| ការបង្កើតការងារសរុប | 743,144 | 1,158,968 | 260,145 |

*ប្រភព៖* ការគណនារបស់អ្នកនិពន្ធដោយប្រើប្រាស់ ទិន្នន័យស្តីពីការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា។

**យ៉ាងនេះក្តីប្រពលភាពកម្លាំងពលកម្មនៃការនាំចេញ (ប្រាក់ឈ្នួលជាដុល្លារអាមេរិកធៀបនឹងការនាំចេញ) មានអត្រាទាបជាងប្រទេសជិតខាង។** ចំនួនកម្លាំងពលកម្មប្រយោលក្នុងការនាំចេញ មានតែប្រមាណ ១ ភាគ ៤ ប៉ុណ្ណោះ ធៀបនឹងអត្រា ១ ភាគ ២ នៅប្រទេសក្នុងតំបន់ (រូប ស ១៦) ដែលបង្ហាញពីកង្វះការផ្សារភ្ជាប់នឹងវិស័យការវិនិយោគផ្ទាល់ពីបរទេស និងគម្លាតផលិតភាពយ៉ាងធំរវាងក្រុមហ៊ុននាំចេញផ្ទាល់ និងប្រយោល។ ចំណុចនេះប៉ះពាល់ដល់របៀបដែលការនាំចេញជួយដល់ការបង្កើតការងារនៅកម្ពុជា។ ប្រាក់ឈ្នួល និងការងារដែលត្រូវបានគាំទ្រតាមរយៈទំនាក់ទំនងដោយ ប្រយោលទៅនឹងក្រុមហ៊ុននាំចេញ នៅតែមានកម្រិតខ្សោយ។ ក្នុងន័យម្យ៉ាងទៀតការងារជាមួយក្រុមហ៊ុននាំចេញដោយប្រយោល មិនត្រូវបានបែងចែកដល់ក្រុមហ៊ុនដែលមានផលិតភាពបំផុតឡើយ (ខុសពីក្រុមហ៊ុននាំចេញផ្ទាល់)។ ក្រៅពីនេះ ភាគរយនៃវត្ថុធាតុដើមដែលរកបានក្នុងស្រុក មានកម្រិតទាបបំផុតក្នុងតំបន់ ដោយសារវិស័យក្នុងស្រុកដែលមិនសូវមានការអភិវឌ្ឍ (រូប ស ១៧) ដែលបញ្ជាក់ពីសារៈសំខាន់នៃការបង្កើតការងារល្អប្រសើរតាមរយៈការអភិវឌ្ឍក្រុមហ៊ុនក្នុងស្រុក។

**រូប ស១៦៖ ចំណែកនៃកម្លាំងពលកម្មផ្ទាល់ និងប្រយោលក្នុងការនាំចេញ**




*ប្រភព៖* មូលដ្ឋានទិន្នន័យរបស់ធនាគារពិភពលោកស្តីពីចំណែកកម្លាំងពលកម្មក្នុងការនាំចេញ

**រូប ស១៧៖ ភាគរយនៃវត្ថុធាតុដើមពីក្នុងស្រុក**




*ប្រភព៖* ទិន្នន័យការអង្កេតសហគ្រាសរបស់ធនាគារពិភពលោក

២៨ ការប៉ាន់ស្មាន FDI តាមវិស័យ ៖ ធនាគារជាតិនៃកម្ពុជា។

## ឃ) សហគ្រាសគ្រួសារមិនមែនកសិដ្ឋាន

**ដូចការពិភាក្សាខាងលើ សហគ្រាសគ្រួសារមិនមែនកសិដ្ឋាន កំពុងផ្តល់ការងារប្រមាណ ១,៤១ លាន ឬស្មើនឹង ១៨% នៃការងារសរុប។ ដូច្នេះ ការជំរុញសហគ្រាសប្រភេទនេះ ជាពិសេសសហគ្រាសដែលមិនសូវរីកចម្រើន ជាការចាំបាច់ក្នុងការសម្រេចបានការងារ ប្រាក់ចំណូល និងកំណើនផលិតភាពកាន់តែខ្ពស់។** សហគ្រាសគ្រួសារមិនមែនកសិដ្ឋាននៅកម្ពុជា មានលក្ខណៈចម្រុះ។ គ្រួសារនៅទីប្រជុំជនជាង ៥០% មានសហគ្រាសខ្នាតតូច ធៀបនឹងគ្រួសារត្រឹមតែ ២៣% នៅជនបទ ហើយសហគ្រាសពាក់កណ្តាលប្រកបអាជីវកម្មលក់រាយ ចំណែកពាក់កណ្តាលទៀតផ្តល់សេវា និងផលិតផលសម្រេចចម្រុះ។ ស្ត្រី (១៩%) មានចំណែកច្រើនជាងបុរស (១៣%) ក្នុងសមាសភាគសហគ្រាសគ្រួសារ។ ជាមធ្យម ប្រាក់ចំណូល និងផលិតភាពរបស់សហគ្រាសគ្រួសារមិនមែនកសិដ្ឋាន មានសភាពល្អប្រសើរដូចប្រាក់ចំណូល និងផលិតភាពរបស់កម្មករទទួលបានប្រាក់ឈ្នួលដែរ (រូប ស ១៨) ករណីកើតឡើងជាពិសេសនេះ សម្រាប់សហគ្រាសគ្រួសារដែលធ្វើប្រតិបត្តិការក្នុងសហគមន៍ប្រជាជនដែលមានជីវភាពធូរធារ។ ប៉ុន្តែរបាយប្រាក់ចំណូល និងផលិតភាពជាច្រើនបង្ហាញថា សហគ្រាស ៥០% កំពុងបំពេញមុខងារបានយ៉ាងល្អ ចំណែកសហគ្រាស ៥០% ទៀតបំពេញមុខងារមិនបានល្អឡើយ។

### រូប ស១៨៖ របាយប្រាក់ចំណូល (ខាងលើ) និងផលិតភាព (ខាងក្រោម) ទៅតាមប្រភេទការងារ




*ប្រភព៖ ការប៉ាន់ស្មានរបស់អ្នកនិពន្ធដោយប្រើប្រាស់ទិន្នន័យការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ ២០១៤*

**ទោះបីជាសហគ្រាសគ្រួសារមានទំនាក់ទំនងនឹងក្រុមហ៊ុនធំៗក្តី ក៏សហគ្រាសទាំងនេះទទួលបានអត្ថប្រយោជន៍តិចតួចពីឧស្សាហកម្មធំៗបំផុតនៅកម្ពុជា (សម្លៀកបំពាក់ និងស្បែកជើង)។** ខណៈដែលក្រុមហ៊ុនគ្រប់គ្រងដោយប្រជាជនកម្ពុជា មានកាន់តែច្រើន ហើយក្រុមហ៊ុនមិនមែនសម្លៀកបំពាក់ដែលគ្រប់គ្រងដោយជនបរទេស បានជ្រៀតចូលក្នុងទីផ្សារនេះ សហគ្រាសគ្រួសារត្រូវបានបង្កើតឡើងដើម្បីជួយដល់ក្រុមហ៊ុនទាំងនោះ (រូប ស ១៩ តារាងខាងស្តាំ)។ ទំនាក់ទំនងរវាងសហគ្រាសខ្នាតតូចទាំងនេះ និងក្រុមហ៊ុនធំៗ បានផ្តល់ប្រភពប្រាក់ចំណូល ក៏ដូចជាឥទ្ធិពលប្រយោលដែលជួយបង្កើនស្តង់ដារ និងដំណើរការ ព្រមទាំងផលិតភាព និងប្រាក់ចំណូលក្នុងសហគ្រាសខ្នាតតូច។ ផ្ទុយទៅវិញ ការពង្រីកវិស័យសម្លៀកបំពាក់ និងស្បែកជើងមិនសូវជួយឲ្យសហគ្រាសគ្រួសារលូតលាស់ឡើយ (រូប ស ១៩ តារាងខាងឆ្វេង)។ ជាថ្មីម្តងទៀត ចំណុចនេះបញ្ជាក់ពីកង្វះទំនាក់ទំនងរវាងវិស័យដែលជំរុញដោយការវិនិយោគផ្ទាល់ពីបរទេសនេះ និងវិស័យផ្សេងទៀតក្នុងសេដ្ឋកិច្ច។

### រូប ស១៩៖ កំណើនការងារទទួលបានប្រាក់ឈ្នួល និងកំណើនសហគ្រាសមិនមែនកសិដ្ឋាន




*ប្រភព៖ ការប៉ាន់ស្មានរបស់អ្នកនិពន្ធដោយប្រើប្រាស់ទិន្នន័យការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ ២០១៤*

## ង) កម្មករនិយោជិត

**កម្លាំងពលកម្មរបស់កម្ពុជាកំពុងកើនឡើង ហើយនេះជាឱកាសមាសដើម្បីជំរុញកំណើនសេដ្ឋកិច្ច។** ខុសពីបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់ ដូចជា សិង្ហបុរី ជប៉ុន អូស្ត្រាលី វៀតណាម និងចិនដែលមានកំណើនប្រជាជនចាស់យ៉ាងលឿនដោយមានអត្រាពឹងផ្អែកកើនឡើង កំណើនប្រជាជនគ្រប់អាយុធ្វើការនៅកម្ពុជា ត្រូវបានរំពឹងថានឹងមានសន្ទុះលឿនជាងកំណើនប្រជាជនរហូតដល់ឆ្នាំ ២០៤៥ ដែលធ្វើឲ្យអត្រាពឹងផ្អែកថយចុះរហូតដល់ឆ្នាំ ២០៥០។ មានន័យថា ប្រជាជនគ្រប់អាយុធ្វើការ ជាពិសេសស្ត្រី នឹងមានពេលវេលាកាន់តែច្រើនសម្រាប់ធ្វើការ ព្រោះចំនួនអ្នកធ្វើការធៀបនឹងចំនួនមនុស្សក្នុងបន្ទុក មានកម្រិតខ្ពស់។ នៅពេលអត្រាពឹងផ្អែកចាប់ផ្តើមកើនឡើង កម្មករនិយោជិតអាចមានពេលវេលាធ្វើការ ឬជម្រើសការងារតិចតួច ព្រោះពួកគេចំណាយពេលច្រើនលើការថែទាំ មនុស្សចាស់។

**ទោះយ៉ាងនេះក្តី ការរក្សាបានកំណើនកម្លាំងពលកម្មតែមួយម៉ាង មិនទាន់គ្រប់គ្រាន់ដើម្បីទាក់ទាញ និងបង្កើតការងារល្អៗឡើយ ជាពិសេសនៅពេលនិយោជកប្រឈមនឹងការខ្វះខាតជំនាញខ្លាំង។** និយោជកនៅកម្ពុជាមិនពេញចិត្តនឹងជំនាញរបស់កម្លាំងពលកម្មបច្ចុប្បន្នឡើយ។ ខណៈដែលប្រទេស ក្នុងតំបន់ជាច្រើនប្រឈមនឹងឧបសគ្គដូចគ្នា គឺ "កម្លាំងពលកម្មជំនាញមិនគ្រប់គ្រាន់" កម្ពុជាប្រឈម នឹងបញ្ហានេះខ្លាំងបំផុត បន្ទាប់ពីប្រទេសឡាវ (រូប ស ២០)។

**រូប ស២០៖ និយោជកកម្ពុជារងផលប៉ះពាល់ច្រើនជាងប្រទេសដទៃទៀត ដោយសារកម្លាំងពលកម្មមិនមានជំនាញគ្រប់គ្រាន់**




*ប្រភព៖* ការអង្កេតសហគ្រាស ឆ្នាំ ២០១៦

សហគ្រាសខ្នាតតូច និងមធ្យម ដែលសក្តានុពលកំណើនការងារមិនទាន់ត្រូវបានទាញផល លើកឡើងពីកង្វះកម្លាំងពលកម្មជំនាញក្នុងចំណោមបញ្ហាអាទិភាព ៣។ សម្រាប់ក្រុមហ៊ុនធំៗ បញ្ហានេះមានកម្រិតទាប។

**ការដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មជំនាញត្រូវប្រឈមនឹងបញ្ហាមួយទៀត គឺអត្រាចំណូលពីការសិក្សាមានកម្រិតទាប** (រូប ស ២១)។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងចុងក្រោយក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំអាចផ្តល់ផលល្អប្រសើរ (ផ្អែកតាមការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០១៥) ក្តី ក៏និយោជកនៅកម្ពុជាផ្តល់តម្លៃតិចតួចដល់ការអប់រំក្រោម ១២ ឆ្នាំ។ ចំណុចនេះអាចបង្ហាញថា ការបន្ថែមតម្លៃសម្រាប់ចំនួនឆ្នាំសិក្សាបន្ថែមរហូតដល់ការបញ្ចប់បឋមសិក្សា និងថ្នាក់វិទ្យាល័យ មិនទាន់គ្រប់គ្រាន់សម្រាប់ទីផ្សារការងារឡើយ។

ទោះបីជាមានវឌ្ឍនភាពថ្មីៗក្តី ក៏កម្រិតអប់រំរបស់កម្លាំងពលកម្មនៅតែមានកម្រិតទាប។ កម្លាំងពលកម្មនៅកម្ពុជាដែលបញ្ចប់ថ្នាក់បឋមសិក្សា និងទាបជាងនេះ មានប្រមាណ ៦៧,៥% នៃអត្រា

**រូប ស២១៖ ផលនៃការសិក្សាមានកម្រិតទាប**




*ប្រភព៖* ការគណនារបស់អ្នកនិពន្ធដោយប្រើប្រាស់ទិន្នន័យការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ ២០១៤

សរុប (រូប ស ២២)។ ការបង្កើនគុណភាពអប់រំថ្នាក់បឋមសិក្សាអាចមានន័យថាជាការត្រៀមខ្លួនសិស្សបញ្ចប់ថ្នាក់បឋមសិក្សាកាន់តែប្រសើរសម្រាប់ទីផ្សារការងារ និងកាត់បន្ថយឧបសគ្គលើកំណើនការងារ។ ទន្ទឹមនឹងនេះ ការលើកកម្ពស់ការបន្តការអប់រំរហូតដល់បញ្ចប់ថ្នាក់មធ្យមសិក្ស អាចទាក់ទាញការងារល្អៗ។

**រូប ស២២៖ កម្រិតអប់រំរបស់កម្លាំងពលកម្ម**
(គិតជាភាគរយ ឆ្នាំ ២០១៥)




*ប្រភព៖* ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា

**ទោះជាយ៉ាងនេះក៏ដោយ កម្ពុជាអាចត្រូវចំណាយពេលលើសពីមួយជំនាន់មនុស្សសម្រាប់កែលម្អប្រព័ន្ធអប់រំបច្ចុប្បន្នដើម្បីផ្លាស់ប្តូរជំនាញរបស់កម្លាំងពលកម្ម។** ខណៈពេលដែលកម្លាំងពលកម្មថ្មីដែលចូលមកមានកម្រិតអប់រំកាន់តែខ្ពស់ កម្លាំងពលកម្មយ៉ាងច្រើននាពេលបច្ចុប្បន្ន ប្រមាណ ៨ លាននាក់ មានកម្រិតអប់រំទាប។ ដូច្នេះ វាត្រូវការពេលវេលាយូរសម្រាប់ឲ្យកម្លាំងពលកម្មដែលមានការអប់រំតិចចូលនិវត្តន៍ និងសម្រាប់ឲ្យកម្លាំងពលកម្មដែលទើបបញ្ចប់ការសិក្សាថ្មីៗមកជំនួសការងារពួកគេ។ តាមពិត ប្រសិនបើគេអាចរក្សាអត្រាបញ្ចប់ថ្នាក់មធ្យមសិក្សាបច្ចុប្បន្នបានសម្រាប់

រយៈពេល ២០ ឆ្នាំទៅមុខ ចំណែកកម្លាំងពលកម្មដែលបញ្ចប់ថ្នាក់មធ្យមសិក្សានឹងកើនឡើងពី ១៨% (បច្ចុប្បន្ន) ទៅ ៣៨% (ឆ្នាំ ២០៤០)។

**បញ្ហាកង្វះជំនាញនឹងកាន់តែខ្លាំងឡើង នៅពេលកម្ពុជាធ្វើដំណើរទៅរក "ការងារចំណេះដឹង និង សេដ្ឋកិច្ច"។** ការងារនៅឆ្នាំ ២០១៥ ត្រូវបានវាយតម្លៃថាមានជំនាញចម្រុះជាងការងារនៅឆ្នាំ២០០៩ (រូប ស ២៣)។ ដូចពិភាក្សាក្នុងប្រអប់ ៣ ស្តីពីការផ្លាស់ប្តូរចនាសម្ព័ន្ធ (គោលនយោបាយ យុទ្ធសាស្ត្រ និងកំណែទម្រង់)

**រូប ស២៣៖ ទីផ្សារការងារនៅកម្ពុជាបានវិវឌ្ឍដោយមានការប្រើប្រាស់ជំនាញចម្រុះ**




*ប្រភព៖* ការគណនារបស់អ្នកនិពន្ធ
*សម្គាល់៖* R ជាប់លាប់ NR មិនជាប់លាប់

ឧបសគ្គដែលបង្កឡើងដោយកង្វះកម្លាំងពលកម្មមានចំណេះដឹងនឹងក្លាយជាឧប សគ្គធ្ងន់ធ្ងរបំផុតទីពីរសម្រាប់ប្រតិបត្តិការរបស់សហគ្រាសផលិតនៅឆ្នាំ ២០១៦ (កើនពីលំដាប់ឧប សគ្គធ្ងន់ធ្ងរបំផុតទី ៥ នៅឆ្នាំ ២០១៣) (រូប ខ ៣.១)។ អ្វីដែលសំខាន់គឺមានចំណែកកាន់តែច្រើននៃការងារដែលប្រើប្រាស់ចំណេះដឹង គឺជាការងារដែលត្រូវការភាពច្នៃប្រឌិត ភាពជាអ្នកដឹកនាំ ការដោះស្រាយបញ្ហា ភាសា និងបណ្តុះជំនាញជាច្រើន។ កំណើនការងារទាំងនេះមិនមែនបណ្តាលមកពីការកើនឡើងនៃការងារមួយចំនួនណានោះទេ ប៉ុន្តែមកពីកំណើនការងារប្រើប្រាស់ចំណេះដឹងបន្តិចម្តងៗដែលមិនទាន់ក្លាយជាចំណុចស្នូលនៃទីផ្សារការងារកម្ពុជា។ក្រុមហ៊ុនធំៗត្រូវការសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងដែលមិនមានបណ្តុះបណ្តាលក្នុងគ្រឹះស្ថានអប់រំឧត្តមសិក្សា។ សហគ្រាសខ្នាតតូច និងមធ្យមត្រូវការជំនាញថ្មីៗជាច្រើន ជាពិសេសការងារថ្មីៗ ដូចជា ៖

- ជំនាញពិចារណាកម្រិតខ្ពស់ ៖ ទំនាក់ទំនងផ្ទាល់មាត់ ភាសាបរទេស
- ជំនាញសង្គម ៖ សេវាអតិថិជន ការងារជាក្រុម គំនិតផ្តួចផ្តើម
- ចំណេះដឹងឌីជីថល ៖ បច្ចេកវិទ្យាព័ត៌មាន របៀបប្រើប្រាស់បរិក្ខារ/នីតិវិធីថ្មី និង
- ជំនាញសាមញ្ញមួយចំនួន ៖ ការប្រើដៃយ៉ាងស្ទាត់ជំនាញ។

**ប្រព័ន្ធអប់រំមានតួនាទីសំខាន់ ប៉ុន្តែមិនអាចដោះស្រាយបញ្ហាប្រឈមនេះបានគ្រប់ជ្រុងជ្រោយឡើយ។** មានគម្លាតដ៏ធំក្នុងកម្រិតអប់រំ ជាពិសេសនៅពេលពិចារណាលើអត្ថប្រយោជន៍ពិតប្រាកដក្រោយការបញ្ចប់មធ្យមសិក្សា[29]។ យុទ្ធសាស្ត្រអប់រំថ្មីត្រូវបានរំពឹងថានឹងជួយផ្តល់ជំនាញពាក់ព័ន្ធនឹងការងារជាច្រើនដល់កម្លាំងពលកម្មថ្មី ប៉ុន្តែជំនាញមួយចំនួនមិនអាចបង្រៀនក្នុងសាលារៀនឡើយ។ ការប្រែប្រួលកម្លាំងពលកម្ម គឺការផ្លាស់ប្តូរពីដំណាក់កាលអភិវឌ្ឍបច្ចុប្បន្ននៃកម្លាំងពលកម្មដែលមានកម្លាំងពលកម្មភាគច្រើនគ្មានជំនាញ ទៅកម្លាំងពលកម្មមានជំនាញតិចតួច និងកម្លាំងពលកម្មជំនាញ ត្រូវចំណាយពេលយូរ (បរិមាណដែលមានធៀបនឹងលំហូរចូល)។ ក្រៅពីនេះ កម្លាំងពលកម្មភាគច្រើនមិនអាចពឹងផ្អែកលើប្រព័ន្ធអប់រំដើម្បីពង្រីកជំនាញបានឡើយ។

**ប្រភពផ្សេងទៀតនៃការអភិវឌ្ឍជំនាញ រួមមានការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។** យ៉ាងណាក៏ដោយ ការបង្កើតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឆ្លើយតបនឹងតម្រូវការជំនាញពាក់ព័ន្ធនឹងការងារជាច្រើន គឺជាការលំបាក។ ក្រៅពីនេះ ប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ បច្ចុប្បន្នត្រូវមានការកែលម្អបន្ថែម ដើម្បីឆ្លើយតបទៅនឹងទិដ្ឋភាពការងារដែលកំពុងវិវត្តយ៉ាងឆាប់រហ័ស និងអាចបង្កជាឧបសគ្គចំពោះការងារល្អប្រសើរ និងការកែប្រែសេដ្ឋកិច្ច ប្រសិនបើគ្មានការដោះស្រាយ ដោយប្រសិទ្ធផល និងប្រសិទ្ធភាពចំណាយទេនោះ។ ជំហានសំខាន់ដំបូងគឺការកែលម្អវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រោះតម្រូវការវគ្គនេះកំពុងថយចុះជាលំដាប់ (រូប ស ២៤)។

**រូប ស២៤៖ ចំនួនវគ្គសិក្សាតាមកម្រិតជំនាញ**




*ប្រភព៖* ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ ២០១២-១៥

[29] ២ ភាគ ៣ នៃសិស្សថ្នាក់ទី ៦ មិនអាចអាន ឬសរសេរបានស្ទាត់ជំនាញ (EGRA ២០១៣)។

**ត្រូវមានការវិភាគបន្ថែមទៀតដើម្បីបញ្ជាក់ពីអ្វីដែលធ្វើឲ្យមានការថយចុះវគ្គបណ្តុះបណ្តាល វិជ្ជាជីវៈ ថាតើវាពាក់ព័ន្ធនឹងតម្រូវការទីផ្សារ ឬគុណភាព និងជំនាញមិនត្រូវគ្នាទេ។** ឧទាហរណ៍ ការថយចុះយ៉ាងខ្លាំងនៃការផ្តល់វគ្គបណ្តុះបណ្តាលខ្លីៗ ទម្រង់បែបបទដែលកម្លាំងពលកម្មពេញវ័យ ត្រូវការ គឺជាបញ្ហាដែលត្រូវស្វែងយល់បន្ថែម។ បច្ចុប្បន្ន ឱកាសទទួលបានជំនាញ ជាពិសេសក្រោយពីឈប់រៀនហាក់ដូចជាមានកម្រិតតិចតួច។ ដូច្នេះ ការវិភាគពីការផ្គត់ផ្គង់ និងតម្រូវការសម្រាប់ "ការអប់រំមនុស្សពេញវ័យ" នៅកម្ពុជានឹងជាមូលដ្ឋានសម្រាប់ការបង្កើតប្រព័ន្ធអភិវឌ្ឍជំនាញដ៏មានប្រសិទ្ធភាព។

ផ្នែកសំខាន់ៗ ៣ សម្រាប់ប្រព័ន្ធអភិវឌ្ឍជំនាញដ៏ជោគជ័យ រួមមាន ក្របខ័ណ្ឌយុទ្ធសាស្ត្រ ការគ្រប់គ្រងប្រព័ន្ធ និងការផ្តល់សេវា។ ដើម្បីឲ្យអន្តរាគមន៍មួយមានប្រសិទ្ធភាព ត្រូវផ្តោតលើរបៀបដែលប្រព័ន្ធអភិវឌ្ឍជំនាញរបស់កម្ពុជា (ក្រៅប្រព័ន្ធអប់រំ) ដំណើរការធៀបនឹងការអនុវត្តល្អបំផុត ដូចជា ការផ្គត់ផ្គង់ និងសក្តានុពលសម្រាប់សេវាអភិវឌ្ឍជំនាញក្នុងវិស័យឯកជន ដែលត្រូវបានពិភាក្សាក្នុងផ្នែកខាងក្រោម។

**ប្រភពជាជម្រើសនៃការអភិវឌ្ឍជំនាញគឺក្រុមហ៊ុន។** នៅកម្ពុជាមានការបណ្តុះបណ្តាលជំនាញតិចតួចដោយក្រុមហ៊ុន។ ភាគរយក្រុមហ៊ុនដែលផ្តល់ការបណ្តុះបណ្តាលជាផ្លូវការស្ថិតក្រោមអត្រាមធ្យមភាគនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក (រូប ស ២៥)។ ប្រសិនបើការបណ្តុះបណ្តាលក្រៅផ្លូវការត្រូវបានរួមបញ្ចូល ភាគរយក្រុមហ៊ុនអាចកើនឡើងទ្វេដង។

**រូប ស២៥៖ ការបណ្តុះបណ្តាលក្នុងក្រុមហ៊ុន** (ភាគរយផ្តល់ការបណ្តុះបណ្តាល និងភាគរយកម្លាំងពលកម្មដែលទទួលបានការបណ្តុះបណ្តាល)




*ប្រភព៖* ការវិភាគរបស់អ្នកនិពន្ធដោយប្រើប្រាស់ទិន្នន័យ *ការអង្កេតសហគ្រាសរបស់ធនាគារពិភពលោក*

ម៉្យាងវិញទៀត មានកិច្ចសហការតិចតួចរវាងក្រុមហ៊ុន និងការបណ្តុះបណ្តាលវិជ្ជាជីវៈ[៣០]។ បើ ទោះជាក្នុងវិស័យ និងការងារមួយចំនួន កម្រិតអប់រំខ្ពស់គឺជាការចាំបាច់ ប៉ុន្តែក្នុងវិស័យ និងការងារផ្សេងទៀត ជំនាញសំខាន់ៗដែលត្រូវការ មិនទទួលបានពីការរៀនសូត្រជាផ្លូវការឡើយ តែទទួលបានពីការរៀនសូត្រពីការងារ។ នៅកម្ពុជា គ្មានកំណត់ត្រាពីការរៀនសូត្រតាមរយៈការអនុវត្តឡើយ ប៉ុន្តែទិន្នន័យពីប្រទេសវៀតណាមបង្ហាញថា កម្លាំងពលកម្មវៀតណាមជាច្រើនរៀនជំនាញថ្មីៗក្នុងពេលបម្រើការងារ។ ការរៀនសូត្រភាគច្រើនលេចឡើងក្នុងការងារធំៗ ដូចជា ប្រធានគ្រប់គ្រង អ្នកជំនាញ និងអ្នកបច្ចេកទេស (រូប ស ២៦)។ ដូច្នេះ កិច្ចការសំខាន់បំផុតត្រូវជំរុញឲ្យវិស័យឯកជនចូលរួមផ្តល់ ណែនាំ និងគាំទ្រដល់ការអភិវឌ្ឍជំនាញ។

**រូប ស២៦៖ កម្លាំងពលកម្មវៀតណាមដែលបានសិក្សាជំនាញថ្មីៗក្នុងពេលបម្រើការងារ ទៅតាមប្រភេទការងារ** (គិតជាភាគរយ)




*ប្រភព៖* Bodewig និង Badiani –Magnusson (២០១៤)

**ការផ្គូរផ្គងការងារគឺជាបញ្ហាប្រឈមមួយ ព្រោះថា ការត្រៀមខ្លួនធ្វើការ និងការស្វែងរកការងារភាគច្រើនធ្វើឡើងតាមបណ្តាញក្រៅផ្លូវការ។** ចំណុចនេះបង្ហាញថា លទ្ធភាពទទួលបានព័ត៌មានស្តីពីការសិក្សា និងអាជីព នៅតែជាបញ្ហា។ សិស្សនិស្សិត និងយុវជនមានការងារភាគច្រើន ពឹងផ្អែកលើបណ្តាញក្រៅផ្លូវការ (ការណែនាំពីមិត្តភក្តិ និងឪពុកម្តាយ) ពាក់ព័ន្ធនឹងការសិក្សា និងអាជីពរបស់ខ្លួន (រូប ស ២៧)។ ប៉ុន្តែ ខុសពីប្រទេសភាគច្រើន អ្នកស្វែងរកការងារនៅកម្ពុជាប្រើប្រាស់ប្រភពព័ត៌មានជាច្រើន រីឯការប្រើអ៊ីនធើណិតមានកម្រិតខ្ពស់បំផុត។ ៧០% នៃយុវជនមានការងារ ស្វែងរកព័ត៌មានស្តីពីការសិក្សា និងអាជីព ជាពិសេសការផ្សព្វផ្សាយពីការងារតាមគេហទំព័រ។ ទោះបីជាមានប្រភព ព័ត៌មានចម្រុះក្តី ក៏អត្រាផ្លាស់ចេញចូលការងារមិនសូវមានប្រសិទ្ធភាព។ អត្រាផ្លាស់

---

៣០ របាយការណ៍ស្តីពីជំនាញ (២០១៥) ធនាគារអភិវឌ្ឍន៍អាស៊ី។

ចេញចូលមាន កម្រិតខ្ពស់ គឺ ១៣,៧% នៃកម្លាំងពលកម្មទទួលបានប្រាក់ឈ្នួល បានបោះបង់ការងារនៅឆ្នាំ ២០១៥ និងចំនួនច្រើន (ក្រុមហ៊ុនពាក់កណ្ដាលក្នុងសំណាកដែលមានឧស្សាហកម្ម ៨) មានមុខតំណែងទំនេរមួយនៅឆ្នាំ ២០១៥ ហើយក្រុមហ៊ុន ៥០% ក្នុងចំណោមនេះ មានការលំបាកក្នុងការស្វែងរកបុគ្គលិកមកបម្រើការ។ ស្ថានភាពនេះបញ្ជាក់ពីទីផ្សារការងារដែលក្រុមហ៊ុន និងកម្មករនិយោជិតគ្មានមធ្យោបាយក្នុងការស្វែងរកគ្នាទៅវិញទៅមក ហើយអាចបង្ហាញពីការខ្វះខាតកម្មករនិយោជិតមានជំនាញគ្រប់គ្រាន់ដែលមានឆន្ទៈចូលរួមក្នុងការងារដែលទទួលបានប្រាក់ឈ្នួល។

### រូប ស២៧៖ ប្រភពព័ត៌មានពីការសិក្សា និងការងារ




*ប្រភព៖* ការអង្កេតយុវជនដែលធ្វើឡើងដោយក្រុមហ៊ុន HRINC កម្ពុជា ខែ មីនា ឆ្នាំ ២០១១

## ៤. ទិសដៅយុទ្ធសាស្ត្រសម្រាប់ការងារនៅពេលអនាគត៖ ឆ្ពោះទៅរកការងារល្អប្រសើរ និងមានការចូលរួម

### ក) ជម្រើសគោលនយោបាយតាមវិស័យ

**សហគ្រាសខ្នាតតូច និងមធ្យម ដែលជំរុញកំណើនការងារតាមរយៈការពង្រីក "មូលដ្ឋានការងារ" ដោយដោះស្រាយទៅលើកង្វះសហគ្រាសខ្នាតមធ្យម។** កង្វះសហគ្រាសខ្នាតមធ្យមបង្ហាញថាមានឱកាសជាច្រើនក្នុងការបង្កើនវិស័យឯកជនក្នុងស្រុករបស់កម្ពុជា។ ការដោះស្រាយបញ្ហានេះសំដៅលើការលើកកម្ពស់ការចុះបញ្ជី និងកំណើនសហគ្រាសខ្នាតតូច និងមធ្យមដែលមានប្រមាណ ៩០% នៃក្រុមហ៊ុន។ ចំណុចនេះពាក់ព័ន្ធនឹងការលុបបំបាត់គម្លាតផលិតភាពរបស់កម្មករនិយោជិត និងការបង្កើនឥទ្ធិពលប្រយោល និងការផ្ទេរបច្ចេកវិទ្យា ដូចជា ជំនាញគ្រប់គ្រង និងសហគ្រិនភាពពីវិស័យទំនើបទៅវិស័យសាមញ្ញ (ដំណើរការផ្សារភ្ជាប់វិស័យក្នុងស្រុក និងការវិនិយោគទុនពីបរទេស)។ ត្រង់ចំណុចនេះ ការកំណត់ និងដោះស្រាយឧបសគ្គធំៗលើការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធ បរិយាកាសអាជីវកម្ម និងប្រព័ន្ធលើកទឹកចិត្តដែលរាំងស្ទះដល់កំណើនវិស័យឯកជនក្នុងស្រុក គឺជាជំហានសំខាន់ទី ១។

**ការបង្កើនទីតាំងក្នុងសង្វាក់តម្លៃដែលមានស្រាប់ និងការទៅសង្វាក់តម្លៃថ្មី នឹងជួយឲ្យមានការងារល្អប្រសើរ និងមានការចូលរួមក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម។** សក្ដានុពលដ៏ធំនៃសង្វាក់តម្លៃកសិកម្មនៅតែមិនទាន់បានទាញផល ដោយសារតែការលូតលាស់វិស័យទេសចរណ៍យ៉ាងឆាប់រហ័ស។ នេះជាចំណុចសំខាន់បំផុតសម្រាប់ទីជនបទ នៅពេលគេចង់សម្រេចបានការងារដែលមានការចូលរួម។ ត្រង់ចំណុចនេះ អាជ្ញាធរកម្ពុជាបានដាក់ចេញការផ្ដួចផ្ដើមជាច្រើន ដូចជា ការផ្ដល់ប្រាក់កម្ចីដែលមានការប្រាក់ទាបក្នុងវិស័យស្រូវអង្ករ ការវិនិយោគលើការសាងសង់កន្លែងស្តុកទុកស្រូវអង្ករ និងរោងសម្ងួត។ យ៉ាងណាក៏ដោយ កង្វះកម្លាំងពលកម្មដែលមានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ រួមនឹងចំណាយខ្ពស់ផ្នែកភស្តុភារ និងថ្លៃអគ្គិសនី នៅតែមិនត្រូវបានដោះស្រាយ។ បញ្ហានេះបានរឹតត្បិតសមត្ថភាពរបស់សេដ្ឋកិច្ចកម្ពុជាក្នុងការពង្រីកខ្លួន និងជ្រៀតចូលក្នុងការងារក្នុងសង្វាក់តម្លៃថ្មី ដែលជាញឹកញាប់ទាមទារឲ្យមានការកែលម្អល្អប្រសើរ និងការបង្កើតជំនាញថ្មីៗ។

**សហគ្រាសគ្រួសារមិនមែនកសិដ្ឋាន ៖ ការគាំទ្រគោលនយោបាយដើម្បីលើកកម្ពស់សហគ្រាសគ្រួសារមិនមែនកសិដ្ឋាននឹងជួយជំរុញការបង្កើតការងារ។** ជំហានដ៏សំខាន់មួយគឺការវិភាគកត្តាផ្សេងៗដែលរាំងស្ទះការរីកចម្រើនរបស់សហគ្រាសប្រភេទនេះ ការកំណត់ទំនិញសាធារណៈជាអាទិភាពដែលត្រូវដាក់ចេញក្នុងរយៈពេលខ្លី និងមធ្យម។ វិធានការនេះគឺដើម្បីបង្កើនផលិតភាព និងភាពប្រកួតប្រជែងរបស់សហគ្រាសទាំងនោះ។ ដូចការពិភាក្សាខាងលើ សហគ្រាសគ្រួសារមិនមែនកសិដ្ឋានផ្ដល់ការងារប្រមាណ ១,៤១ លាន ឬស្មើនឹង ១៨% នៃការងារសរុប។ កន្លងមក មិនសូវមានការផ្ដោតការយកចិត្តទុកដាក់លើសហគ្រាសគ្រួសារមិនមែនកសិដ្ឋានឡើយ ហើយក៏មិនទាន់មានការគាំទ្រគោលនយោបាយ និងកម្មវិធីជាច្រើនសម្រាប់សហគ្រាសទាំងនេះដែរ។ ការគាំទ្រគោលនយោបាយរួមមាន ការអភិវឌ្ឍជំនាញសម្រាប់ម្ចាស់ក្រុមហ៊ុន ការអភិវឌ្ឍ និងលទ្ធភាពទទួលបានបច្ចេកវិទ្យាឌីជីថល និងអ៊ីនធើណិត ដែលពាក់ព័ន្ធនឹងដំណាក់កាលអភិវឌ្ឍសេដ្ឋកិច្ចបច្ចុប្បន្ន និងតួនាទីជាជើងសារ ដើម្បីពង្រីកទំនាក់ទំនងជាមួយឧស្សាហកម្មធំៗ។

## ខ) ជម្រើសគោលនយោបាយអន្តរវិស័យ

វិនិយោគលើការអភិវឌ្ឍធនធានមនុស្ស ទាំងសម្រាប់ជំនាញសាមញ្ញ និងជំនាញ “ថ្មីៗ” ក្នុងរយៈពេលខ្លី ដោយសារកម្ពុជាកំពុងប្រឈមនឹងបញ្ហាកង្វះកម្លាំងពលកម្មជំនាញខ្លាំងជាងប្រទេសផ្សេងទៀត។ ត្រង់ចំណុចនេះ ជោគជ័យនៃការអន្តរាគមន៍គោលនយោបាយណាមួយទំនងជាពឹងផ្អែកលើប្រសិទ្ធភាពនៃការលើកទឹកចិត្ត និងដំណើរការនានា ដើម្បីសម្រួលដល់តួនាទីរបស់វិស័យសហគ្រាសក្នុងការផ្តល់ ការណែនាំ និងការជំរុញឲ្យមានប្រព័ន្ធអភិវឌ្ឍជំនាញដែលឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម (សូមមើលប្រអប់ ស ២ ៖ ការបណ្តុះបណ្តាលស្តីពីប្រព័ន្ធប្រាក់កម្រៃសម្រាប់ការបណ្តុះបណ្តាលជំនាញ៖ បទពិសោធន៍របស់ប្រទេសកូរ៉េ ម៉ាឡេស៊ី និងសិង្ហបុរី)។ ដូច្នេះ ការអភិវឌ្ឍ និងលទ្ធភាពទទួលបានវគ្គសិក្សាស្តីពីការអភិវឌ្ឍជំនាញលឿន និងឆាប់រហ័ស គឺជាការចាំបាច់។ ក្នុងរយៈពេលមធ្យម សេដ្ឋកិច្ចកម្ពុជានឹងទទួលបានអត្ថប្រយោជន៍ពីការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើគុណភាព និងការរៀនសូត្រ។ ជារួម ត្រូវអភិវឌ្ឍជំនាញពិចារណាជាមូលដ្ឋាន ទាំងសម្រាប់សិស្សក្នុងប្រព័ន្ធអប់រំជាតិ និងក្នុងចំណោមកម្លាំងពលកម្មបច្ចុប្បន្ន។

### ប្រអប់ ស២ ៖ ប្រព័ន្ធប្រាក់កម្រៃសម្រាប់ការបណ្តុះបណ្តាលជំនាញ ពិសោធន៍ពីប្រទេសកូរ៉េ ម៉ាឡេស៊ី និងសិង្ហបុរី

ដើម្បីប្រមូលធនធានកាន់តែច្រើនសម្រាប់កម្មវិធីបណ្តុះបណ្តាលផ្សេងៗ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានប្រើប្រាស់កម្មវិធីថ្មីដែលផ្តល់ថវិកាបន្ថែម ដូចជាប្រាក់កម្រៃសំរាប់ការបណ្តុះបណ្តាលជំនាញដែលកំណត់ពន្ធពាក់កណ្តាល (០,៥%-២,០%) លើចំណាយលើប្រាក់ខែរបស់សហគ្រាស។ ធនធានទាំងនេះភាគច្រើនត្រូវបានបញ្ជូនទៅគ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់ជាតិ និងក្រុមជួបការលំបាកអ្នកគ្មានការងារធ្វើ និងនិយោជកខ្នាត តូច។ ប្រព័ន្ធនេះមានលក្ខណៈការិយាធិបតេយ្យ និងត្រូវចំណាយច្រើនក្នុងការប្រមូលពន្ធ និងដំណើរការកម្មវិធីបណ្តុះបណ្តាល ព្រមទាំងបានបង្កជាអំពើពុករលួយក្នុងចំណោមមន្ត្រីរដ្ឋាភិបាលនៅពេលប្រព័ន្ធនេះអនុញ្ញាតឲ្យមានការរួចពន្ធ ឬបន្ថយពន្ធសម្រាប់សហគ្រាសដែលផ្តល់កម្មវិធីបណ្តុះបណ្តាលដល់កម្មករនិយោជិតរបស់ខ្លួន។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងកែសម្រួលទៅតាមតម្រូវការនៃបរិយាកាសម៉ាក្រូសេដ្ឋកិច្ចនេះ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានកែប្រែប្រព័ន្ធនេះទៅជាប្រព័ន្ធផ្តល់កម្រៃ (ឧទាហរណ៍ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី និងសិង្ហបុរី)។ ជំនួសឲ្យការបញ្ជូនប្រាក់កម្រៃពីចំណាយប្រាក់ខែទៅកម្មវិធីបណ្តុះបណ្តាលរបស់រដ្ឋាភិបាល មូលនិធិពន្ធ ទូទាត់ ឬបង្វិលសងការចំណាយលើការបណ្តុះបណ្តាលរបស់សហគ្រាស។ គុណសម្បត្តិនៃប្រព័ន្ធនេះគឺថា វាជំរុញឲ្យនិយោជកស្ម័គ្រចិត្តផ្តល់ការបណ្តុះបណ្តាលក្នុងពេលបម្រើការដល់កម្មករនិយោជិតរបស់ខ្លួន តាមរយៈកម្មវិធីបណ្តុះបណ្តាលនៅកន្លែងការងារ ឬកម្មវិធីបណ្តុះបណ្តាលខាងក្រៅដោយគ្រឹះស្ថានបណ្តុះបណ្តាលដែលមានការទទួលស្គាល់ ដោយបង្វិលប្រាក់សងដល់ការចំណាយលើការបណ្តុះបណ្តាលដោយសហគ្រាសក្នុងទម្រង់ជាជំនួយឥតសំណង។ តាមវិធីនេះ កម្មវិធីជំនួយនេះអាចផ្តល់អត្ថប្រយោជន៍ដល់សហគ្រាសដែលចំណាយលើការបណ្តុះបណ្តាល ហើយកម្មវិធីបណ្តុះបណ្តាលអាចឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាសទាំងនោះកាន់តែខ្លាំង។

ជាក់ស្តែង សហគ្រាសជាច្រើនទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធទីពីរនេះច្រើនជាងប្រព័ន្ធទីមួយ ហើយកម្មករនិយោជិតកាន់តែច្រើនត្រូវបានបណ្តុះបណ្តាលពីគណនីនៃប្រព័ន្ធទីពីរនេះ។ ឧទាហរណ៍ នៅសិង្ហបុរី មូលនិធិអភិវឌ្ឍន៍ជំនាញត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧៩ ដើម្បីផ្តល់ការលើកទឹកចិត្តដល់ការអភិវឌ្ឍជំនាញកម្រិតខ្ពស់ដែលចាំបាច់សម្រាប់ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចឡើងវិញ ចំនួនកម្មករនិយោជិតដែលទទួលបានការបណ្តុះបណ្តាលបានកើនឡើង ៣ ដង ហើយចំនួនសហគ្រាសដែលទទួលបានអត្ថប្រយោជន៍ពីមូលនិធិនេះកើនឡើងជាង ២ ដងនៅឆ្នាំ ១៩៩១។

ក្រៅពីនេះ ការប្រមូលថវិការមានប្រសិទ្ធភាពកាន់តែខ្លាំងក្នុងប្រព័ន្ធទីពីរនេះ។ ប្រព័ន្ធនេះអាចបញ្ចៀសអំពើពុករលួយ និងភាពមិនប្រក្រតីផ្សេងទៀតបាន ព្រោះសហគ្រាសទាំងអស់ត្រូវចំណាយលើប្រព័ន្ធនេះជាមុនសិន ដោយមិនគិតថាសហគ្រាសនោះមានផែនការសម្រាប់បណ្តុះបណ្តាលកម្មករនិយោជិតដែរឬទេ ហើយការចំណាយលើការបណ្តុះបណ្តាលដែលបានធ្វើត្រូវទូទាត់សងវិញពីប្រព័ន្ធនេះ។ មិនចាំបាច់មានការលើកលែង ឬការបញ្ចុះតម្លៃពិសេសឡើយនៅក្នុងប្រព័ន្ធនេះ។ លើសពីនេះទៀត កម្មវិធីបណ្តុះបណ្តាលកាន់តែមានសារៈសំខាន់ ព្រោះកម្មវិធីទាំងនេះត្រូវបានរៀបចំ ឬចំណាយដោយសហគ្រាសផ្ទាល់ផ្អែកតាមតម្រូវការរបស់ខ្លួន។ គ្រឹះស្ថាន និងកម្មវិធីបណ្តុះបណ្តាលសាធារណៈ និងឯកជន កាន់តែមានប្រសិទ្ធភាពជាងមុន ព្រោះថាពួកគេប្រកួតប្រជែងក្នុងទីផ្សារបណ្តុះបណ្តាលសម្រាប់ឲ្យសហគ្រាសធ្វើការជ្រើសរើស។

**បង្កើតប្រព័ន្ធព័ត៌មានទីផ្សារការងារសម្រាប់ផ្គូផ្គងការងារ ៖ ការពង្រីកទម្រង់បែបបទសម្រាប់ជួយដល់ការផ្គូផ្គងការងារ។** ការបង្កើតព័ត៌មានទីផ្សារការងារស្តីពីការសិក្សា និងអាជីពជាសាធារណៈ តាមរយៈការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងអ៊ីនធើណិត គឺជាកត្តាអាទិភាព និងអាចសម្រេចបានក្នុងរយៈពេលខ្លី។ ការងារនេះរួមមាន ការផ្តោតសំខាន់លើបច្ចេកវិទ្យាក្នុងវិស័យឯកជនសម្រាប់មុខតំណែងដែលទំនេរ និងការបញ្ចូលសេវាស្វែងរកការងារសាធារណៈ និងឯកជន ការពង្រឹងមជ្ឈមណ្ឌលការងារ និងមជ្ឈមណ្ឌលអាជីពតាមសាលារៀន/សាកលវិទ្យាល័យ ដោយមានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងអ៊ីនធើណិត ដើម្បីផ្តល់ទិន្នន័យស្តីពីមុខតំណែងដែលទំនេរ និងការផ្គូផ្គងការងារ។

**ទាញយកតម្លៃកាន់តែច្រើនពីចល័តភាពរបស់កម្មករ (អន្តរជាតិ និងក្នុងស្រុក) ៖ ការសម្រួលដល់ពលករចំណាកស្រុកដែលត្រឡប់មកវិញដើម្បីនាំយកជំនាញ និងចំណេះធ្វើពីបរទេស មកបង្កើតការងារក្នុងស្រុក** តាមរយៈការបង្កើតកិច្ចព្រមព្រៀងទ្វេភាគីជាយុទ្ធសាស្ត្រ (និងបំពេញមុខងារល្អប្រសើរ) ជាមួយប្រទេសនានា ជាពិសេសប្រទេសមានប្រជាជនចាស់ៗ ដែលអាចផ្តល់ការងារដូចជា ការថែទាំមនុស្សចាស់ដល់កម្ពុជា ដោយទាញប្រយោជន៍ពីកម្លាំងពលកម្មកម្ពុជាយ៉ាងច្រើនដែលចេះភាសាអង់គ្លេស និងចិន ការចំណាយទាប (ចំនួនថ្ងៃ និងប្រាក់កាក់) លើការធ្វើចំណាកស្រុកស្របច្បាប់ដើម្បីរកការងារធ្វើក្នុងប្រទេស និងក្រៅប្រទេសដើម្បីទទួលបានជំនាញ និងចំណេះធ្វើសម្រាប់ការបង្កើតការងារបន្ថែមក្រៅពីសេវាធ្វើប្រាក់។

# ប្រទេសកម្ពុជា៖ សូចនាករសំខាន់ៗ

| | 2015 | 2016 | 2017e | 2018p | 2019f | 2020f |
|---|---|---|---|---|---|---|
| **លទ្ធផល និងកំណើនសេដ្ឋកិច្ច** | | | | | | |
| ផសស ពិត (% ប្រែប្រួល ឆ្នាំធៀបឆ្នាំ) | 7.0 | 7.0 | 6.8 | 6.9 | 6.7 | 6.6 |
| ផសស ចំណែកការចំណាយ (% តម្លៃបច្ចុប្បន្ន) | | | | | | |
| ការប្រើប្រាស់របស់ឯកជន | 75.4 | 74.0 | 72.0 | 70.5 | 69.0 | 68.8 |
| ការប្រើប្រាស់របស់រដ្ឋាភិបាល | 7.0 | 7.3 | 7.4 | 8.1 | 7.7 | 7.2 |
| ការវិនិយោគមិនប្រែប្រួលដុល | 21.4 | 21.7 | 21.9 | 22.2 | 23.1 | 23.5 |
| ការនាំចេញ ទំនិញ និងសេវាកម្ម១/ | 61.7 | 61.3 | 60.7 | 61.0 | 62.0 | 62.8 |
| ការនាំចូល ទំនិញ និងសេវាកម្ម | 66.6 | 65.7 | 64.2 | 63.6 | 63.6 | 64.0 |
| តម្រូវការក្នុងស្រុក (% ប្រែប្រួល ឆ្នាំធៀបឆ្នាំ) | 8.5 | 9.5 | 8.4 | 9.4 | 9.7 | 10.1 |
| ផសស សម្រាប់មនុស្សម្នាក់ៗ (US$ ណូមីណាល) | 1,171.0 | 1,264.9 | 1,374.9 | 1,493.0 | 1,617.9 | 1,764.4 |
| **រូបិយវត្ថុ និងតម្លៃ** | | | | | | |
| អតិផរណា តម្លៃសម្រាប់អ្នកប្រើប្រាស់ (% ប្រចាំឆ្នាំ រយៈពេលមធ្យម) | 1.3 | 3.5 | 3.4 | 3.2 | 3.4 | 3.3 |
| M2 (% នៃ ផសស) | 66.6 | 70.9 | 79.5 | 86.9 | 93.8 | 100.8 |
| ឥណទានក្នុងស្រុកទៅវិស័យឯកជន (% នៃ ផសស) | 75.0 | 92.0 | 109.0 | 120.7 | 126.7 | 131.1 |
| អត្រាប្តូរប្រាក់ណូមីណាល (រូបិយវត្ថុក្នុងស្រុក ធៀបនឹងដុល្លារអាមេរិក) | 4,025.0 | 4,058.0 | 4,062.0 | 4,067.0 | 4,075.0 | 4,050.0 |
| សន្ទស្សន៍អត្រាប្តូរប្រាក់ពិត (២០១០=១០០) | 104.5 | 105.5 | 106.7 | 108.1 | 109.8 | 113.8 |
| អត្រាការប្រាក់រយៈពេលខ្លី (% ក្នុងមួយឆ្នាំ) | 11.6 | 11.8 | 11.7 | 11.6 | 11.7 | 11.8 |
| **សារពើពន្ធ** | | | | | | |
| ចំណូល (% នៃ ផសស) | 17.6 | 18.5 | 19.7 | 18.7 | 18.7 | 18.8 |
| ការចំណាយ(% នៃ ផសស) | 21.1 | 22.0 | 22.3 | 24.6 | 24.1 | 24.0 |
| សមតុល្យសារពើពន្ធសរុប(% នៃ ផសស) | -3.5 | -3.6 | -2.7 | -5.9 | -5.4 | -5.3 |
| សមតុល្យសារពើពន្ធចម្បង(% នៃ ផសស) | -3.2 | -3.1 | -2.3 | -5.6 | -5.0 | -4.9 |
| បំណុលរួមរបស់រដ្ឋាភិបាល (% នៃផសស) | 31.3 | 32.4 | 33.8 | 35.3 | 36.1 | 36.7 |
| **គណនីខាងក្រៅ** | | | | | | |
| កំណើនការនាំចេញ ទំនិញដឹកត្រឹមផែ (ណូមីណាល គិតជាដុល្លារ ភាគរយប្រចាំឆ្នាំ) | 7.5 | 9.0 | 9.4 | 10.6 | 11.8 | 12.1 |

| | | | | | | |
|---|---|---|---|---|---|---|
| កំណើនការនាំចូល ទំនិញដឹកដល់អ្នកទិញ (ណូមីណល គិតជាដុល្លារ ភាគរយប្រចាំឆ្នាំ) | 8.4 | 8.2 | 7.8 | 9.2 | 10.0 | 11.3 |
| ការនាំចេញទំនិញ (% នៃ ផសស) | 45.4 | 45.5 | 45.2 | 44.8 | 45.2 | 45.2 |
| ការនាំចូលទំនិញ (% នៃផសស) | 57.8 | 56.9 | 55.6 | 55.1 | 55.0 | 55.3 |
| សេវាកម្ម សុទ្ធ (% នៃ ផសស) | 7.5 | 7.0 | 7.0 | 7.6 | 8.3 | 9.0 |
| សមតុល្យគណនេយ្យចរន្ត (គិតជាលានដុល្លារបច្ចុប្បន្ន) ២/ | -2,093.9 | -2,041.4 | -2,160.6 | -2,286.9 | -2,452.8 | -2,927.6 |
| សមតុល្យគណនេយ្យចរន្ត (% នៃ ផសស) | -11.5 | -10.2 | -9.8 | -9.4 | -9.2 | -9.9 |
| ការវិនិយោគទុនផ្ទាល់ពីបរទេស (សុទ្ធ គិតជាលានដុល្លារបច្ចុប្បន្ន) | 1,668.8 | 2,164.4 | 2,381.0 | 2,664.7 | 2,850.5 | 3,104.8 |
| ការវិនិយោគទុនផ្ទាល់ពីបរទេស លំហូរសុទ្ធ(% នៃ ផសស) | 9.1 | 10.8 | 10.8 | 10.9 | 10.6 | 10.5 |
| ប្រាក់បម្រុងរូបិយវត្ថុបរទេស ដុល(គិតជាលានដុល្លារបច្ចុប្បន្ន) | 5,672.1 | 6,730.8 | 8,757.9 | 9,852.6 | 10,936.4 | 12,030.1 |
| (ខែរំពឹងទុកនៃការនាំចូលទំនិញ និងសេវាកម្ម) | 5.2 | 5.7 | 6.8 | 6.9 | 6.9 | 6.8 |
| សម្គាល់ ៖ ផសស ណូមីណល (គិតជាលានដុល្លារបច្ចុប្បន្ន) | 18,241.7 | 20,020.2 | 22,095.9 | 24,355.5 | 26,777.0 | 29,614.6 |

*ប្រភព៖* អាជ្ញាធរកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ និងការប៉ាន់ប្រមាណ និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក។

e = ការប៉ាន់ប្រមាណ f= ការទស្សន៍ទាយ p = ការព្យាករណ៍

1/ មិនរួមបញ្ចូលការផ្ទេរទេ។

ក្រុមធនាគារពិភពលោក

ធនាគារពិភពលោក
ប្រចាំនៅប្រទេសកម្ពុជា
អគារ Exchange Square
ជាន់ទី 10 IBRD និងជាន់ទី 11 IFC
ផ្លូវលេខ 51-61 និងផ្លូវលេខ 102-106
សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ
ភ្នំពេញ ប្រទេសកម្ពុជា
គេហទំព័រ: www.worldbank.org/cambodia